មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ ឆ្នាំ២០១៣

# កម្ពុជា៖ ដីមានជម្លោះ
# ទិដ្ឋភាពនៃស្ថានភាពដីធ្លី



## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធឈានមុខគេ ដែលធ្វើការដើម្បីលើកកម្ពស់ និងការការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា)។ ចក្ខុវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺចង់ឲ្យប្រទេសកម្ពុជាក្លាយជាព្រះរាជាណាចក្រដែលគ្មានអំពើហិង្សា ដែល ប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចង់បាននីតិរដ្ឋ ជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំ ជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយម ដែលក្នុងនោះភាពខុសគ្នាត្រូវបានត្រួតពិនិត្យ និងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ រូបសញ្ញារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បង្ហាញពីសត្វព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវតំណាងឲ្យការទាមទារសេរីភាពរបស់កម្ពុជា។

របាយការណ៍ស្តីអំពី «កម្ពុជា៖ ដីមានជម្លោះ» (តទៅហៅថា «របាយការណ៍») ជាសមិទ្ធផលរបស់គម្រោងកែទម្រង់ដីធ្លីរបស់ម.ស.ម.ក ហើយរបាយការណ៍នេះ បង្ហាញពីទិដ្ឋភាពទូទៅនៃជម្លោះដីធ្លីដែលបានប៉ះពាល់ប្រទេសកម្ពុជា ដោយចាប់ផ្តើមពិនិត្យពីឫសគល់នៃបញ្ហា ទម្រង់នៃបញ្ហា និងផលប៉ះពាល់នៃបញ្ហាជម្លោះនេះ។ របាយការណ៍នេះ បានប្រើប្រាស់ទិន្នន័យ និងករណីសិក្សាដែលបុគ្គលិករបស់ម.ស.ម.ក បានប្រមូលចងក្រងទុក។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះអាចកើតជារូបរាងឡើងបាន គឺដោយសារកិច្ចឧបត្ថម្ភគាំទ្ររបស់សហភាពអឺរ៉ុប និងអង្គការអន្តរព្រះវិហារសម្រាប់កិច្ចសហប្រតិបត្តិការការងារអភិវឌ្ឍន៍(ICCO ឬ អ៊ីកូ)។ ខ្លឹមសារនៃរបាយការណ៍នេះជាការទទួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងទស្សនៈរបស់សហភាពអឺរ៉ុប និងអ៊ីកូនោះឡើយ។ ម.ស.ម.ក សូមថ្លែងអំណរគុណដល់អ្នកទាំងឡាយដែលបានចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម និងកិច្ចសម្ភាសនានា ដែលផ្តល់ជាព័ត៌មានដ៏មានសារៈសំខាន់ ដើម្បីបំពេញដល់ការចងក្រងរបាយការណ៍នេះឡើង។

## សំណួរ និងមតិប្រតិកម្ម

ប្រសិនលោកអ្នកមានសំណួរឬត្រូវការព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងរបាយការណ៍នេះឬមានបំណងចង់ផ្តល់ជាមតិយោបល់ សូមសរសេរជាអ៊ីមែលមកកាន់ ម.ស.ម.ក តាមរយៈ៖ info@cchrcambodia.org ។

របាយការណ៍នេះ និងការបោះពុម្ពផ្សាយទាំងអស់របស់ ម.ស.ម.ក គឺអាចរកបាននៅក្នុងគេហទំព័រសិទ្ធិមនុស្សដែលទទួលបានពានរង្វាន់ គឺ www.sithi.org ដែលគ្រប់គ្រងដោយ ម.ស.ម.ក។ ម្យ៉ាងទៀត លោកអ្នកអាចទាក់ទង ម.ស.ម.ក តាមរយៈ៖

ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក
ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អ៊ីមែល៖ info@cchrcambodia.org

ទូរស័ព្ទ៖ ៨៥៥(០)២៣ ៧២ ៦៩ ០១

ទូរសារ៖ ៨៥៥(០)២៣ ៧២ ៦៩ ០២

វេបសាយ៖ www.cchrcambodia.org

CC BY NC SA

# មាតិកា


និយមន័យ និងពាក្យកាត់ .......... iii

សេចក្ដីសង្ខេប .......... v

១. សេចក្ដីផ្ដើម .......... ១

១.១. សិទ្ធិដីធ្លីទៅតាមប្រវត្តិសាស្ត្រប្រទេសកម្ពុជា .......... ១

១.២. ទិដ្ឋភាពរួមនៃស្ថានភាពដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ន .......... ៤

១.៣. គោលបំណង វិសាលភាព និងវិធីសាស្ត្រ .......... ៧

២. ទ្រឹស្ដី៖ ក្របខណ្ឌការពារដោយច្បាប់.......... ៩

២.១. ការធានាសិទ្ធិដីធ្លីតាមច្បាប់អន្តរជាតិ.......... ៩

២.១.១. សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ .......... ១០

២.១.២. សិទ្ធិទទួលបានសុវត្ថិភាពក្នុងការកាន់កាប់ .......... ១០

២.១.៣. សិទ្ធិមិនត្រូវបានគេបណ្ដេញចេញដោយបង្ខំ .......... ១១

២.១.៤. គោលការណ៍និងសេចក្ដីណែនាំអន្តរជាតិការពារសិទ្ធិដីធ្លី .......... ១២

២.២. ការធានាសិទ្ធិដីធ្លីតាមច្បាប់ជាតិ.......... ១៣

២.២.១. ទ្រព្យសម្បត្តិឯកជន.......... ១៤

២.២.២. ទ្រព្យសម្បត្តិសមូហភាព.......... ១៥

២.២.៣. ទ្រព្យសម្បត្តិរដ្ឋ.......... ១៧

២.២.៤. សម្បទានដី.......... ១៨

៣. ការអនុវត្តជាក់ស្ដែង៖ មិនបានអនុលោមតាមច្បាប់.......... ២១

៣.១. អសុវត្ថិភាពក្នុងការកាន់កាប់ដី .......... ២១

៣.១.១. កម្មវិធីចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ.......... ២២

៣.១.២. កម្មវិធីចុះបញ្ជី ក្រុមយុវជនស្ម័គ្រចិត្តសម្ដេចតេជោ.......... ២៥

៣.១.៣. ការចុះបញ្ជីកម្មសិទ្ធិសមូហភាពរបស់ក្រុមជនជាតិដើមភាគតិច .......... ២៧

៣.២. ការអភិវឌ្ឍមិនអនុលោមតាមវិធានច្បាប់ .......... ២៩

៣.២.១. មន្ត្រីរដ្ឋាភិបាល និងសម្បទានដីធ្លី.......... ២៩

៣.២.២. ខ្វះការពិគ្រោះយោបល់ និងការវាយតម្លៃ.......... ៣០

៣.២.៣. ការគ្រប់គ្រងសម្បទានជាទូទៅដែលនៅទន់ខ្សោយ ..... ៣២
៣.២.៤. កំណែទម្រង់ពិតប្រាកដ? ..... ៣៣
៣.៣. ការបណ្តេញចេញដោយបង្ខំ និងអំពើហិង្សាដែលពាក់ព័ន្ធ ..... ៣៤
៣.៣.១. ការបណ្តេញចេញដោយបង្ខំរួមជាមួយច្បាប់ដែលគ្មានដំណើរការត្រឹមត្រូវ ..... ៣៤
៣.៣.២. ការបណ្តេញចេញដោយបង្ខំរួមជាមួយការប្រើហិង្សា ..... ៣៦
៣.៣.៣. គ្មានចំណុចបញ្ចប់៖ គ្មានយន្តការដោះស្រាយជម្លោះ ..... ៤០
៤. លទ្ធផល៖ ការវាយតម្លៃលើផលប៉ះពាល់នៃជម្លោះដីធ្លី ..... ៤៣
៤.១. ផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ចមកលើប្រជាពលរដ្ឋរងគ្រោះ ..... ៤៣
៤.២. ផលប៉ះពាល់មកលើស្ត្រី និងកុមារ ..... ៤៥
៤.៣. ផលប៉ះពាល់មកលើជនជាតិដើមភាគតិច ..... ៤៩
៤.៤. ផលប៉ះពាល់លើបរិស្ថាន ..... ៥០
៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..... ៥៤
៥.១. សេចក្តីសន្និដ្ឋាន ..... ៥៤
៥.២. អនុសាសន៍ ..... ៥៤
៥.២.១. ពាក់ព័ន្ធនឹងតម្លាភាព ..... ៥៥
៥.២.២. ពាក់ព័ន្ធនឹងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ..... ៥៥
៥.២.៣. ពាក់ព័ន្ធនឹងការពិគ្រោះយោបល់ ..... ៥៦
៥.២.៤. ពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ ..... ៥៦
៥.២.៥. ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានសំណងដ៏មានប្រសិទ្ធភាព ..... ៥៦
៥.២.៦. ពាក់ព័ន្ធនឹងសិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំ និងសិទ្ធិធ្វើសមាគម ..... ៥៧
ឯកសារយោង ..... ៥៨

# និយមន័យ និងពាក្យកាត់

| | |
|---|---|
| អង្គការអាដហុក | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| គ.ស.ស.ស.វ | គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ម.ស.ល.ប | មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (ត្រូវបានធ្វើវិសោធនកម្ម) |
| ប្រ.ជ | គណបក្សប្រជាជនកម្ពុជា |
| បទបញ្ជាលេខ ០១ បប | បទបញ្ជាលេខ ០១ បប ស្តីពី វិធានការពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច |
| ច្បាប់អស្សាមិករណ៍ | ច្បាប់ស្តីពី អស្សាមិករណ៍ ឆ្នាំ២០១០ |
| គ.ស.ម | គណបក្សសិទ្ធិមនុស្ស |
| ក.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.ស.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ច្បាប់ភូមិបាល | ច្បាប់ភូមិបាល ឆ្នាំ២០០១ |
| អង្គការលីកាដូ | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ) |
| ក្រសួងកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក្រសួងបរិស្ថាន | ក្រសួងបរិស្ថាន |
| ក្រសួងរៀបចំដែនដី | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រសួងអភិវឌ្ឍន៍ជនបទ |

| | |
|---|---|
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |
| ការិយាល័យឧត្តមស្នងការអ.ស.ប | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា |
| ក្រុមហ៊ុនផានអ៊ីម៉ិច | ក្រុមហ៊ុនផានអ៊ីម៉ិច |
| គោលការណ៍ស្តីពីការដោះស្រាយមាន ប្រសិទ្ធភាពចំពោះលំនៅដ្ឋាន | គោលការណ៍ស្តីពីការដោះស្រាយមានប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិសម្រាប់ជនភៀសខ្លួន និងជនភៀសសឹក |
| របាយការណ៍ | របាយការណ៍ស្តីអំពី «កម្ពុជា៖ ដីមានជម្លោះ» |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| អ្នករាយការណ៍ពិសេសអ.ស.ប | អ្នករាយការណ៍ពិសេសរបស់អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា |
| អនុក្រឹត្យលេខ១៩ | អនុក្រឹត្យលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ច |
| អនុក្រឹត្យលេខ៨៣ | អនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច |
| អនុក្រឹត្យលេខ១២៩ | អនុក្រឹត្យលេខ១២៩ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ |
| អនុក្រឹត្យលេខ១៤៦ | អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច |
| ស.ប.ស.ស | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| ស.ស.ជ | សេចក្តីប្រកាសអ.ស.បស្តីពីសិទ្ធិជនជាតិដើមភាគតិច |
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្នអ.ស.ប |

# សេចក្តីសង្ខេប

ដូចដែលអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (អ្នករាយការណ៍ពិសេសអ.ស.ប) បានធ្វើការកត់សម្គាល់ នៅចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់ អ.ស. កាលពីខែសីហា គឺថា«សិទ្ធិដីធ្លីបន្តជាបញ្ហាដ៏ធំនៅក្នុងប្រទេសនេះ»។[១] ជម្លោះដីធ្លី គួបផ្សំនឹងការបំពានលើសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ និងយ៉ាងរីករាលដាលនោះ គឺជាបញ្ហាសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរមួយដែលពលរដ្ឋកម្ពុជាទូទាំងប្រទេសបានប្រឈម ហើយឫសគល់មួយដែលអាចកត់សម្គាល់បាននោះ គឺការលុបបំបាត់ចោលនូវភាពជាម្ចាស់កម្មសិទ្ធិឯកជន នៅពេលដែលខ្មែរក្រហមបានឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។

អស់ជាងពីរសតវត្សរ៍ បន្ទាប់ពីសង្គ្រាមស៊ីវិលបានបញ្ចប់រួចមក ឥទ្ធិពលនៃផលប៉ះពាល់នេះនៅតែបន្សល់ទុកមកដល់ពេលបច្ចុប្បន្ននៅឡើយ។ ថ្វីបើមានក្របខណ្ឌច្បាប់ដែលអាចការពារសិទ្ធិដីធ្លីយ៉ាងណាក៏ដោយ ពលរដ្ឋកម្ពុជាជាច្រើននៅតែមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីរបស់ពួកគាត់។ ជាជាងការស្តារឡើងវិញនូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីជាច្រើនឆ្នាំបន្ទាប់ពីការផ្លាស់ប្តូរទីលំនៅទាំងបង្ខំ គោលនយោបាយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(រដ្ឋាភិបាល)បច្ចុប្បន្ន បានកេងចំណេញពីលើកង្វះប័ណ្ណកាន់កាប់ដីធ្លី ក្នុងការត្រួសត្រាយផ្លូវឲ្យគម្រោងអភិវឌ្ឍន៍ដែលមិនបានបំពេញតាមលក្ខខណ្ឌច្បាប់អាចប្រព្រឹត្តទៅបាន។ គោលនយោបាយទាំងនេះ រួមផ្សំនឹងការមិនអនុលោមតាមវិធានច្បាប់ និងកង្វះឆន្ទៈនយោបាយផងនោះ បានធ្វើឲ្យទំនាស់ដីធ្លីក្លាយទៅជាជម្លោះដ៏រ៉ុាំរ៉ៃ ហើយដែលការបណ្តេញចេញដោយបង្ខំបានបន្តកើតមាន។ មកទល់នឹងបច្ចុប្បន្ននេះ ពលរដ្ឋដែលរងផលប៉ះពាល់បានបន្តខកចិត្តយ៉ាងខ្លាំង ហើយប្រការនេះបានបណ្តាលឲ្យមានការតវ៉ានិងការប្រឆាំងជាច្រើន ចំពោះការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ។

ចំពោះមុខនៃការកើនឡើងយ៉ាងធ្ងន់ធ្ងរនៃជម្លោះដីធ្លីនៅកម្ពុជា របាយការណ៍នេះត្រូវបានតាក់តែងឡើងដើម្បីរៀបរាប់ពីប្រភព ទម្រង់ និងផលប៉ះពាល់បង្កពីជម្លោះនេះនៅទូទាំងប្រទេស។ របាយការណ៍នេះផ្តល់នូវទិដ្ឋភាពរួមនៃជម្លោះដីធ្លីនៅក្នុងប្រទេស ព្រមទាំងផ្តល់ជាអនុសាសន៍ដល់រដ្ឋាភិបាលផងដែរ។

ជំពូកទី១ (សេចក្តីផ្តើម) ផ្តល់នូវទិដ្ឋភាពសង្ខេបនៃស្ថានភាពសិទ្ធិដីធ្លី និងប្រព័ន្ធផ្សេងៗគ្នាជាម្ចាស់កម្មសិទ្ធិដីធ្លីទៅតាមប្រវត្តិសាស្ត្រនៃប្រទេស និងស្ថានភាពដីធ្លីនាពេលបច្ចុប្បន្ន មុននឹងឈានដល់ការពិភាក្សាលើវិសាលភាព វិធីសាស្ត្រ និងគោលបំណងនៃរបាយការណ៍។

ជំពូកទី២ (ទ្រឹស្តីៈក្របខណ្ឌការពារដោយច្បាប់) បរិយាយនូវទិដ្ឋភាពសិទ្ធិតាមច្បាប់ជាតិនិងអន្តរជាតិ ព្រមទាំងកាតព្វកិច្ចពាក់ព័ន្ធនឹងសិទ្ធិដីធ្លីនិងលំនៅដ្ឋាន ដែលត្រូវអនុវត្តនៅកម្ពុជា។

---

[១] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា» (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣) http://bit.ly/17G77ox

ជំពូកទី៣ (ការអនុវត្តជាក់ស្តែង៖ មិនបានអនុលោមតាមច្បាប់) រៀបរាប់ពីភាពទន់ខ្សោយក្នុងការអនុវត្តន៍ច្បាប់ទាំងឡាយដូចដែលបានរៀបរាប់ក្នុងជំពូកទី២ ដែលនេះបង្កឲ្យទៅជាអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ការអភិវឌ្ឍដែលមិនអនុលោមតាមវិធានច្បាប់និងមិនមានតម្លាភាព ព្រមទាំងការបណ្តេញចេញដោយបង្ខំដែលប្រកបដោយហឹង្សាផងដែរ។ ជំពូកនេះ ក៏សិក្សាចំពោះកង្វះយន្តការដោះស្រាយជម្លោះនិងសំណងនានាក្នុងករណីមានទំនាស់ដីធ្លី និងការបំពានសិទ្ធិនោះ។

ជំពូកទី៤ (លទ្ធផលៈការវាយតម្លៃលើផលប៉ះពាល់នៃជម្លោះដីធ្លី) គូសបញ្ជាក់ពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផ្នែកសង្គមសេដ្ឋកិច្ច ដែលបណ្តាលមកពីការបណ្តេញចេញដោយបង្ខំ ជាពិសេសផលប៉ះពាល់ពីជម្លោះដីធ្លីចំពោះស្ត្រី កុមារ ពលរដ្ឋជនជាតិដើមភាគតិច និងផលប៉ះពាល់យ៉ាងអន្តរាយចំពោះបរិស្ថាន។

ជំពូកទី៥ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍) ធ្វើការសន្និដ្ឋានថា ជម្លោះដីធ្លីនៅកម្ពុជាគឺមានលក្ខណៈហឹង្សា រីករាលដាល និងនៅតែបន្ត ហើយជំពូកនេះផ្តល់ជាអនុសាសន៍ដល់រដ្ឋាភិបាលដើម្បីប្រែស្ថានការណ៍ឲ្យមានលក្ខណៈវិជ្ជមានវិញ។

# ១. សេចក្តីផ្តើម

ប្រវត្តិសាស្រ្តនយោបាយដ៏ជូចត់ដែលកម្ពុជាបានឆ្លងកាត់ បានចូលរួមចំណែកដល់ស្ថានភាពដីធ្លីនាពេលបច្ចុប្បន្នដែលមិនទាន់បានដោះស្រាយត្រឹមត្រូវនៅឡើយ៖ រាល់របបនយោបាយ រាប់ចាប់ពីសក្តិភូមិនិយមទៅដល់របបក្រោមអាណានិគម និងរបបកម្មុយនីស្ត បានបង្កើតជាប្រព័ន្ធកាន់កាប់កម្មសិទ្ធិដោយឡែកៗពីគ្នា។ ដើម្បីស្វែងយល់ឲ្យបានច្បាស់ពីជម្លោះដីធ្លីនាពេលបច្ចុប្បន្ននោះ ជំពូកនេះផ្តល់នូវទិដ្ឋភាពរួមនៃរបបកាន់កាប់កម្មសិទ្ធិដីធ្លីផ្សេងៗទៅតាមសម័យកាលប្រវត្តិសាស្រ្ត និងកេរដំណែលនៃរបបនោះបានបន្សល់មកជាជម្លោះដីធ្លីនាពេលបច្ចុប្បន្ន ព្រមទាំងផ្តល់ជាទិដ្ឋភាពនៃស្ថានការណ៍បច្ចុប្បន្នពាក់ព័ន្ធនឹងសិទ្ធិដីធ្លី នៅកម្ពុជា និងបង្ហាញពីវិធីសាស្រ្តដែលម.ស.ម.ក បានប្រើប្រាស់សម្រាប់តាក់តែងរបាយការណ៍នេះផងដែរ។

## ១.១. សិទ្ធិដីធ្លីនៅតាមប្រវត្តិសាស្រ្តប្រទេសកម្ពុជា

កម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូររបបនយោបាយជាច្រើន ហើយការផ្លាស់ប្តូរនេះ បានប៉ះពាល់ដល់ក្របខណ្ឌសិទ្ធិដីធ្លីផងដែរ។ សិទ្ធិកាន់កាប់ដីធ្លីមានលក្ខណៈខុសៗគ្នាទាំងអស់ រាប់ចាប់តាំងពីការគ្រប់គ្រងបែបសក្តិភូមិនិយមទៅជាអាណានិគមបារាំង ពីការបះបោររបស់ខ្មែរក្រហម ទៅកម្មុយនីស្តជាច្រើនឆ្នាំបន្ទាប់ពីការឈ្លានពានរបស់ប្រទេសវៀតណាមនៅឆ្នាំ១៩៧៩ និងចុងក្រោយពីមូលធននិយមទៅជាប្រព័ន្ធសេដ្ឋកិច្ចសេរីដែលត្រូវបានប្រកាន់ភ្ជាប់មកទល់នឹងបច្ចុប្បន្ន ។

កម្ពុជាមុនសម័យអាណានិគម នោះគឺថា ព្រះមហាក្សត្រមានកម្មសិទ្ធិលើដីទាំងស្រុងនៅទូទាំងប្រទេស ហើយកម្ពុជាបានប្រើប្រាស់ប្រព័ន្ធសក្តិភូមិ ដែលភាគច្រើនពលរដ្ឋជាអ្នកស្រែចំការរស់នៅតាមជនបទ និងប្រកបរបរភ្ជួរស្រែ។ ប្រព័ន្ធសក្តិភូមិនិយមបានបន្តអនុវត្ត រហូតដល់ពេលដែលបារាំងបានចូលមកដាក់អាណាព្យាបាលនៅកម្ពុជា ក្នុងឆ្នាំ១៨៦៣។ ក្នុងអំឡុងកាលអាណានិគម ដែលបន្តរហូតដល់ឆ្នាំ១៩៥៣ បារាំងបានព្យាយាមប្រែប្រព័ន្ធឲ្យទៅជា «ប្រព័ន្ធមានកម្មសិទ្ធិអាស្រ័យលើការប្រើប្រាស់» ដោយមានប្រព័ន្ធកម្មសិទ្ធិ ដែលមាន «ប័ណ្ណកាន់កាប់» ស្របច្បាប់។ ទោះជាយ៉ាងនេះក្តី កសិករជាច្រើនបានតវ៉ាប្រឆាំងនឹងការផ្លាស់ប្តូរនេះ ហើយជាលទ្ធផល ច្បាប់ដ៏ចម្បងមួយក្នុងគោលបំណងផ្តល់នូវសិទ្ធិលើទ្រព្យសម្បត្តិនោះ ពោលគឺ ច្បាប់ភូមិបាលឆ្នាំ១៨៨៤ មិនត្រូវបានអនុវត្តពេញលេញនោះទេ រហូតដល់ឆ្នាំ១៩១២។[2] ក្នុងឆ្នាំ១៩២០ ទស្សនទាននៃភាពជាម្ចាស់កម្មសិទ្ធិរបស់បារាំង ត្រូវបានពង្រឹងបន្ថែមនៅពេលដែលក្រមរដ្ឋប្បវេណីត្រូវបានអនុម័ត ដែលក្នុងនោះ

---

២ សឹក បូរ៉ក្ស, «ភាពជាម្ចាស់កម្មសិទ្ធិ, លក់ និងការក្តោបក្តាប់ដីធ្លីនៅកម្ពុជា៖ ការពិនិត្យបឋមលើទិន្នន័យដែលមានស្រាប់ និងទិន្នន័យដែលប្រមូលបានពីការស្ទង់មតិថ្មីៗចំនួន៤» (ខែកញ្ញា ឆ្នាំ២០០០), ឯកសារសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) លេខ១៦, ទំព័រទី៣ http://bit.ly/18AWa17

ភាពជាម្ចាស់កម្មសិទ្ធិត្រូវបានគេឲ្យនិយមន័យថា «ច្បាប់ដែលអនុញ្ញាតឲ្យប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនដោយគ្មានការហាមប្រាម។»[៣]

នៅឆ្នាំ១៩៥៣ កម្ពុជាបានទទួលឯករាជ្យពីបារាំង ហើយក្នុងចន្លោះឆ្នាំ១៩៥៣ និងឆ្នាំ១៩៧០ កម្ពុជាត្រូវបានគេស្គាល់ថា ជាព្រះរាជាណាចក្រកម្ពុជា។ ក្នុងអំឡុងពេលនោះ ប្រព័ន្ធបែបបារាំងនៃសិទ្ធិលើទ្រព្យសម្បត្តិត្រូវបានបន្តអនុវត្ត ហើយកម្មសិទ្ធិលើទ្រព្យសម្បត្តិទៀតសោតនោះ ក៏បានកើនឡើងផងដែរ។ នៅឆ្នាំ១៩៧០ បដិវត្តន៍មួយបានកើតឡើង ទម្លាក់ព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាប្រមុខរដ្ឋចេញពីអំណាច ហើយបានបំពាក់នូវរដ្ឋាភិបាលដែលនិយមលោកខាងលិច ដោយមានលោកសេនាប្រមុខ លន់ នល់ ជាអ្នកដឹកនាំ ដែលពេលនោះហើយជាការចាប់ផ្តើមនៃសម័យសាធារណរដ្ឋខ្មែរ រហូតដល់ឆ្នាំ១៩៧៥។ ថ្វីបើគ្មានការផ្លាស់ប្តូរផ្នែកច្បាប់ណាមួយ ពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី និងទ្រព្យសម្បត្តិក្នុងអំឡុងសាធារណរដ្ឋខ្មែរយ៉ាងណាក្តី បម្រែបម្រួលពាក់ព័ន្ធនឹងការបែងចែកដីធ្លីបានកើតមានឡើង ដោយថាកសិករនៅតាមជនបទជាច្រើនបានបោះបង់វាលស្រែរបស់ខ្លួន មករស់នៅតាមបណ្តាទីក្រុង ដើម្បីគេចផុតពីយុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិក សំដៅមកលើតំបន់ជនបទនៃប្រទេសកម្ពុជា។ ក្នុងអំឡុងពេលនោះ សង្គ្រាមស៊ីវិលក៏កើតមានជាបន្តបន្ទាប់រវាងខ្មែរក្រហម និងកងម្លាំងរបស់ លន់ នល់ ផងដែរ។

បន្ទាប់ពីខ្មែរក្រហមបានផ្តួលរលំរបប លន់ នល់ ហើយបានក្តោបក្តាប់ទីក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក ប៉ុល ពត និងរដ្ឋាភិបាលជ្រុលនិយមរបស់ខ្លួនបានប្រកាស «ឆ្នាំសូន្យ» ហើយបានផ្លាស់ប្តូរឈ្មោះប្រទេសទៅជា កម្ពុជាប្រជាធិបតេយ្យ។ ខ្មែរក្រហមបានបង្កើតសង្គមអាស្រ័យកសិកម្ម ហើយដើម្បីសម្រេចគោលដៅនោះ ខ្មែរក្រហមបានលុបបំបាត់ចោលនូវរូបិយវត្ថុ និងជម្លៀសពលរដ្ឋដោយបង្ខំចេញពីទីក្រុង ព្រមទាំងបញ្ញវន្ត និងអ្នកចេះដឹងផ្សេងៗត្រូវបានគេសម្លាប់យ៉ាងសាហាវ។ របបខ្មែរក្រហមបានអនុវត្តភ្លាមៗ នូវការផ្លាស់ប្តូរជ្រុលហួសហេតុ ហើយតំបន់ទីក្រុងសឹងតែទាំងស្រុងត្រូវបានបោះបង់ចោល ដោយសារតែមនុស្សទាំងអស់ត្រូវបានជម្លៀសចេញទាំងបង្ខំឲ្យទៅនៅទីជនបទដើម្បីធ្វើការបង្កបង្កើនផលលើដីធ្លី។ ការបង្កបង្កើនផលស្រូវត្រូវបានចាត់ទុកជាអាទិភាពខ្ពស់បំផុត ហើយដីស្រែត្រូវបានកែទម្រង់ និងកសិកម្មជាការងារសមូហភាព។ របបនេះបានលុបបំបាត់ទាំងស្រុងជាលក្ខណៈប្រព័ន្ធ នូវរាល់កំណត់ហេតុកាន់កាប់ទ្រព្យសម្បត្តិ និងលុបចោលនូវសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ រាល់ផ្ទះសម្បែង ទ្រព្យសម្បត្តិ និងដីធ្លីទាំងអស់ ជាកម្មសិទ្ធិរបស់ «អង្គការ» (សំដៅដល់រដ្ឋដឹកនាំ)។ អ្នកទាំងឡាយដែលជាអ្នកជំនាញខាងច្បាប់ភូមិបាល ការគ្រប់គ្រងដីធ្លី ឬរដ្ឋបាលដីធ្លីត្រូវបានផ្លាស់ទីលំនៅ ឬស្រដៀងនឹងអ្នកដទៃដែលមានចំណេះដឹងខ្ពង់ខ្ពស់នោះ គឺត្រូវបានយកទៅសម្លាប់ចោល។

ក្នុងឆ្នាំ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបង្កើតឡើង ដោយប្រទេសវៀតណាម បន្ទាប់កងទាហានរបស់ខ្លួនបានឈ្លានពានចូលមកប្រទេសកម្ពុជា ដោយបានដកហូតអំណាចពីខ្មែរក្រហម។ ទោះជាយ៉ាងនេះក្តី ពុំមានការស្តារឡើងវិញនូវប្រព័ន្ធភាពជាម្ចាស់កម្មសិទ្ធិឯកជននោះទេ ហើយរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១

---

[៣] ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ឆ្នាំ១៩២០ មាត្រា៦៤៤, ដកស្រង់ពី ហែល ចំរើន, «ការណែនាំច្បាប់ភូមបាលនៃប្រទេសកម្ពុជា» នៅក្នុងរបាយការណ៍របស់ ហោ ផេង, គង់ ផល្លៈ និងជត មែនហ្សែល, ការណែនាំច្បាប់កម្ពុជា (២០១២) ទំព័រទី៣១៦ http://bit.ly/18AYchV

បានចែងថាពល់ដីធ្លី និងធនធានធម្មជាតិទាំងឡាយ ជាទ្រព្យសម្បត្តិរបស់រដ្ឋ។[៤] គ្រួសារនីមួយៗត្រូវបានផ្តល់សិទ្ធិអាស្រ័យផល(សិទ្ធិប្រើប្រាស់និងទាញយកផលចំណេញ ពីទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃទៀត) លើដីជនបទ និងអ្នករស់នៅជាយក្រុងមិនត្រូវបានលើកទឹកចិត្តឲ្យត្រឡប់មកចូលទីក្រុងនោះទេ។ ប៉ុន្តែ អចលនទ្រព្យ នៅតាមតំបន់ទីក្រុងសំខាន់ៗ ត្រូវបានគេចែករំលែកទៅឲ្យមន្ត្រីជាន់ខ្ពស់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាទៅវិញ។[៥] ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០មក សិទ្ធិកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិនានាត្រូវបានធ្វើឲ្យលែងជារបស់សមូហភាពបន្តិចម្តងៗ ហើយសាធារណរដ្ឋប្រជាមានិតបានប្រគល់កិច្ចការរដ្ឋបាលក្នុងការបំលែងសមូហភាពនេះទៅឲ្យមន្ត្រីមូលដ្ឋានទៅវិញ។ ប៉ុន្តែ ដោយសារតែគ្មានរចនាសម្ព័ន្ធ ឬក្របខណ្ឌច្បាប់ផ្លូវការនោះ ការអនុវត្តន៍ផែនការនេះ ត្រូវបានគេបំពាន ហើយទំនោរទៅរកខ្សែរយៈអ្នកមានអំណាច។

នៅឆ្នាំ១៩៨៩ សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានប្តូរឈ្មោះទៅជារដ្ឋកម្ពុជា ហើយគណបក្សកាន់អំណាចបានកែប្រែទៅជា គណបក្សប្រជាជនកម្ពុជា(ប្រ.ជ)។ ប្រទេសនេះបានចាប់ផ្តើមលុបដានអតីតកាលនៃរបបកុម្មុយនីស្ត ហើយរដ្ឋាភិបាលបានបិតក្នុងអន្តរកាលទៅរកប្រព័ន្ធសេដ្ឋកិច្ចសេរី។ វិនិយោគិនបរទេសត្រូវបានទទួលស្វាគមន៍យ៉ាងខ្លាំង ហើយសិទ្ធិលើទ្រព្យសម្បត្តិឯកជនត្រូវបានទទួលស្គាល់ និងដាក់ឲ្យប្រើប្រាស់ឡើងវិញ។ បិតក្រោមការដឹកនាំរបស់រដ្ឋកម្ពុជា ដីធ្លីនៅតែជាទ្រព្យសម្បត្តិរបស់រដ្ឋដដែល ហើយមូលដ្ឋានច្បាប់ពាក់ព័ន្ធនឹងម្ចាស់កម្មសិទ្ធិលើដីធ្លីត្រូវបានគេធ្វើឲ្យជឿនលឿន តាមរយៈការដាក់ចេញនូវច្បាប់ភូមិបាល ឆ្នាំ១៩៩២។ ទោះជាយ៉ាងនេះក្តី វិសាលភាពនៃភាពជាម្ចាស់កម្មសិទ្ធិដីធ្លី ដែលបានចែងក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ នៅមានលក្ខណៈចង្អៀត និងមិនច្បាស់លាស់ ដោយសារថាសិទ្ធិនោះត្រូវបានគេយល់ថាជាការកាន់កាប់តែបណ្តោះអាសន្ន ជាជាងកម្មសិទ្ធិទាំងស្រុងលើដីធ្លីនោះ។[៦]

ក្នុងឆ្នាំ១៩៩១ ជម្លោះប្រដាប់អាវុធអស់ជាងមួយទសវត្សរ៍ត្រូវបានបញ្ចប់ ដោយមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានផ្តល់ជាក្របខណ្ឌលទ្ធិប្រជាធិបតេយ្យ និតិរដ្ឋ និងសិទ្ធិមនុស្សនៅកម្ពុជា។ ដោយសារតែកិច្ចព្រមព្រៀងទីក្រុងប៉ារីសនោះ អង្គការសហប្រជាជាតិ (អ.ស.ប) បានបង្កើតអាជ្ញាធរបណ្តោះអាសន្ន អ.ស.ប(អ៊ុនតាក់) ដែលមានបេសកម្មរក្សាសន្តិភាព ជួយរៀបចំប្រទេសឲ្យមានរដ្ឋធម្មនុញ្ញថ្មីមួយ ព្រមទាំងកិច្ចការបោះឆ្នោតដោយសេរីនិងយុត្តិធម៌។

---

[៤] ហ៊ែល ចំរើន, «ការណែនាំច្បាប់ភូមបាលនៃប្រទេសកម្ពុជា» នៅក្នុងរបាយការណ៍របស់ ហោ ផេង, គង់ ផល្លៈ និងជត មែនហ្វៃល, ការណែនាំច្បាប់កម្ពុជា (២០១២) ទំព័រទី៣១៦ http://bit.ly/18AYchV

[៥] សឹក បូរ៉ក្ស, «ភាពជាម្ចាស់កម្មសិទ្ធិ, លក់ និងការក្តោបក្តាប់ដីធ្លីនៅកម្ពុជា៖ ការពិនិត្យបឋមលើទិន្នន័យដែលមានស្រាប់ និងទិន្នន័យដែលប្រមូលបានពីការស្ទង់មតិថ្មីៗចំនួន៤» (ខែកញ្ញា ឆ្នាំ២០០០), ឯកសារសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) លេខ១៦, ទំព័រទី៣ http://bit.ly/18AWa17

[៦] ហ៊ែល ចំរើន, «ការណែនាំច្បាប់ភូមបាលនៃប្រទេសកម្ពុជា» នៅក្នុងរបាយការណ៍របស់ ហោ ផេង, គង់ ផល្លៈ និងជត មែនហ្វៃល, ការណែនាំច្បាប់កម្ពុជា (២០១២) ទំព័រទី៣១៦ http://bit.ly/18AYchV

*រូបភាព ១៖ តារាងកាលនៃភាពជាម្ចាស់កម្មសិទ្ធិដីធ្លីនៅកម្ពុជា*

- មុនឆ្នាំ ១៨៦៣៖ ប្រព័ន្ធសក្តិភូមិនិយម - ប្រព័ន្ធម្ចាស់កម្មសិទ្ធិអាស្រ័យផល
- ឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣៖ ក្រោមការដាក់អាណាព្យាបាលរបស់បារាំង - សិទ្ធិលើទ្រព្យសម្បត្តិតាមបែបបារាំងត្រូវបានគេដាក់ឲ្យអនុវត្ត
- ឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧៥៖ ការបន្តប្រព័ន្ធតាមបែបបារាំង
- ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩៖ កម្ពុជាប្រជាធិបតេយ្យ - លុបបំបាត់ចោលនូវសិទ្ធិលើទ្រព្យសម្បត្តិ
- ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩៖ សាធារណរដ្ឋប្រជាមានិតកម្ពុជា - រដ្ឋជាម្ចាស់លើដីធ្លី និងធនធានធម្មជាតិ
- ឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣៖ រដ្ឋកម្ពុជា - ការត្រឡប់ចូលមកវិញនូវប្រព័ន្ធមូលធននិយម និងសេដ្ឋកិច្ចសេរី
- ឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន៖ ព្រះរាជាណាចក្រកម្ពុជា - ការកើនឡើងនូវវិសមភាព

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋកម្ពុជាត្រូវបានប្រែឈ្មោះទៅជាព្រះរាជាណាចក្រកម្ពុជា ដោយមានទាំងរដ្ឋធម្មនុញ្ញថ្មីមួយ ពោលគឺ«រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា» ត្រូវបានអនុម័ត ក្នុងគោលដៅកំណត់ឲ្យបានជាក់លាក់លើការទទួលស្គាល់កម្មសិទ្ធិដីធ្លីឯកជន។ ទោះជាយ៉ាងនេះក្តី រហូតដល់ឆ្លងសហវត្សរ៍ហើយក៏ដោយ ស្ថានភាពសិទ្ធិដីធ្លីនៅកម្ពុជានៅតែមិនមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីនៅឡើយ។ ជាជាងការផ្តល់ឲ្យពលរដ្ឋនូវមូលដ្ឋានសុវត្ថិភាពលើផ្ទះសម្បែងនិងដីធ្លីដែលអំណោយផល តាមរយៈក្របខណ្ឌច្បាប់ដែលអាចធានាការពារបាននោះ ឯកជនភាវូបនីយកម្មបានបង្កឲ្យមានការកើនឡើងនូវវិសមភាពនៅកម្ពុជា។[៧]

## ១.២. ទិដ្ឋភាពរួមនៃស្ថានភាពដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ន

កម្ពុជាជាប្រទេសដែលទីផ្សារទើបតែលេចធ្លោឡើង ហើយដែលគ្រប់គ្រងដោយរដ្ឋាភិបាលដែលព្យាយាមបង្កើននូវការនាំចេញ និងទាញយកផលពីធនធានធម្មជាតិ ក្នុងគោលបំណងអភិវឌ្ឍន៍ជាតិ។ ជាងមួយ

[៧] ក្របខណ្ឌច្បាប់បច្ចុប្បន្ន និងចន្លោះប្រហោងក្នុងការអនុវត្តន៍ច្បាប់ទាំងនេះនឹងត្រូវបានលើកមកពិភាក្សាក្នុងជំពូកទី២ នៃរបាយការណ៍នេះ។

ទសវត្សរ៍កន្លងមកនេះ តម្រូវការដីធ្លីជាសកល រួមផ្សំនឹងការពង្រីកសេដ្ឋកិច្ចយ៉ាងឆាប់រហ័សផងនោះ បានជះឥទ្ធិពលដ៏មហន្តរាយដល់សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីរបស់ពលរដ្ឋក្រីក្រជាច្រើននៅក្នុងប្រទេសនេះ។

តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច អ្នកទទួលប្រយោជន៍ត្រូវបានផ្តល់នូវសិទ្ធិលើការប្រើប្រាស់ដីរបស់រដ្ឋក្នុងកំណត់ ៩៩ ឆ្នាំ សម្រាប់អាជីវកម្មកសិឧស្សាហកម្ម។[8] រដ្ឋាភិបាល បានប្រកាសតាំងពីមុនមកថា សម្បទានដីសេដ្ឋកិច្ចគឺមានសារៈសំខាន់ដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេស និងនាំមកនូវផលចំណេញខាងសង្គម និងសេដ្ឋកិច្ចជាច្រើនថែមទៀតផង។[9] ប៉ុន្តែ ដូចដែលអ្នករាយការណ៍ពិសេសអ.ស.បបានកត់សម្គាល់នោះ គឺថា «មិនមានរបាយការណ៍ដែលសំអាងដោយភស្តុតាងជាក់លាក់ត្រូវបានបោះពុម្ពផ្សាយជាផ្លូវការស្តីពីផលចំណេញពីសម្បទានដីនោះទេ»។[10]

ថ្វីបើមានកិច្ចគាំពារផ្នែកច្បាប់ជាច្រើនយ៉ាងណាក៏ដោយ[11] ជម្លោះដីធ្លីបានកើនឡើងយ៉ាងខ្លាំង ជាងមួយទសវត្សរ៍កន្លងមកនេះ។ ចំនួនសម្បទានដីសេដ្ឋកិច្ច ដែលខ្លះជាដីដែលមានជម្លោះ ឬដែលមានអ្នករស់រាននៅលើដីនោះ ដោយរាប់ទាំងតំបន់ដែលត្រូវអភិរក្ស និងព្រៃឈើផងដែរនោះ បានបន្តកើនឡើងជាលំដាប់។[12] ដីជាង ៣ លានហិចតា ប្រហាក់ប្រហែលនឹង ១៦,៦% នៃផ្ទៃដីសរុបចំនួន ១៨១.០៣៥ គីឡូម៉ែត្រការ៉េ នៅកម្ពុជា ត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនបរទេស និងក្នុងស្រុក ព្រមទាំងអ្នកនយោបាយដែលមានអំណាច ក្នុងគោលបំណងអភិវឌ្ឍឧស្សាហកម្ម។[13] ជាលទ្ធផល សហគមន៍ដែលរស់នៅលើដីទាំងនោះ តែងត្រូវបានគេបណ្តេញចេញដោយបង្ខំ ទៅតាំងទីលំនៅថ្មី ឬត្រូវបានផ្លាស់ប្តូរទីលំនៅទាំងមិនបានស្ម័គ្រចិត្ត ដែលជាញឹកញយមិនបានរៀបចំផែនការត្រឹមត្រូវ និងត្រូវបានអនុវត្តដោយមិនបានអនុលោមតាមវិធានច្បាប់និងសិទ្ធិមនុស្សឲ្យបានត្រឹមត្រូវនោះទេ។ ចាប់តាំងពីឆ្នាំ២០០០មក ពលរដ្ឋជាង ៧០០.០០០ នាក់ត្រូវបានគេគណនាថាបានរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចនៅទូទាំងប្រទេស។[14]

សិទ្ធិដីធ្លី និងទ្រព្យសម្បត្តិ ប្រហែលជាសិទ្ធិមនុស្សដ៏សំខាន់បំផុតមួយ ដែលគាំពារដល់សុខុមាលភាពសេដ្ឋកិច្ចរបស់សហគមន៍តាមជនបទ ដែលដីធ្លីរបស់ពួកគាត់ជាប្រភពដ៏សំខាន់ក្នុងការស្វែងរកចំណូល។ នៅកម្ពុជា កសិកម្មគឺគ្របដណ្តប់ដល់ទៅ ៣៦% នៃផលិតផលក្នុងស្រុកសរុប និងបានផ្តល់ការងារដល់ពលករដល់

---

[8] ច្បាប់ភូមិបាល, នស/រកម/០៨០១/១៤ (ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១) មាត្រា ៦១ http://bit.ly/1dGTrbO

[9] សន្ទរកថារបស់សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី"យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី២ នៅអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៤ នៃរដ្ឋសភា (ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨) http://bit.ly/HpfSqY

[10] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគបែបសិទ្ធិមនុស្សចំពោះសម្បទានដីសេដ្ឋកិច្ច និងដទៃទៀតនៅកម្ពុជា» A/HRC/21/63/Add.1/Rev.1, (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[11] សម្រាប់ការរៀបរាប់លម្អិត និងការវិភាគលើច្បាប់ និងសេចក្តីណែនាំពាក់ព័ន្ធនឹងដីធ្លី សូមយោងទៅជំពូកទី២ នៃរបាយការណ៍នេះ។

[12] អង្គការលីកាដូ/ការវិភាគរបស់កាសែតឌឹខេមបូឌាដេលី, «ការរូងយកកម្ពុជា៖ សម្បទានម្តងមួយៗ» (ថ្ងៃទី១១ និង១២ ខែមិនា ឆ្នាំ២០១២) http://bit.ly/Hpgih2

[13] ម.ស.ម.ក, «របាយការណ៍គោលនយោបាយកំណែទម្រង់ដីធ្លី៖ របកគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ» (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1inGTWX

[14] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីបើកឱកាសឲ្យមានការបំពាន» (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/17FLZsD

ទៅ ៥៥,៨%។[15] ប៉ុន្តែ ថ្វីបើច្បាប់ជាតិនិងអន្តរជាតិការពារដល់សិទ្ធិក្នុងការមានកម្មសិទ្ធិលើទ្រព្យសម្បត្តិ និងការដែលអាចមានទីលំនៅសមរម្យយ៉ាងណាក្តី ការបំពានលើសិទ្ធិដីធ្លីគឺជាបញ្ហារំលោភសិទ្ធិមនុស្សមួយដែលលេចធ្លោបំផុតនៅកម្ពុជា។

គោលនយោបាយដីធ្លីដែលមិនច្បាស់លាស់ រួមផ្សំនឹងការអនុវត្តន៍ច្បាប់ដ៏ធូររលុង ដោយសារតែអំពើពុករលួយ បក្សពួកនិយម និងកង្វះឆន្ទៈនយោបាយពិតប្រាកដ បានធ្វើឲ្យជម្លោះរវាងពលរដ្ឋកម្ពុជានិងសម្បទានិកបានកើនឡើងយ៉ាងខ្លាំងក្លា។ កង្វះនៃកិច្ចការពារតាមនីតិវិធី និងវិធានច្បាប់ នៅពេលអនុវត្តគម្រោងមួយចំនួន បានបង្កឲ្យមានមជ្ឈដ្ឋានអភិវឌ្ឍន៍មួយដែលមិនមានសណ្តានច្បាប់ត្រឹមត្រូវ ដែលពោរពេញដោយកង្វះតម្លាភាព ការពិគ្រោះយោបល់ និងផែនការ។[16] បញ្ហានេះត្រូវបានបង្កើនទម្ងន់ដោយសារតែប្រព័ន្ធយុត្តិធម៌ដែលមានលក្ខណៈលម្អៀងខាងនយោបាយ[17] ហើយបានខកខានក្នុងការផ្តល់នូវដំណោះស្រាយប្រកបដោយយុត្តិធម៌ និងទាន់សភាពការណ៍ចំពោះករណីជម្លោះដីធ្លីជាច្រើន។

ឧទាហរណ៍ជាច្រើនរាប់មិនអស់ពាក់ព័ន្ធនឹងការបណ្តេញចេញពីដីធ្លីនៅពេញផ្ទៃប្រទេស បង្ហាញនូវសភាពធ្ងន់ធ្ងរនៃស្ថានការណ៍នេះ។ ក្នុងឆ្នាំ២០១៣ ការិយាល័យឧត្តមស្នងការអ.ស.ប បានជួយអន្តរាគមន៍ទៅលើករណីដីកំពុងមានទំនាស់ និងមិនទាន់ត្រូវបានដោះស្រាយ រវាងភាគីសហគមន៍ដែលប៉ះពាល់ អាជ្ញាធរ និងក្រុមហ៊ុន ទាំងក្នុងតំបន់ជនបទ និងទីក្រុងជាសរុបចំនួន ៧៤ ករណី[18] ហើយក្នុងឆ្នាំ២០១២ សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(អាដហុក) បានដោះស្រាយបញ្ហាដីចំនួន ៧០ ករណី ហើយបានតាមដានបន្តលើករណីចំនួន ៦២ ដែលមិនទាន់បានដោះស្រាយបន្សល់ពីឆ្នាំកន្លងទៅ។[19] ការបណ្តេញចេញដោយបង្ខំក៏បានក្លាយជាព្រឹត្តិការណ៍ហឹង្សាផងដែរនាប៉ុន្មានឆ្នាំមកនេះ ដោយមានទាំងការប្រើប្រាស់រថយន្តឈូសឆ្កលរលំផ្ទះ ឬក៏ដុតកំទេចផងដែរ។

សហគមន៍ដែលត្រូវបានគេបណ្តេញចេញ មិនត្រឹមតែបាត់បង់ផ្ទះសម្បែងរបស់ពួកគាត់ប៉ុណ្ណោះទេ។ ការបណ្តេញចេញ មិនថាដោយបង្ខំ ឬមិនបង្ខំនោះទេ «បានបំពានលើសិទ្ធិមនុស្សជាច្រើនដែលបានទទួលស្គាល់ជាអន្តរជាតិ រួមទាំងសិទ្ធិមានផ្ទះសម្បែង អាហារ ទឹក សុខភាព ការអប់រំ ការងារ សន្តិសុខបុគ្គល សន្តិសុខលំនៅដ្ឋាន សេរីភាពចាកផុតពីការប្រព្រឹត្តយោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងសេរីភាពខាងការដើរហើរ។»[20] ការបណ្តេញចេញដោយបង្ខំបានបង្កើននូវវិសមភាពខាងសង្គមសេដ្ឋកិច្ច ជម្លោះសង្គម និងការបែង

---

[15] ភ្នាក់ងារស៊ើបអង្កេតកណ្តាលរបស់សហរដ្ឋអាមេរិក, «កណត់ហេតុទូទៅរបស់ពិភពលោក» ស្តីពីសេដ្ឋកិច្ចកម្ពុជា http://1.usa.gov/HpceNG

[16] ការិយាល័យឧត្តមស្នងការអ.ស.ប, «តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអ.ស.បក្នុងការជួយដល់រដ្ឋាភិបាល និងពលរដ្ឋកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស» (ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១) http://bit.ly/1iteXBc

[17] ម.ស.ម.ក, «កំណែទម្រង់ប្រព័ន្ធយុត្តិធម៌» (របាយការណ៍សង្ខេប) (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1bo6GdM

[18] ការិយាល័យឧត្តមស្នងការអ.ស.ប, «តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអ.ស.បក្នុងការជួយដល់រដ្ឋាភិបាល និងពលរដ្ឋកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស» (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣) http://bit.ly/1itfzXq

[19] អង្គការអាដហុក, «ផ្លូវរបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

[20] គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំរបស់អ.ស.ប ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍, និងឧបសម្ព័ន្ធ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.ប ស្តីពីការមានផ្ទះសម្បែងសមរម្យជាធាតុផ្សំនៃសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ A/HRC/4/18, (ឆ្នាំ២០០៧) http://bit.ly/HbSJIF

ចែកក្នុងសង្គម ហើយដែលប៉ះពាល់ខ្លាំងចំពោះពលរដ្ឋក្រីក្របំផុត ដែលជាអ្នកងាយរងគ្រោះខាងសង្គមនិងសេដ្ឋកិច្ច ព្រមទាំងក្រុមដែលមានសំឡេងតិចក្នុងសង្គម ជាពិសេស ស្ត្រី កុមារ ជនជាតិភាគតិច និងជនជាតិដើមភាគតិច។[21]

ទំនាស់ដីធ្លីបានបង្កទៅជាមជ្ឈដ្ឋានសង្គមនយោបាយដែលមានភាពរឹករវ ដោយបានបញ្ចេះភាពខកចិត្តរបស់សហគមន៍ដែលរងផលប៉ះពាល់ និងបង្កលក្ខណៈឲ្យពលរដ្ឋធ្វើយុទ្ធនាការទាមទារការទទួលស្គាល់សិទ្ធិ និងការប៉ះប៉ូវនានាដែលបានប៉ះពាល់ដល់ពួកគាត់។ បាតុកម្ម និងការប្រមូលផ្តុំជាច្រើនត្រូវបានរៀបចំឡើង កាន់តែញឹកញយឡើង ទាំងតាមបណ្តាខេត្ត និងទីក្រុងភ្នំពេញ។ សកម្មភាពទាំងនោះ កាន់តែមានលក្ខណៈប្រឈមខ្លាំង ហើយតែងត្រូវបានពើបប្រទះនឹងការប្រើប្រាស់កម្លាំងដែលជ្រុលហួសពីសំណាក់អាជ្ញាធរ[22] ហើយមានការចាប់ខ្លួន និងចោទប្រកាន់សកម្មជនដីធ្លីផងដែរ។[23]

អ្វីដែលនឹងត្រូវរៀបរាប់ក្នុងជំពូកបន្ទាប់ទៀតនេះ គឺថា សិទ្ធិដីធ្លីត្រូវបានការពារក្រោមច្បាប់ជាតិ និងអន្តរជាតិ (ជំពូកទី២)។ ប៉ុន្តែ កិច្ចគាំពារនេះគឺគ្រាន់តែជាទ្រឹស្តីតែប៉ុណ្ណោះ។ ជាក់ស្តែង ការអនុវត្តន៍ច្បាប់ដ៏ធូររលុង បានបង្កឲ្យមានអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ការអភិវឌ្ឍន៍ដែលមិនត្រឹមត្រូវបានវិធានច្បាប់ និងការបណ្តេញចេញដោយបង្ខំ (ជំពូកទី៣) ដែលនេះបានបណ្តាលឲ្យកើតជាជម្លោះប៉ះពាល់ដល់ជនរងគ្រោះយ៉ាងច្រើន (ជំពូកទី៤)។

## ១.៣. គោលបំណង ទំហំវិសាលភាព និងវិធីសាស្ត្រ

ដោយយល់នូវតម្រូវការជាបន្ទាន់និងជាមូលដ្ឋាន សម្រាប់កំណែទម្រង់ដីធ្លីនៅកម្ពុជា ម.ស.ម.កបានចងក្រងរបាយការណ៍នេះឡើងដើម្បីផ្តល់ទិដ្ឋភាពរួមពីស្ថានភាពសិទ្ធិដីធ្លី ដែលបានវិវត្តពីឆ្នាំ២០១២ រហូតដល់ពាក់កណ្តាលឆ្នាំ២០១៣។ របាយការណ៍នេះ ផ្តល់នូវព័ត៌មានអំពីក្របខណ្ឌច្បាប់ ស្ថាប័ន និងគោលការណ៍ពាក់ព័ន្ធនឹងដីធ្លី និងទិដ្ឋភាពរួមនៃឫសគល់នៃផលប៉ះពាល់បណ្តាលពីជម្លោះដីធ្លី។ របាយការណ៍ក៏បានតាក់តែងជាអនុសាសន៍ជាក់លាក់ ដើម្បីឲ្យស្ថានភាពដីធ្លីនៅកម្ពុជាបានប្រសើរឡើង ហើយរបាយការណ៍នេះនឹងក្លាយជាឧបករណ៍តស៊ូមតិសម្រាប់ធ្វើការជាមួយពលរដ្ឋកម្ពុជា អង្គការជាតិ និងអន្តរជាតិ ម្ចាស់ជំនួយ ស្ថានទូត និងជាពិសេសគឺរដ្ឋាភិបាលថ្មី។

របាយការណ៍នេះកំណត់នូវរបត់នៃការបំពានសិទ្ធិមានផ្ទះសម្បែងត្រឹមត្រូវ និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ព្រមទាំងផ្តល់ជាដំណោះស្រាយក្នុងការលុបបំបាត់នូវការបំពានទាំងនេះ។ គួរកត់សម្គាល់ផងដែរថារបាយការណ៍នេះមិនអះអាងទាំងស្រុងនូវរាល់ការបំពាននោះឡើយ តែផ្ទុយទៅវិញ របាយការណ៍នេះផ្តល់ជាឧទាហរណ៍ដែលអាចបង្ហាញពីបរិបទទូទៅមួយជុំវិញការរំលោភបំពានសិទ្ធិពលរដ្ឋនៅកម្ពុជា និងហេតុផលពីក្រោយនៃការបំពានទាំងនេះ។

---

[21] ដូចខាងលើ។

[22] ការិយាល័យឧត្តមស្នងការអ.ស.ប, «តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអ.ស.បក្នុងការជួយដល់រដ្ឋាភិបាល និងពលរដ្ឋកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស» (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣) http://bit.ly/1itfzXq

[23] ម.ស.ម.ក និងអង្គការមាត្រា១៩, «ការពារអ្នកការពារសិទ្ធិមនុស្ស៖ សុវត្ថិភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (ឆ្នាំ២០១៣) ទំព័រទី២៩ http://bit.ly/HrQfWL

ដើម្បីចងក្រងរបាយការណ៍នេះបាន ម.ស.ម.ក បានរៀបចំកិច្ចពិភាក្សាជាក្រុមជាមួយភាគីពាក់ព័ន្ធនៅកម្ពុជា។ ម.ស.ម.ក ក៏បានប្រមូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការបំពានលើសិទ្ធិដីធ្លី តាមរយៈកិច្ចពិភាក្សាតុមូលចំនួន ៦ និងវេទិកាគោលនយោបាយចំនួន ២ ដែលបានរៀបចំនៅតាមបណ្តាខេត្ត ក្នុងខែកញ្ញា ឆ្នាំ២០១២ និងខែមិថុនា ឆ្នាំ២០១៣ ដោយបានការចូលរួមពីក្រុមពាក់ព័ន្ធ តំណាងសហគមន៍ និងតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងគណបក្សនយោបាយផងដែរ។ ម.ស.ម.ក ក៏បានចុះបេសកកម្មស្រាវជ្រាវដល់កន្លែង នៅខែវិច្ឆិកា ឆ្នាំ២០១២ និងខែឧសភា ព្រមទាំងខែតុលា ឆ្នាំ២០១៣ នៅតាមបណ្តាខេត្តចំនួន ១៥ ផងដែរ។ ម.ស.ម.ក ក៏បានតាមដានស្ថានការណ៍សិទ្ធិដីធ្លី តាមរយៈការចងក្រងករណីដែលត្រូវបានព័ត៌មានធ្វើការរាយការណ៍ និងករណីដែលពលរដ្ឋបានរាយការណ៍ដោយផ្ទាល់មកកាន់ម.ស.ម.ក។ បន្ថែមលើសនេះទៀត ម.ស.ម.ក ក៏បានធ្វើការស្រាវជ្រាវយ៉ាងលំអិតតាមប្រភពជាច្រើន រាប់បញ្ចូលទាំងអង្គការជាតិ និងអន្តរជាតិ អ្នកសិក្សាស្រាវជ្រាវ ស្ថាប័នអន្តរជាតិ និងព័ត៌មានជាតិនិងអន្តរជាតិផងដែរ។

# ២. ទ្រឹស្តីៈ ក្របខណ្ឌការពារដោយច្បាប់

ពលរដ្ឋកម្ពុជាជាច្រើន ពឹងអាស្រ័យលើដីធ្លី ដែលជាប្រភពសំខាន់ក្នុងការស្វែងរកប្រាក់ចំណូល។ អាស្រ័យហេតុនេះហើយ ជាការចាំបាច់ដែលប្រព័ន្ធច្បាប់ការពារដល់សិទ្ធិដីធ្លី មិនគួរត្រូវបានមើលរំលងនោះឡើយ។ រដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ភូមិបាលឆ្នាំ២០០១ (ច្បាប់ភូមិបាល) និងអនុក្រឹតពាក់ព័ន្ធ ហាក់ដូចជាបានបញ្ចូលនូវបទដ្ឋានច្បាប់អន្តរជាតិសិទ្ធិដីធ្លី ហើយដែលជាទ្រឹស្តីកិច្ចការទាំងនេះគួរអាចការពារយ៉ាងស្របច្បាប់ដល់ពលរដ្ឋទាំងឡាយ។ ប៉ុន្តែ ថ្វីបើមានខែលខាងនីតិវិធីច្បាប់ការពារយ៉ាងក៏ដោយ ជាក់ស្តែងកិច្ចការពារនេះ កម្រត្រូវបានអនុវត្តណាស់។

ជំពូកនេះ ផ្តល់នូវទិដ្ឋភាពរួមពីបរិបទច្បាប់ពាក់ព័ន្ធនឹងស្ថានភាពដីធ្លីនៅកម្ពុជា ដោយពិនិត្យមើលលើ ប្បញ្ញត្តិនានានៃច្បាប់ជាតិ និងអន្តរជាតិ ហើយជំពូកទី៣នោះ យើងនឹងធ្វើការសិក្សាទៅលើការអនុវត្តន៍ជាក់ស្តែងនៃច្បាប់ទាំងអស់នេះ ព្រមទាំងការបំពានសិទ្ធិជាច្រើនដែលបានកើតមានជុំវិញបញ្ហានេះ។

## ២.១. ការធានាសិទ្ធិដីធ្លីតាមច្បាប់អន្តរជាតិ

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានបញ្ចូលរាល់កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់និងគោលនយោបាយជាតិ។[24] ដូចនេះហើយ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិអាចអនុវត្តទាំងស្រុងក្នុងតុលាការកម្ពុជា ដូចដែលបានបញ្ជាក់បន្ថែមក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីឆ្នាំ២០០៧។[25]

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(ស.ប.ស.ស) ដែលជាឯកសារគន្លឹះក្នុងប្រវត្តិសាស្ត្រសិទ្ធិមនុស្សនោះ បានចែងក្នុងមាត្រា ១៧ ថា «បុគ្គលគ្រប់រូប ទោះតែម្នាក់ឯងក្តី ឬដោយរួមជាមួយអ្នកដទៃក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ហើយគ្មានជនណាម្នាក់ ត្រូវបានដកហូតកម្មសិទ្ធិ តាមអំពើចិត្តឡើយ។[26] សិទ្ធិក្នុងការមានទំនៅឋានគ្រប់គ្រាន់ ក៏ត្រូវបានធានាក្នុងមាត្រា ២៥[27] ដែលនេះភ្ជាប់ដល់សិទ្ធិមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងការទទួលបានបានការពារពីការបណ្តេញចេញដោយបង្ខំ។

**ស.ប.ស.ស ២៥(១)**

**(សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់)**

*«មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្តាលមកពីកាលៈទេសៈផុតពីចន្ទៈរបស់ខ្លួន។*

[24] រដ្ឋធម្មនុញ្ញ មាត្រា៣១៖ « *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារ។* http://bit.ly/1hcJqYV

[25] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចចុះលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

[26] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨), មាត្រា ១៧, http://bit.ly/1808grH

[27] ដូចខាងលើ, មាត្រា២៥(កថាខណ្ឌ១)

### ២.១.១. សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់

មាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.ស.ស.វ) ដែលកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩២ ធានាដល់សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់។[28] សិទ្ធនេះក៏ត្រូវបានធានាក្នុងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ[29] និងអនុសញ្ញាស្តីពីសិទ្ធិកុមារ[30] ហើយសិទ្ធិនេះក៏មានបញ្ចូលក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ដែលអនុសញ្ញានេះហាមប្រាមដល់ការរើសអើងពូជសាសន៍ ក្នុងការទទួលបានសិទ្ធិមានលំនៅដ្ឋាន។[31]

គណៈកម្មាធិការស្តីពីសិទ្ធសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(គ.ស.ស.ស.វ) ដែលជាស្ថាប័នមួយទទួលបន្ទុកតាមដានលើការអនុវត្តន៍ក.ស.ស.ស.វ របស់រដ្ឋជាហត្ថលេខីនោះ បានគូសបញ្ជាក់បន្ថែមនូវសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ ចាំបាច់ត្រូវ ១) មានសុវត្ថិភាពស្របច្បាប់ក្នុងការកាន់កាប់, ២) មានគ្រប់គ្រាន់នូវសេវាកម្ម សម្ភារៈ គ្រឿងបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ, ៣) លទ្ធភាពចំណាយទៅបាន, ៤) អាចរស់នៅបាន, ៥) លទ្ធភាពអាចចូលប្រើប្រាស់បាន, ៦) ទីតាំង, និង៧) ភាពសមល្មមតាមបែបវប្បធម៌។[32]

### ២.១.២. សិទ្ធិទទួលបានសុវត្ថិភាពក្នុងការកាន់កាប់

ជាតុផ្សំដំបូងនៃសិទ្ធិមានលំនៅដ្ឋានគ្រប់គ្រាន់ ដូច គ.ស.ស.ស.វ បានរាយបញ្ជីនោះ គឺសុវត្ថិភាពក្នុងការកាន់កាប់។

ពាក់ព័ន្ធនឹងសុវត្ថិភាពក្នុងការកាន់កាប់នោះ គ.ស.ស.ស.វ បានចែងថាៈ

«បុគ្គលគ្រប់រូប គួរទទួលបាននូវសុវត្ថិភាពក្នុងការកាន់កាប់ ដែលជាខែលច្បាប់ការពារប្រឆាំងនឹងការបណ្តេញចេញ ការយាយី និងការគំរាមកំហែងផ្សេងៗទៀត។ រដ្ឋភាគីត្រូវតែចាត់វិធានការឲ្យបានទាន់ពេលវេលាសំដៅផ្តល់នូវសុវត្ថិភាពស្របច្បាប់ដល់បុគ្គល និងគ្រួសារទាំងឡាយដែលកំពុងតែខ្វះនូវខែលការពារនោះ ក្នុងន័យត្រូវពិគ្រោះយោបល់ជាមួយភាគី និងក្រុមពាក់ព័ន្ធ»[33]

ម្យ៉ាងវិញទៀត ជនគ្រប់រូបត្រូវឋិតក្រោមការការពារដោយច្បាប់ ដែលមិនមានជនណាម្នាក់ត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះនិងដីធ្លីរបស់ខ្លួននោះឡើយ បើមិនដូច្នេះទេពលរដ្ឋនឹងរស់នៅក្នុងភាពភ័យខ្លាចពីការបណ្តេញចេញគ្រប់ពេលវេលា។ ដូចនេះ សិទ្ធិក្នុងការកាន់កាប់ដីធ្លី ជាមធ្យោបាយមួយ ការពារគ្រួសារនិងពលរដ្ឋទាំងអស់ពីការបណ្តេញចេញដោយបង្ខំ។ ការងារនេះគឺចាំបាច់សម្រាប់បរិបទក្នុងប្រទេសកម្ពុជា ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ ដែលថា គ្រួសារជាច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លីនោះឡើយ ហើយប្រការធ្វើឲ្យខ្វះនូវខែលការពារដោយច្បាប់ចំពោះមុខការបណ្តេញចេញយ៉ាងខ្លាំង។

---

[28] ក.ស.ស.ស.វ (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦) មាត្រា ១១(១) http://bit.ly/15WUwtO

[29] អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩) មាត្រា ១៤ http://bit.ly/180arEj

[30] អនុសញ្ញាស្តីពីសិទ្ធិកុមារ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) មាត្រា ២៧ http://bit.ly/180atMv

[31] អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥ (ង)http://bit.ly/180azUe

[32] សេចក្តីពន្យល់ទូទៅស្តីពីក.ស.ស.ស.វ លេខ៤ «សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់» (មាត្រា ១១(១)) (ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ១៩៩១) http://bit.ly/15WViHa

[33] ដូចខាងលើ, ៨(ក)

### ២.១.៣. សិទ្ធិមិនត្រូវបានគេបណ្តេញចេញដោយបង្ខំ

> **សេចក្តីណែនាំទូទៅលេខ៧ របស់គ.ស.ស.ស.វ**
>
> **«ការបណ្តេញចេញ ជាការបណ្តេញជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នប្រឆាំងនឹងឆន្ទៈរបស់បុគ្គល និងគ្រួសារ និង/ឬសហគមន៍ឲ្យចេញពីផ្ទះនិង/ឬដីដែលពួកគាត់បានរស់នៅ ដែលគ្មានបញ្ញត្តិ និងលទ្ធភាព ព្រមទាំងទម្រង់ការពារដោយច្បាប់ឬទម្រង់ផ្សេងទៀត។**

ការបណ្តេញចេញដោយបង្ខំ ជាការបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត។[34] ការបំពានជាច្រើនបានកើតមានឡើង ចំពោះសិទ្ធិមានលំនៅដ្ឋានគ្រប់គ្រាន់ សិទ្ធិមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងស្តង់ដារសិទ្ធិមនុស្សដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិច្រើនទៀត។[35]

យោងតាមគ.ស.ស.ស.វ ទង្វើនៃការបណ្តេញចេញដោយបង្ខំ «គឺមិនសមស្រប»តាមក.ស.ស.ស.វនោះទេ។[36] តាមច្បាប់ ការបណ្តេញចេញ ត្រូវតែជាជម្រើសចុងក្រោយបំផុត ហើយសម្រាប់តែក្នុងករណីពិសេសបំផុត។[37] លើសនេះទៀត ក្នុងករណីដែលការបណ្តេញចេញអាចធ្វើទៅបានក្រោមហេតុផលថាចាំបាច់បំផុតនោះ រដ្ឋាភិបាលនៅតែត្រូវគោរពតាមបទដ្ឋានអន្តរជាតិ ទាំងមុនពេល ក្នុងអំឡុងពេល និងបន្ទាប់ពីការបណ្តេញចេញនោះត្រូវបានកើតឡើង។

ដូចដែលគ.ស.ស.ស.វបានគូសបញ្ជាក់នោះគឺថា មុនពេលបណ្តេញចេញអាចធ្វើទៅបាន ត្រូវមាន ១) ឱកាសពិគ្រោះយោបល់ជាមួយអ្នកដែលត្រូវបានគេបណ្តេញចេញ, ២) សេចក្តីជូនដំណឹងគ្រប់គ្រាន់ដល់អ្នកដែលត្រូវបានគេបណ្តេញចេញ, ៣) ការចែករំលែកព័ត៌មានពាក់ព័ន្ធនឹងដីធ្លីដែលនឹងត្រូវធ្វើការដោះដូរជាមួយអ្នកដែលត្រូវបានគេបណ្តេញចេញ, ៤) សំណងគ្រប់គ្រាន់។[38] ក្នុងអំឡុងពេលនៃការបណ្តេញចេញ ៥) មន្ត្រីរដ្ឋាភិបាលត្រូវមានវត្តមាននៅទីកន្លែងនៃការបណ្តេញចេញ, ៦) បុគ្គលដែលអនុវត្តការបណ្តេញចេញត្រូវតែកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់, ៧) ការបណ្តេញចេញមិនគួរត្រូវធ្វើឡើងចំពេលអាកាសធាតុមិនអំណោយផល ឬនៅពេលយប់។ បន្ទាប់ពីការបណ្តេញចេញនេះ ៨) ការប៉ះប៉ូវផ្នែកច្បាប់គួរត្រូវបានផ្តល់ជូនសហគមន៍ដែលបានប៉ះពាល់ ដោយផ្តល់ជំនួយផ្នែកមេធាវី[39] និង៩) ការបណ្តេញចេញនោះមិនត្រូវបង្កឲ្យបុគ្គលទាំងនោះគ្មានផ្ទះសម្បែងស្នាក់នៅនោះទេ។[40]

---

[34] សេចក្តីសម្រេចរបស់គណៈកម្មាការសិទ្ធិមនុស្ស ឆ្នាំ១៩៩៣/៧៧, (ថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៣), ១, http://bit.ly/1af2DiE

[35] គោលការណ៍ណែនាំរបស់អ.ស.ប ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍, និងឧបសម្ព័ន្ធ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.ប ស្តីពីការមានផ្ទះសម្បែងសមរម្យជាធាតុផ្សំនៃសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ A/HRC/4/18, (ឆ្នាំ២០០៧) http://bit.ly/HbSJIF

[36] សេចក្តីពន្យល់ទូទៅរបស់គ.ស.ស.ស.វ លេខ៧ ស្តីពី «សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់» (មាត្រា ១១(១))៖ ការបណ្តេញចេញដោយបង្ខំ, E/១៩៩៨/២២, (ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧), ៣, http://bit.ly/HbQDIV

[37] គោលការណ៍ណែនាំរបស់អ.ស.ប ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍, និងឧបសម្ព័ន្ធ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.ប ស្តីពីការមានផ្ទះសម្បែងសមរម្យជាធាតុផ្សំនៃសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ A/HRC/4/18, (ឆ្នាំ២០០៧) http://bit.ly/HbSJIF

[38] សេចក្តីពន្យល់ទូទៅរបស់គ.ស.ស.ស.វ លេខ៧៖ ១៣, ១៤, និង១៥

[39] ដូចខាងលើ, ១៥

[40] ដូចខាងលើ, ១៦

## ២.១.៤. គោលការណ៍និងសេចក្តីណែនាំអន្តរជាតិការពារសិទ្ធិដីធ្លី

បន្ថែមលើសិទ្ធិនានាដែលបានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ[41] អ្នកជំនាញឯករាជ្យរបស់អ.ស.ប ដែលគេបានស្គាល់ថាជាអ្នករាយការណ៍ពិសេសនោះ បានបង្កើតនូវកម្រងគោលការណ៍ និងសេចក្តីណែនាំជាច្រើនដែលដាក់ជាក្របខណ្ឌក្នុងការអនុវត្តន៍លើការបណ្តេញចេញ និងណែនាំដល់រដ្ឋភាគីឲ្យគោរព និងការពារសិទ្ធិមនុស្ស។

- គោលការណ៍ណែនាំរបស់អ.ស.ប ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍ឆ្នាំ២០០៧ ត្រូវបានអ្នករាយការណ៍ពិសេសអ.ស.បស្តីពីលំនៅដ្ឋានគ្រប់គ្រាន់បានតាក់តែងឡើងដើម្បីកំណត់នូវបទដ្ឋានអប្បបរមាសម្រាប់ការផ្លាស់ទីលំនៅ។[42]
- គោលការណ៍សិទ្ធិមនុស្សអប្បបរមាពាក់ព័ន្ធនឹងការទទួលបានឬផ្ទេរសិទ្ធិដីធ្លីក្នុងទ្រង់ទ្រាយធំ[43] ត្រូវបានអ្នករាយការណ៍ពិសេសអ.ស.បស្តីពីសិទ្ធិទទួលបានស្បៀងអាហារ បានតាក់តែងឡើងដើម្បីកំណត់តម្រូវការមួយចំនួយក្នុងការឆ្លើយតបនឹងការប្រឈមផ្នែកសិទ្ធិមនុស្សដោយសារតែការទទួលបានដីទ្រង់ទ្រាយធំ។
- គោលការណ៍ស្តីពីការដោះស្រាយមានប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិសម្រាប់ជនភៀសខ្លួន និងជនភៀសសឹក “Pinheiro Principles”[44] ត្រូវបានអ្នករាយការណ៍ពិសេសអ.ស.បស្តីពីការដោះស្រាយមានប្រសិទ្ធភាពចំពោះលំនៅដ្ឋាននិងទ្រព្យសម្បត្តិ បានតាក់តែងឡើង ដែលទាក់ទងនឹងបរិបទនៅកម្ពុជា នៅពេលដែលជនភៀសខ្លួនត្រលប់ចូលមកក្នុងប្រទេសវិញ។
- គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស[45] រាប់បញ្ចូលនូវ ១) កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការបំពានលើសិទ្ធិមនុស្សពីសំណាក់សាជីវកម្ម ២) ទំនួលខុសត្រូវរបស់សាជីវកម្មក្នុងការ

---

[41] ច្បាប់សិទ្ធិមនុស្សអន្តរជាតិ រាប់បញ្ចូលទាំងស.ប.ស.ម, ក.ស.ស.ស.វ, ក.ស.ព.ន ព្រមទាំងពិធីសារទាំងពីរផងដែរ http://bit.ly/1afhCcC

[42] គោលការណ៍ណែនាំរបស់អ.ស.ប ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍, និងឧបសម្ព័ន្ធ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.ប ស្តីពីការមានផ្ទះសម្បែងសមរម្យជាធាតុផ្សំនៃសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ A/HRC/4/18, ( ឆ្នាំ២០០៧ ) http://bit.ly/HbSJIF

[43] គោលការណ៍សិទ្ធិមនុស្សអប្បបរមាពាក់ព័ន្ធនឹងការទទួលបាន ឬផ្ទេរសិទ្ធិដីធ្លីក្នុងទ្រង់ទ្រាយធំ, ឧបសម្ព័ន្ធភ្ជាប់ក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.បស្តីពីសិទ្ធិទទួលបានស្បៀងអាហារ A/HRC/13/33/Add.2, ( ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩ ) http://bit.ly/HbTqlk

[44] គោលការណ៍ស្តីពីការដោះស្រាយមានប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិសម្រាប់ជនភៀសខ្លួន និងជនភៀសសឹក, អ្នករាយការណ៍ពិសេសរបស់អ.ស.បស្តីពីប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិ, E/CN.4/Sub.2/2005/17, ( ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៥) http://bit.ly/1afgYM9

[45] គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស, ឧបសម្ព័ន្ធក្នុងរបាយការណ៍របស់តំណាងពិសេសស្តីពីបញ្ហាសិទ្ធិមនុស្ស និងអន្តរសាជីវកម្ម និងសហគ្រាសដទៃទៀត A/HRC/17/31 ( ថ្ងៃទី១២ ខែមិនា ឆ្នាំ២០១១ ) http://bit.ly/HbVg5A

គោរពសិទ្ធិមនុស្ស និង៣) ការដែលអាចទទួលបានការដោះស្រាយឲ្យបានទូលំទូលាយសម្រាប់ជនរងគ្រោះនៃអំពើរំលោភបំពានទាក់ទងនឹងធុរកិច្ច ទាំងតាមប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ។[46]

សិទ្ធិអន្តរជាតិ និងការការពារសិទ្ធិដីធ្លីដូចបានរៀបរាប់ខាងលើនេះ គឺអាចអនុវត្តបានក្នុងតុលាការប្រទេសកម្ពុជា ហើយស្ទើរតែគោលការណ៍ទាំងអស់ ក៏បានបញ្ចូលក្នុងច្បាប់ជាតិផងដែរ។

## ២.២. ការធានាសិទ្ធិដីធ្លីតាមច្បាប់ជាតិ

ក្របខណ្ឌច្បាប់ដែលផ្តោតលើដីធ្លី និងទ្រព្យសម្បត្តិនៅកម្ពុជា គឺមានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងលិខិតូបករណ៍ជាច្រើន ពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ទាំងនេះ។

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញធានាដល់សិទ្ធិពលរដ្ឋគ្រប់រូបជាម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិ ទោះជាបុគ្គលក្តី ឬជាសមូហភាពក្តី ហើយក៏បានផ្តល់ការការពារប្រឆាំងនឹងការដកហូតកម្មសិទ្ធិតាមអំពើចិត្ត ដោយតម្រូវថា លុះត្រាតែជាប្រយោជន៍សាធារណៈត្រូវឲ្យធ្វើ ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ទើបអាចដកហូតសិទ្ធិ នោះបាន។

**មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ**

*ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។*

*កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបានលុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។*

ការធានាសិទ្ធិដីធ្លី និងទ្រព្យសម្បត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានចងក្រងបន្ថែមក្នុងច្បាប់ភូមិបាល។[47] គោលបំណងនៃការអនុម័តចេញនូវច្បាប់ភូមិបាលនេះ គឺមានពីរយ៉ាង៖ ១)ដើម្បីផ្តល់សុវត្ថិភាពក្នុងការកាន់កាប់ដល់ពលរដ្ឋកម្ពុជា និង២) ដើម្បីសម្របសម្រួលដល់ការចូលរួមរបស់ប្រទេសកម្ពុជាទៅក្នុងសេដ្ឋកិច្ចសកល តាមរយៈការប្រើប្រាស់ប្រព័ន្ធសម្បទានដី។

ច្បាប់ភូមិបាលជាការវិវត្តន៍ផ្នែកច្បាប់សំខាន់បំផុតដែលផ្តល់ការការពារដល់សិទ្ធិដីធ្លីនៅកម្ពុជា។ ច្បាប់នេះបានកំណត់ដីជាបីប្រភេទ និងឆ្លើយតបទៅតាមរបបកម្មសិទ្ធរបស់ប្រភេទដីនោះ៖ ដីរដ្ឋ ដីឯកជន និងដីសមូហភាព។ និយាយរួម រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងអស់ក្នុងដែនដីកម្ពុជា ហើយដែលមិនទាន់ជាកម្ម-សិទ្ធិឯកជនត្រឹមត្រូវ ឬចាត់ជាដីសមូហភាពនៅឡើយ។[48] ដីរដ្ឋត្រូវបានចែកជាពីរប្រភេទថែមទៀត គឺទ្រព្យ-សម្បត្តិសាធារណៈរបស់រដ្ឋ (ដីដែលសាធារណជនអាចប្រើប្រាស់ ឬសម្រាប់ផលប្រយោជន៍សាធារណៈ) និង

---

[46] របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការដ្ឋានស្តីពីបញ្ហាសិទ្ធិមនុស្ស និងអន្តរសាជីវកម្ម និងសហគ្រាសដទៃទៀត, « ការពារ, គោរព, និងដោះស្រាយ» ដែលជាក្របខណ្ឌមួយសម្រាប់ធុរកិច្ចនិងសិទ្ធិមនុស្ស A/HRC/8/5 (ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨) http://bit.ly/HbWayZ

[47] មាត្រា ១ នៃច្បាប់ភូមិបាល

[48] ដូចខាងលើ មាត្រា ១២

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ (ដីទាំងឡាយដែលរដ្ឋកាន់កាប់) ហើយដីសមូហភាព ក៏ត្រូវបែងចែងជាអចលនវត្ថុរបស់វត្ត និងអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច (សូមមើលក្នុងតួលេខខាងក្រោម)។

រូបភាព ២៖ ការបែងចែកប្រភេទដីធ្លី[៤៩]




ជាការចាំបាច់ណាស់ដែលយើងត្រូវយល់ពីការបែងចែកដីជាប្រភេទផ្សេងៗ ដើម្បីកំណត់ថាអ្នកណាមានកម្មសិទ្ធិលើដីនោះ ហើយដីនោះត្រូវបានគេប្រើប្រាស់សម្រាប់គោលបំណងអ្វី។

### *២.២.១. ទ្រព្យសម្បត្តិឯកជន*

**មាត្រា ៥ នៃច្បាប់ភូមិបាល**

**គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សា-ធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។**

សិទ្ធិទៅលើទ្រព្យសម្បត្តិឯកជន មាន ២ របប បើយោងតាមច្បាប់ភូមិបាល៖ សិទ្ធិជាកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។ ដរាបណាម្ចាស់កម្មសិទ្ធិឯកជន និងភោគី (អ្នកកាន់កាប់)មិនប្រព្រឹត្តផ្ទុយនឹងច្បាប់ទេនោះ ពួកគាត់ មានសិទ្ធិចូលទៅរស់នៅ ប្រើប្រាស់ ផ្ទេរកម្មសិទ្ធិ ឬមិនឲ្យជនណាម្នាក់ចូលមកនៅលើដីរបស់ខ្លួន។[50]

បុគ្គលណាម្នាក់អាចមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ដរាបណាដីនោះបានចុះបញ្ជី ហើយម្ចាស់កម្មសិទ្ធិមានប័ណ្ណកម្ម-សិទ្ធិដីធ្លីត្រឹមត្រូវចេញដោយគណៈកម្មការសុរិយោដី។[51] បុគ្គលណាម្នាក់មានសិទ្ធិកាន់កាប់ដីធ្លី ថ្វីបើខ្លួនមិនមានប័ណ្ណកម្មសិទ្ធិ

---

[49] ស្ពានទៅកាន់សន្តិភាពកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាននិងការបណ្តេញចេញ, គម្រោងគណនេយ្យភាពអន្តរជាតិ៖ «សៀវភៅណែនាំស្តីពីពីសិទ្ធិដីធ្លី និងលំនៅដ្ឋាននៅកម្ពុជា» លេខ១, ផ្នែកទី២ (ខែតុលា ឆ្នាំ២០០៩) http://bit.ly/Hrafs4

[50] ច្បាប់ភូមិបាល, មាត្រា ៨៥

[51] ដូចខាងលើ, សន្ទានុក្រម (កម្មសិទ្ធិ)

ក៏ដោយ ប្រសិនណាការកាន់កាប់នោះស្របច្បាប់។[52] ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបំពេញលក្ខខណ្ឌដូចជា៖ ការកាន់កាប់នោះត្រូវធ្វើឡើងមុនខែកក្កដា ឆ្នាំ២០០១ ហើយត្រូវតែគ្មានហឹង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាននិងដោយសុចរិត។[53] ភោគៈដែលកាន់កាប់ដោយស្របច្បាប់ អាចនឹងត្រូវបានទទួលការការពារយ៉ាងត្រឹមត្រូវ និងអាចទទួលបានសិទ្ធិកម្មសិទ្ធិ និងប័ណ្ណកម្មសិទ្ធិដែលចេញដោយគណៈកម្មការសុរិយោដី។

ដីដែលជាកម្មសិទ្ធិឯកជន ត្រូវបានការពារពីការបណ្តេញចេញ។ ទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាល[54] ចែងថា គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ ហើយបន្ទាប់ពីបានផ្តល់សំណងជាមុន ដោយសមរម្យនិងយុត្តិធម៌។ ច្បាប់ភូមិបាលក៏បានចែងផងដែរថា ការបណ្តេញចេញចំពោះអ្នកដែលគ្មានប័ណ្ណកាន់កាប់អចលនវត្ថុអាចធ្វើបាន តែតាមការបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចប៉ុណ្ណោះ។[55] ការបណ្តេញចេញដែលបានបង្គាប់ដោយតុលាការអាចត្រូវបានព្យួរការអនុវត្តន៍ជាបណ្តោះអាសន្ន បើវិធានការបណ្តេញចេញនោះ «អាចបណ្តាលឲ្យមានភាពរឹករឹប ឬមានផលវិបាកធ្ងន់ធ្ងរដល់សង្គម។»[56] ច្បាប់ភូមិបាលមិនបានកំណត់ក្របខណ្ឌច្បាប់លម្អិតអំពីលក្ខខណ្ឌដែលការបណ្តេញចេញគួរអនុវត្តនោះទេ ដូចនេះហើយនៅឆ្នាំ២០១០ ច្បាប់អស្សាមិករណ៍ត្រូវបានអនុម័ត។[57] ទោះជាយ៉ាងនេះក្តី ការបណ្តេញចេញនោះ គឺអនុវត្តសម្រាប់ផលប្រយោជន៍សាធារណៈ (ដូចជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ) ប៉ុណ្ណោះ។[58] ច្បាប់នោះក៏បានកំណត់នូវលក្ខខណ្ឌតម្រូវសម្រាប់អស្សាមិករណ៍ដើម្បីផលប្រយោជន៍សាធារណៈដែលអាចទទួលយកបានផងដែរ[59] ហើយនីតិវិធីទៀតសោតត្រូវតែជានាំឲ្យមានដំណើរការត្រឹមត្រូវនិងយុត្តិធម៌។[60] ប៉ុន្តែ ច្បាប់ស្តីពីការបណ្តេញចេញស្រដៀងគ្នានេះ មិនទាន់ត្រូវបានបង្កើតនៅឡើយ ចំពោះសម្បទានដី ដែលនេះបង្កឲ្យមានការខ្វះខាតដល់ការការពារដល់ពលរដ្ឋក្នុងការទទួលសំណងគ្រប់គ្រាន់ និងទាន់វេលា។

**និយមន័យនៃសហគមន៍ជនជាតិដើមភាគតិចក្នុងមាត្រា ២៣ នៃច្បាប់ភូមិបាល៖**

*«សហគមន៍ជនជាតិដើមភាគតិចគឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។*

### ២.២.២. *ទ្រព្យសម្បត្តិសមូហភាព*

ដោយសារតែមានវប្បធម៌ អត្តសញ្ញាណ និងជីវភាពរស់នៅមួយបែបដោយឡែក ពលរដ្ឋជនជាតិដើមភាគតិចនៅទូទាំងពិភពលោកបានប្រឈមនឹងការរើសអើង និងជាញឹ-

---

[52] ដូចខាងលើ, មាត្រា ៣០
[53] ដូចខាងលើ, មាត្រា ៣៨
[54] មាត្រា ៥ នៃច្បាប់ភូមិបាល
[55] មាត្រា ៣៥ នៃច្បាប់ភូមិបាល
[56] ដូចខាងលើ មាត្រា ៣៦
[57] ច្បាប់អស្សាមិករណ៍ (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០) http://bit.ly/1dKukoq
[58] ដូចខាងលើ មាត្រា ៣
[59] ដូចខាងលើ មាត្រា ៧ ដល់ មាត្រា ១១
[60] ដូចខាងលើ មាត្រា ១៥ ដល់ មាត្រា ២៩

ញាប់ទទួលរងនូវផលវិបាកពីការដែលគេបំពានបូរណភាពទឹកដី។ ត្រឹមឆ្នាំ២០០៩ ជនជាតិដើមភាគតិចផ្សេងៗចំនួន ២៣ ត្រូវបានគេប៉ាន់ស្មានថា បានរស់នៅក្នុងប្រទេសកម្ពុជា ពោលគឺប្រមាណ ១% និង ១.៩% នៃប្រជាពលរដ្ឋសរុប។[61] ពួកគាត់ជាជនជាតិភាគតិចដែលងាយរងគ្រោះបំផុត ដោយសារពួកគាត់រស់នៅឆ្ងាយពីយន្តការរបស់រដ្ឋ ដែលមិនអាចទទួលបាននូវសុវត្ថិភាពសង្គមនិងការអប់រំផ្តល់ដោយរដ្ឋ។ អាស្រ័យហេតុនេះហើយ សហគមន៍ជនជាតិដើមភាគតិចត្រូវការជាចាំបាច់នូវការការពារជាក់លាក់មួយ។[62]

កម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីប្រកាសរបស់អ.ស.បស្តីពីសិទ្ធិជនជាតិដើមភាគតិច (ស.ស.ជ)[63] ដែលបានផ្តល់ជាមូលដ្ឋានដល់ក្របខណ្ឌច្បាប់របស់រដ្ឋាភិបាលក្នុងការទទួលស្គាល់ និងចុះបញ្ជីដល់ពលរដ្ឋជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេជាម្ចាស់កម្មសិទ្ធិ អាចប្រើប្រាស់ និងអភិវឌ្ឍដីសមូហភាពបែបប្រពៃណីរបស់ពួកគេ និងមានប្រព័ន្ធសុវត្ថិភាពដីធ្លីបែបប្រពៃណីដែលត្រូវបានគេទទួលស្គាល់ផងដែរ។ ច្បាប់ភូមិបាល និងអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច (អនុក្រឹត្យលេខ ៨៣)[64] ដែលបានកំណត់នូវនីតិវិធីក្នុងការចេញប័ណ្ណកម្មសិទ្ធិ និងការចុះបញ្ជីដីធ្លីដល់ជនជាតិដើមភាគតិច គឺជាលិខិតូបករណ៍ពីរដ៏សំខាន់ ក្នុងការការពារដល់សិទ្ធិដីធ្លីរបស់ពលរដ្ឋជនជាតិដើមភាគតិចនៅកម្ពុជា។

អ្វីដែលជាចំណុចជឿនលឿនក្នុងច្បាប់ភូមិបាល និងអនុក្រឹត្យលេខ៨៣នោះ គឺការទទួលស្គាល់សិទ្ធិជាម្ចាស់កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។[65] ទោះជាយ៉ាងនេះក្តី សហគមន៍ត្រូវតែចុះបញ្ជីជាមួយក្រសួងមហាផ្ទៃដើម្បីក្លាយរូបវន្តស្របច្បាប់ មុនដែលអាចចុះបញ្ជីទទួលនូវប័ណ្ណកម្មសិទ្ធិដីសមូហ-ភាពបាន។[66]

អនុក្រឹត្យលេខ៨៣ ក៏បានផ្តល់និយមន័យបន្ថែមដល់ដីសហគមន៍ជនជាតិដើមភាគតិច ហើយចែងថាដីនេះមាន ៥ ប្រភេទ៖ ១) ដីលំនៅដ្ឋាន ២)ដីដាំដំណាំ ៣) ដីសម្រាប់កសិកម្មវិលជុំ ៤) ដីព្រៃអារក្ស និង៥) ដីសម្រាប់កប់សព[67]។ ប្រភេទដីពីរដំបូងគេនោះ (ដីលំនៅដ្ឋាន និងដីដាំដុះ) ចាំបាច់ត្រូវតែជាដីដែលបានចុះបញ្ជីជាមួយរដ្ឋជាដីឯកជនរបស់រដ្ឋ។[68] រីឯប្រភេទដីចំនួន ៣ ដទៃទៀតនោះរាប់បញ្ចូលជាដីដែលបានចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ។ ដោយសារលក្ខខណ្ឌតម្រូវនិងការសន្មតថាដីដែលសហគមន៍ជនជាតិដើមភាគតិចបាន

---

[61] ស្តេបហ្វេន អេរិនត្រូដ, «វិសហមជ្ឈការ និងក្តីសង្ឃឹមនៃការពង្រឹងអំណាចពលរដ្ឋជនជាតិដើមភាគតិច៖ ករណីធនាគារពិភពលោកនៅកម្ពុជា ឆ្នាំ២០០៩,» កាសែតប៉ាស៊ីហ្វិក, វ៉ុល ២៤, លេខ ១ (ខែមិនា ឆ្នាំ២០១១) ទំព័រ៩០។

[62] ហ្វ្រេង វិលមែ, «សំឡេងជនជាតិដើមភាគតិចក្នុងនយោបាយពិភពលោក (១៩៩៣), ៩៧, ដកស្រង់ចេញពីរបាយការណ៍របស់ សុទ្ធ សង់ប៊ុន, «សិទ្ធិពលរដ្ឋជនជាតិដើមភាគតិចនៅកម្ពុជា» (ឆ្នាំ២០០៨) ទំព័រ៤១៣។

[63] សេចក្តីប្រកាសរបស់អ.ស.បស្តីពីសិទ្ធិជនជាតិដើមភាគតិច, សេចក្តីសម្រេចរបស់មហាសន្និបាត៦១/២៩៥ (ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧) http://bit.ly/1h1SfDS

[64] អនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច, (ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩), http://bit.ly/17FKSZV

[65] ដូចខាងលើ មាត្រា ២៦

[66] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[67] មាត្រា ៤ នៃអនុក្រឹត្យលេខ៨៣

[68] ដូចខាងលើ មាត្រា ៦

ប្រើប្រាស់នោះជាដីរដ្ឋ មិនមែនជាដីរបស់សហគមន៍បែបដូចនេះហើយ ទើបធ្វើឲ្យស្ថានភាពដីរបស់ពួកគាត់ ឋិត ក្រោមហានិភ័យនៃការដកហូតពីសំណាក់អាជ្ញាធរ។ ទាំងអស់នេះ មានន័យថា ដរាបណាពួកគាត់មិនបានចុះ បញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិចនោះទេ ដីប្រភេទនេះនឹងត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអាចត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ចបាន។ ទោះជាយ៉ាងនេះក្តី សហគមន៍ជនជាតិដើមភាគតិចមាន សិទ្ធិបន្តគ្រប់គ្រង និងប្រើប្រាស់ដីទាំងនោះទៅតាមទំនៀមទំលាប់របស់ពួកគាត់។[69]

អាស្រ័យហេតុនេះហើយ តាមទស្សនទានច្បាប់ ជនជាតិដើមភាគតិចកម្ពុជាបានទទួលនូវការការពារ សិទ្ធិដីធ្លីយ៉ាងច្រើន តែទោះជាមានការការពារស្របច្បាប់យ៉ាងណាក្តី ពលរដ្ឋជនជាតិដើមភាគតិចនៅតែជាជន រងគ្រោះពីការបណ្តេញចេញ និងការបំពានសិទ្ធិមនុស្សដទៃទៀត ដែលព័ត៌មានលម្អិតនឹងយកមកពិភាក្សាក្នុង ជំពូកទី៣ និងទី៤។

### ២.២.៣. *ទ្រព្យសម្បត្តិរដ្ឋ*

ការបែងចែកដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ គឺជាបរិបទ គន្លឹះនៃក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា។ ការបែងចែងប្រភេទដីនេះគឺជាចំណុចគន្លឹះក្នុងការស្វែង យល់ពីនីតិវិធីនៃការប្រើប្រាស់ដីទាំងនោះ។

អនុក្រឹត្យលេខ១២៩ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ (អនុក្រឹត្យលេខ១២៩)[70] បានចាត់ប្រភេទដីសាធារណៈរបស់រដ្ឋជាដីប្រើប្រាស់ សម្រាប់ផលប្រយោជន៍សាធារណៈ ដូចជាដីដែលផ្ទុកដោយធនធានធម្មជាតិ មានដូចជាបឹង ទន្លេ ព្រៃឈើ ដែន បំរុងធម្មជាតិ និងបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ព្រមទាំងដីដែលដាក់ឲ្យដំណើរការសម្រាប់ សេវាសាធារណៈដូចជាមន្ទីរពេទ្យ សាលារៀន ឬអាគាររដ្ឋបាលសាធារណៈជាដើម។[71] អនុក្រឹត្យនេះក៏បានផ្តល់ និយមន័យដីឯកជនរបស់រដ្ឋថាជាដីដែលទាំងឡាយណា ដែលមិនសម្រាប់ផលប្រយោជន៍សាធារណៈ និង ក្រៅ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។[72]

ខណៈដែលដីឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែកដូចជាតាមរយៈសម្បទានដី សេដ្ឋកិច្ច ឬសម្បទានដីសង្គមកិច្ចនោះ[73] ប្រការនេះគឺមិនអាចអនុវត្តបានចំពោះដីសាធារណៈរបស់រដ្ឋនោះ ទេ។[74] ភាពខុសគ្នារវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ គឺមានលក្ខណៈពិសេសក្នុងការដែលអាចផ្ត- ល់ឬជួលដីទាំងនោះទៅឲ្យក្រុមហ៊ុនសម្រាប់គោលបំណងពាណិជ្ជកម្ម និងអភិវឌ្ឍន៍តាមរយៈសម្បទានដីសេដ្ឋ កិច្ច និងសង្គមកិច្ច។ សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចអាចធ្វើទៅបានចំពោះតែដីឯកជនរបស់រដ្ឋ

---

[69] មាត្រា ២៣ នៃច្បាប់ភូមិបាល

[70] អនុក្រឹត្យលេខ១២៩ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ (ថ្ងៃ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦) http://bit.ly/1hcMjcc

[71] មាត្រា ១៥ នៃច្បាប់ភូមិបាល

[72] ដូចខាងលើ មាត្រា ១២ និង១៥, និងមាត្រា ៣ នៃអនុក្រឹត្យលេខ១២៩

[73] ដូចខាងលើ មាត្រា ១៧ និង ៥៨

[74] ដូចខាងលើ មាត្រា ១៦

ប៉ុណ្ណោះ ដើម្បីជាលក្ខណៈទ្រឹស្តីថាការអភិវឌ្ឍន៍សេដ្ឋកិច្ចនោហមិនបំពានហួសពីផលប្រយោជន៍សាធារណៈ។[75] លើសនេះទៀត ដីសាធារណៈរបស់រដ្ឋអាចត្រូវអាចត្រូវបានជួលក្នុងរយៈពេលកំណត់ត្រឹម ១៥ ឆ្នាំប៉ុណ្ណោះ ខណៈដែលដីឯកជនរបស់រដ្ឋអាចធ្វើបានរហូតដល់ ៩៩ ឆ្នាំ។[76]

ទោះជាយ៉ាងនេះក្តី កិច្ចការពារនេះអាចត្រូវបានកាត់ផ្តាច់ តាមលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋឲ្យទៅជាដីឯកជនរបស់រដ្ឋបាន។ យោងតាមច្បាប់ភូមិបាលនោះ ការធ្វើអនុបយោគនោះទៅបានគឺអាស្រ័យទៅតាមច្បាប់ដែលសភាជាអ្នកអនុម័ត។[77] ប៉ុន្តែ រដ្ឋាភិបាលបានដាក់ចេញតែកម្រិតអនុក្រឹត្យដើម្បីធ្វើការអនុបយោគដីដែលជាទ្រព្យសម្បត្តិរដ្ឋ ហើយប្រការនេះគឺមិនអនុលោមតាមតម្រូវការច្បាប់ដែលត្រូវតែឆ្លងកាត់រដ្ឋសភានោះឡើយ។[78] លើសនេះទៀត យោងតាមអនុក្រឹត្យលេខ១២៩ នីតិវិធីនៃការធ្វើអនុបយោគនោះគឺមិនមានលក្ខណៈលំអិតនោះទេ ហើយមិនបានបញ្ចូលនូវបទបញ្ញត្តិនៃការបើកចំហកិច្ចការអនុបយោគ ឬតម្រូវការឲ្យមានការពិគ្រោះយោបល់ជាសាធារណៈផងដែរ។ ទាំងនេះបានបង្កឲ្យមានការធ្វើអនុបយោគដីយ៉ាងបំពាននៅកម្ពុជា ដែលឧទាហរណ៍ជាច្រើនបានបង្ហាញថាដីសាធារណៈរបស់រដ្ឋត្រូវបានបំលែងទៅជាដីឯកជនរបស់រដ្ឋ ហើយបន្ទាប់មកក៏បានផ្តល់សម្បទានដល់ក្រុមហ៊ុនឯកជនសម្រាប់គោលបំណងអភិវឌ្ឍន៍ជាដើម។[79]

### ២.២.៤. សម្បទានដី

> *«ប្រទេសកម្ពុជានឹងមិនត្រូវបាននរណាម្នាក់ទិញនោះទេ» នេះបើយោងតាមប្រសាសន៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន*

សម្បទានគឺជាសិទ្ធិស្របច្បាប់ដែលបានចែកក្នុងឯកសារគតិយុត្តចេញដោយរដ្ឋាភិបាល ឲ្យទៅរូបវន្តបុគ្គលឬនីតិបុគ្គលឬក្រុមមនុស្ស ដើម្បីកាន់កាប់ដី និងអភិវឌ្ឍដីឯកជនរបស់រដ្ឋនោះ។[80] សិទ្ធិនេះត្រូវបានកម្រិតដោយច្បាប់ភូមិបាល អនុក្រឹត្យពាក់ព័ន្ធ និងគោលការណ៍ជាក់លាក់នៃកិច្ចសន្យាសម្បទាននោះ។ យោងតាមច្បាប់ភូមិបាល ប្រភេទសម្បទានដីត្រូវបានចែកជា ២ ប្រភេទ៖[81] សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច។[82] សម្បទានដីសេដ្ឋកិច្ចអនុញ្ញាតឲ្យសម្បទានិកកាប់ឆ្ការ ទាញយកផលដោយអាជីវកម្មកសិឧស្សាហកម្មលើដី ដូចជាការដាំដុះឈើ (កៅស៊ូ ។ល។) ឬផលិតកម្មស្បៀងអាហារទ្រង់ទ្រាយធំ (អង្ករ ពោត ។ល។) ផ្ទុយទៅវិញ សម្បទានដីសង្គមកិច្ចគឺត្រូវប្រើប្រាស់សម្រាប់ការងារសង្គម ជាជាងគោលបំណងសេដ្ឋកិច្ច។

---

[75] ដូចខាងលើ មាត្រា ១៦

[76] ដូចខាងលើ មាត្រា ៦១

[77] ដូចខាងលើ មាត្រា ១៦ និង១៧

[78] លោក សុរិយា ប្រាសាទ ស៊ូបេឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[79] សម្រាប់ព័ត៌មានលម្អិត សូមមើលក្នុងជំពូកទី៣

[80] មាត្រា ៤៨ នៃច្បាប់ភូមិបាល

[81] សម្បទានរុករករ៉ែ ការអភិវឌ្ឍន៍សហគ្រាស និងសម្បទាននេសាទ (អាជ្ញាប័ណ្ណ) គឺឋិតក្រៅពីយុត្តាធិការនៃច្បាប់ភូមបាល គឺមានសម្បទាន

[82] មាត្រា ៤៩ នៃច្បាប់ភូមិបាល

ឧទាហរណ៍សម្បទានដីសង្គមកិច្ចអាចត្រូវបានផ្ដល់ដីឯកជនរបស់រដ្ឋ ឲ្យទៅពលរដ្ឋក្រីក្រដែលគ្មានដីសម្រាប់ជាលំនៅដ្ឋាន និងការងារកសិកម្ម។

សម្បទានដីសង្គមកិច្ច គឺត្រូវបានអនុវត្តន៍តាមអនុក្រឹត្យលេខ១៩ ស្ដីពីសម្បទានដីសង្គមកិច្ច(អនុក្រឹត្យលេខ១៩)។[83] សម្បទានដីសង្គមកិច្ចអាចត្រូវបានផ្ដល់ជូនដើម្បីឆ្លើយតបនឹងប្រយោជន៍សង្គម ប៉ុន្តែក៏អាចសម្រាប់ប្រយោជន៍អភិវឌ្ឍន៍សេដ្ឋកិច្ច សម្រួលដល់សម្បទានដីសេដ្ឋកិច្ចតាមរយៈការផ្ដល់ដីដល់កម្មករដែលធ្វើការលើការដាំដំណាំទ្រង់ទ្រាយធំនោះសម្រាប់សង់លំនៅដ្ឋាន ឬដាំដំណាំនៅលើដីនោះជាការចិញ្ចឹមគ្រួជីវិតគ្រួសារ។»[84] គោលបំណងទាំងបីនេះសំខាន់គឺផ្ដោតលើការអភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅ ដែលនេះផ្ដល់ជាធន្ទានុសិទ្ធិដល់រដ្ឋាភិបាលក្នុងការកំណត់ថាតើសម្បទានដីសង្គមកិច្ចគួរត្រូវបានប្រើប្រាស់យ៉ាងណា ពោលគឺសម្រាប់ជាឧបករណ៍ផែនការទីក្រុងនិងជនបទ ព្រមទាំងការគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល។ គោលបំណងដូចបានរៀបរាប់នេះ ហាក់ដូចជាជៀសឆ្ងាយពីគោលបំណងនៃការផ្ដល់សម្បទានដី សម្រាប់សង្គមកិច្ច ហើយធ្វើហើយកម្មវិធីនេះងាយត្រូវបានគេបំពានប្រើប្រាស់សម្រាប់ផលប្រយោជន៍ពាណិជ្ជកម្មជាង។

ខុសពីសម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ចត្រូវផ្ដល់ជូនដោយឥតគិតថ្លៃ ហើយសម្បទានិកអាចមានកម្មសិទ្ធិលើដីនោះ។ ប្រសិនបើកិច្ចសន្យាសម្បទានដីនោះត្រូវបានធ្វើឡើងក្នុងរយៈពេល ៥ ឆ្នាំដំបូង នោះសម្បទានិកអាចទទួលបានដីសម្បទាននោះទៅជាកម្មសិទ្ធិ ហើយស្នើសុំនូវប័ណ្ណកម្មសិទ្ធិផងដែរ។[85] ក្នុងអំឡុងពេល ៥ ឆ្នាំនេះ ដីសម្បទានសង្គមកិច្ច និងសម្បទាននេះ មិនបានត្រូវបានធ្វើការលក់ដូរ ជួល ឬធ្វើអំណោយដីសម្បទានឡើយ។[86]

សម្បទានដីសេដ្ឋកិច្ច ត្រូវបានចែងក្នុងអនុក្រឹត្យលេខ១៤៦ ស្ដីពីសម្បទានដីសេដ្ឋកិច្ច(អនុក្រឹត្យលេខ១៤៦)[87]។ ចាប់តាំងពីឆ្នាំ២០០០មក ពលរដ្ឋជាង ៧០០.០០០ នាក់ ត្រូវបានគេគណនាថាត្រូវបានរងផលប៉ះពាល់ដោយសារសម្បទានដីសេដ្ឋកិច្ច។[88] ដីជា ៣ លានហិកតា ប្រហែលជា១៦,៦% នៃដីសរុបចំនួន១៨.១ លានហិកតានៅកម្ពុជា ត្រូវបានគេផ្ដល់សម្បទានសេដ្ឋកិច្ច ដល់ក្រុមហ៊ុនបរទេស និងក្នុងស្រុកព្រមទាំងអ្នកនយោបាយដែលមានទ្រព្យស្ដុកស្ដម្ភ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម។[89] យោងតាមការស្រាវជ្រាវរបស់ ម.ស.ម.ក ដីជាង ១ លានហិកតា ត្រូវបានផ្ដល់ឲ្យតាមរយៈសម្បទានដីសេដ្ឋកិច្ចក្នុងអឡុងអណត្តិនីតិកាលទី៤នៃរដ្ឋសភាជាតិ។

---

[83] អនុក្រឹត្យ លេខ ១៩ ស្ដីពីដីសម្បទានសង្គមកិច្ច អនក/បក (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣) http://bit.ly/17FLTRS

[84] ដូចខាងលើ មាត្រា ៣

[85] មាត្រា ១៨ នៃអនុក្រឹត្យលេខ១៩

[86] ដូចខាងលើ

[87] អនុក្រឹត្យលេខ១៤៦ ស្ដីពីសម្បទានដីសេដ្ឋកិច្ច (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥) http://bit.ly/17FLWgj

[88] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ យុទ្ធនាការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានគេបំពាន» (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/17FLZsD

[89] ម.ស.ម.ក, របាយការណ៍គោលនយោបាយកែទម្រង់ដីធ្លី៖ របកគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1eFH2Fc

សម្បទានដីសេដ្ឋកិច្ច គឺមិនអាចជាកម្មសិទ្ធិបាននោះទេ តែជាការជួលដីកម្មសិទ្ធិរដ្ឋតែប៉ុណ្ណោះ ដែលការផ្តល់សម្បទាននេះអាចកំណត់ដល់ ៩៩ ឆ្នាំ។[90] ជាងនេះទៅទៀត សម្បទានដីសេដ្ឋកិច្ចមិនអាចធ្វើឡើងឲ្យហួសពី ១០.០០០ ហិកតានោះឡើយ ហើយគ្មានបុគ្គលរូបវន្ត ឬនីតិបុគ្គលអាចត្រូវបានទទួលសម្បទានដីសេដ្ឋ-កិច្ចច្រើនជាង ១០.០០០ ហិកតានោះដែរ។[91] បញ្ញាតិនេះក៏ត្រូវអនុវត្តចំពោះសម្បទានដីសេដ្ឋកិច្ចដែលផ្តល់ដល់នីតិបុគ្គលដែលជាម្ចាស់ដដែលៗផងដែរ។ មានតែរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទេដែលមានសមត្ថកិច្ចក្នុងការផ្តល់សម្បទានសេដ្ឋកិច្ច។[92]

យោងតាមអនុក្រឹត្យលេខ១៤៦ សម្បទានសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឲ្យ ចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យចំនួន ៥៖[93]១) ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថា ជាដីឯកជនរបស់រដ្ឋ ២) ដីដែលមានផែនការប្រើប្រាស់ដីអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង[94] ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ ៣) ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ៤) ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មី ហើយមិនមានការបង្ខំឲ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត និង៥)មានការពិគ្រោះយោបល់ជាសាធារណៈជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់នោះ។

[90] មាត្រា ៦១ នៃច្បាប់ភូមិបាល

[91] ដូចខាងលើ មាត្រា ៥៩

[92] មាត្រា ២៩ នៃអនុក្រឹត្យលេខ១៤៦

[93] ដូចខាងលើ មាត្រា ៤

[94] សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ដោយរដ្ឋាភិបាលកណ្តាលផងដែរ។ សូមមើលអនុក្រឹត្យលេខ១៣១ ស្តីពីវិសោធនកម្មអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨។

# ៣. ការអនុវត្តជាក់ស្តែង៖ មិនបានអនុលោមតាមច្បាប់

ដូចបានរៀបរាប់ក្នុងជំពូកមុន កិច្ចគាំពារដោយក្របខណ្ឌច្បាប់ ចំពោះសិទ្ធិដីធ្លីនៅកម្ពុជា គឺមានតែនៅលើក្រដាសប៉ុណ្ណោះ។ តំណាងពិសេសរបស់អង្គការសហប្រជាជាតិ បានកត់សម្គាល់ថា "ដោយឃើញលក្ខណៈនៃក្របខណ្ឌច្បាប់និងក្របខណ្ឌគោលនយោបាយ ដែលសភាពប្រសើរឡើងគួរសមហើយនោះ [...] គេពិបាកនឹងទទួលយកបាន នូវទង្វើដូចពេលបច្ចុប្បន្ននេះណាស់"។[៩៥] *ទោះបីច្បាប់ភូមិបាល នៅមានចំណុចខ្វះខាតដែលគួរវេងការរិះគន់យ៉ាងណាក្តី បញ្ហាដែលបង្កឡើងដោយចន្លោះប្រហោង របស់ក្របខណ្ឌច្បាប់នេះ នៅមានកម្រិតតិចតួចប៉ុណ្ណោះ ក្នុងស្ថានភាពជាក់ស្តែង បើប្រៀបធៀបនឹងទំហំបញ្ហា ដែលបង្កឡើងដោយការពុំអនុលោមតាមច្បាប់ វិញនោះ។ ជាក់ស្តែង នៅក្នុងបណ្តាកិច្ចពិភាក្សាតុមូល ដែលម.ស.ម.កបានរៀបចំកន្លងមក គេបានលើកឡើងថា ការដែលរដ្ឋាភិបាល ពុំបានអនុវត្តឲ្យត្រឹមត្រូវ ទៅតាមច្បាប់ដែលមានស្រាប់ គឺជាប្រភពនៃជម្លោះដីធ្លី។*[៩៦]

ការអនុវត្តច្បាប់នៅធូររលុង បានក្លាយជាបញ្ហានៃអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ការអភិវឌ្ឍមិនអនុលោមតាមក្របខណ្ឌច្បាប់ បានបង្កជាមជ្ឈដ្ឋានអំណោយផលដល់ការរំលោភយកដី និងធ្វើឲ្យប្រជាពលរដ្ឋកាន់តែងាយរងគ្រោះពីការបណ្តេញចេញ និងអំពើហិង្សា។ ជំពូកនេះ បានប្រើប្រាស់ករណីជាក់ស្តែង ដែលបង្ហាញពីភាពខុសប្លែករវាងច្បាប់និងការអនុវត្តច្បាប់ ដែលពាក់ព័ន្ធនឹងអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី (ផ្នែក ៣.១) សម្បទានដី(ផ្នែក ៣.២) និងការបណ្តេញចេញដោយបង្ខំ(ផ្នែក ៣.៣)។

## ៣.១. អសុវត្ថិភាពក្នុងការកាន់កាប់ដី

តាមការកត់សម្គាល់ពីខាងដើម ខ្មែរក្រហមបានរំលាយកម្មសិទ្ធឯកជនទាំងអស់ ហើយមកទល់បច្ចុប្បន្ន ប្រជាពលរដ្ឋកម្ពុជានៅតាមជនបទ នៅតែផ្អែកលើការតាំងទីលំនៅអាស្រ័យផល ដើម្បីសម្គាល់ជាម្ចាស់កម្មសិទ្ធិ ហើយដែលការយល់ចិត្តគ្នារវាងអ្នកជិតខាងនិងអ្នកភូមិ ត្រូវបានគិតថាគ្រប់គ្រាន់ហើយ ក្នុងការកំណត់ព្រំដែន។ ជាលទ្ធផល ប្រជាពលរដ្ឋរាប់លាននាក់នៅតែខ្វះឯកសារ និងការទទួលស្គាល់យ៉ាងពេញលេញ លើសិទ្ធិពួកគេដែលអមជាមួយនឹងកម្មសិទ្ធិដីធ្លី។[៩៧]

---

[៩៥] លោក សុរិយា ប្រាសាទ ស៊ូបេឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[៩៦] ម.ស.ម.ក, «របាយការណ៍គោលនយោបាយកំណែទម្រង់ដីធ្លី៖ របកគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ» (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1inGTWX

[៩៧] លោក សុរិយា ប្រាសាទ ស៊ូបេឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

**អត្ថន័យនៃការរំលោភយកដីធ្លី៖** *(សេចក្តីប្រកាស ទី៦៣)*
សកម្មភាពទិញយកដីក្នុងទំហំធំ ឬសម្បទាន ត្រូវបានកំណត់ថាជាការរំលោភយកដី ប្រសិនបើសកម្មភាពទាំងនោះមានលក្ខណៈដូចចំណុចណាមួយ ខាងក្រោម៖

- ការរំលោភសិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្មើភាពរបស់ស្ត្រី
- មិនផ្អែកលើការព្រមព្រៀងជាមួយអ្នកប្រើប្រាស់ដីដែលប៉ះពាល់ ដែលធ្វើឡើងដោយមិនបង្ខិតបង្ខំ (ដោយសេរី) និងដោយមានការជូនដំណឹងជាមុនបានយ៉ាងត្រឹមត្រូវ
- មិនផ្អែកលើការវាយតម្លៃឲ្យបានហ្មត់ចត់ ឬក៏មិនអើពើចំពោះផលប៉ះពាល់ផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម រួមទាំងផលប៉ះពាល់ជាក់លាក់មកលើស្ត្រី
- មិនផ្អែកលើកិច្ចសន្យាដែលមានតម្លាភាព ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តច្បាស់លាស់ និងគោរពតាមច្បាប់អំពីសកម្មភាព ការងារ និងការបែងចែកផលប្រយោជន៍ និង
- មិនផ្អែកលើផែនការបែបលទ្ធិប្រជាធិបតេយ្យដ៏មានប្រសិទ្ធភាព ការពិនិត្យមើលដោយឯករាជ្យ និងការចូលរួមដ៏មានអត្ថន័យ។

កង្វះប័ណ្ណកម្មសិទ្ធិដីធ្លី(ប្លង់រឹង) បង្កើតឲ្យមានអសុវត្ថិភាព និងងាយរងគ្រោះយ៉ាងធំធេង ចំពោះការចាប់យកដីធ្លី និងការបណ្តេញចេញដោយបង្ខំ។ ដោយគ្មានប័ណ្ណកម្មសិទ្ធិ ប្រជាពលរដ្ឋជាច្រើនបានក្លាយទៅជាបុគ្គលដែលមិនអាចការពារខ្លួនបាន នៅពេលដែលអាជ្ញាធរ ឬក្រុមហ៊ុនមកចាប់យកដីរបស់ពួកគេ។ បញ្ហាដែលពាក់ព័ន្ធនឹងអវត្តមាននៃប្លង់រឹងរបស់ប្រជាពលរដ្ឋ ក៏ត្រូវបានអ្នកចូលរួមកិច្ចពិភាក្សាតុមូល លើកឡើងជាញឹកញាប់ផងដែរ ហើយក្នុងអំឡុងវេទិកាគោលនយោបាយចំនួន ២ ដែលរៀបចំដោយម.ស.ម.ក បេក្ខជនគណបក្សប្រឆាំងជាច្រើន បានបញ្ចូលតម្រូវការប្លង់រឹង ទៅក្នុងបញ្ជីគោលនយោបាយរបស់ខ្លួនផងដែរ។[៩៨]

### *៣.១.១. កម្មវិធីចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ*

ដោយទទួលស្គាល់ពីភាពចាំបាច់ ក្នុងការផ្តល់សុវត្ថិភាពចំពោះសិទ្ធិកាន់កាប់ដីធ្លីឲ្យបានល្អប្រសើរ និងដើម្បីការពារប្រជាពលរដ្ឋកម្ពុជាឲ្យបានល្អជាងនេះ រដ្ឋាភិបាល បានបង្កើតកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីចំនួន ២ ៖ (១) កម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធ និង (២) កម្មវិធីចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ។ យោងតាមរដ្ឋាភិបាល គិតត្រឹមខែកញ្ញា ឆ្នាំ២០១៣ កម្មវិធីនេះ

**ការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ** ចាប់ផ្តើមឡើងដោយមានការសំណូមពរពីម្ចាស់ដី ដែលមានបំណងចង់ដាក់សំណើដើម្បីទទួលបាន និងចុះបញ្ជីដីធ្លី។

**ការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ** ចាប់ផ្តើមដោយរដ្ឋ ដែលកំណត់តំបន់ដែលដីនឹងត្រូវបានវិនិច្ឆ័យ និងផ្តល់កម្មសិទ្ធិ។

[៩៨] ម.ស.ម.ក, «របាយការណ៍គោលនយោបាយកំណែទម្រង់ដីធ្លី៖ របកគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ» (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1inGTWX

បានផ្តល់កម្មសិទ្ធិដីធ្លីចំនួន ជាង ៣ លាន កម្មសិទ្ធិរួចទៅហើយ។[៩៩] ខណៈពេលដែលកម្មវិធីទាំងនេះ ទទួលបានជោគជ័យ សម្រាប់លទ្ធផលជាបរិមាណ ដោយសារតែមានប័ណ្ណកម្មសិទ្ធិជាច្រើនត្រូវបានផ្តល់នៅក្នុងប្រទេស ប៉ុន្តែកម្មវិធីនេះបានបង្ហាញឲ្យឃើញថា ផលប៉ះពាល់ផ្នែកគុណភាព នៅមានកម្រិតទាបនៅឡើយ ក្នុងការផ្តល់ស្ថិរភាពកម្រិតខ្ពស់ និងការការពារសម្រាប់ប្រជាពលរដ្ឋ ដែលកំពុងតែប្រឈមនឹងជម្លោះដីធ្លី។[១០០] បន្ថែមពីលើនោះ ការចំណាយដែលកើតមានព្រមជាមួយនឹងការសម្រេចចិត្តរបស់រដ្ឋ ក្នុងការដកដីមានជម្លោះចេញពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិនេះ ក៏បានកំហិតប្រសិទ្ធភាពនៃកម្មវិធីនេះយ៉ាងធំសម្បើមផងដែរ។

យោងតាម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក្រសួងរៀបចំដែនដី) ការចំណាយសម្រាប់កម្មវិធីចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ មានតម្លៃចាប់ពី ១២.៥ ដុល្លារ (សម្រាប់ដីនៅជនបទ) និង ៨៧.៥០ ដុល្លារ (សម្រាប់ដីនៅទីប្រជុំជន នៅភ្នំពេញ សីហនុ[101] និងសៀមរាប)[102] និងការចំណាយសម្រាប់ធ្វើការវិនិច្ឆ័យ ស្រាវជ្រាវ និងការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ មានតម្លៃប្រហែល ១០ ដុល្លារ ក្នុង ១ក្បាលដី[103] (ដោយមិនបញ្ចូលការចំណាយសម្រាប់ការចុះបញ្ជីក្បាលដី)។ ខណៈពេលដែល ការចំណាយទាំងនោះតែម្យ៉ាង អាចនឹងក្លាយជាបន្ទុកដែលមិនអាចគ្រប់គ្រងបានសម្រាប់ប្រជាពលរដ្ឋកម្ពុជាជាច្រើន ការចំណាយនោះគឺតិចជាង តម្លៃដែលបានទទួលពីកម្រៃជើងសារនៃការចុះបញ្ជី។ មន្ត្រីរដ្ឋាភិបាល តែងតែទាមទារឲ្យអ្នកដាក់ស្នើសុំ បង់ប្រាក់សំណូកដើម្បីឲ្យការស្នើសុំនោះត្រូវបានអនុញ្ញាត មានន័យថាក្នុងការអនុវត្តជាក់ស្តែង ចំនួនដែលអ្នកដាក់ពាក្យស្នើសុំត្រូវចំណាយពិតប្រាកដនោះ អាចលើសពីតម្លៃដី ប្រហែលជា ២៥ %។[104]

បន្ថែមពីលើនោះ ក្បាលដីដែលត្រូវបានដកចេញពីការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ ដោយសារតែដីទាំងនោះ "ស្មុគស្មាញពេក" ឬ ដោយសារ "ស្ថានភាពមិនច្បាស់លាស់" (ដូចជា ក្បាលដីដែលមានព្រំដែនជាប់នឹងដីរដ្ឋមិនទាន់ត្រូវបានកំណត់ព្រំដែន ឬពេលដែលបុគ្គលច្រើនជាងម្នាក់ទាមទារកម្មសិទ្ធិលើដីនោះ ជាដើម)។ ក្នុងច្បាប់មិនទាន់មានបទប្បញ្ញត្តិ ដែលកំណត់ឲ្យច្បាស់ថាមានអ្វីដែលត្រូវបានពិចារណាថាជាដីដែល "ស្មុគស្មាញពេក" ឬមាន "ស្ថានភាពមិនច្បាស់លាស់" ឬដែលបានចែងថាដីបែបនោះគួរតែត្រូវបានដកចេញពីដំណើរការចុះបញ្ជី ដែលការកំណត់ទុកធន្ទានុសិទ្ធិឲ្យរដ្ឋក្នុងការបកស្រាយ។ ឧទាហរណ៍ ក្រុមគ្រួសារដែលរស់

---

[៩៩] សន្ទរកថារបស់សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី"យុទ្ធសាស្រ្តចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា (ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣) http://bit.ly/HxsV9U

[១០០] ស្ពានទៅកាន់សន្តិភាពកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាននិងការបណ្តេញចេញ សេវាកម្មយេស៊ូជួយជនភៀសខ្លួន «គ្មានកម្មសិទ្ធិ៖ សុវត្ថិភាពការកាន់កាប់ដីធ្លី និងអសមភាពក្នុងវិស័យដីធ្លីនៅកម្ពុជា» (ឆ្នាំ២០០៩) http://bit.ly/1inMtbK

[101] បច្ចុប្បន្នឈ្មោះថាខេត្តព្រះសីហនុ

[102] ក្រសួងរៀបចំដែនដី «សេចក្តីប្រកាសអន្តរក្រសួងស្តីពី ការកំណត់ប្រាក់ចំណូលមកពីថ្លៃសេវាកម្មសុរិយោដី» លេខ៣៧៧ SHV/, (ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២), http://bit.ly/1bU3wQH

[103] ទស្សនាវដ្តីអ្នកស្រាវជ្រាវអាជីព «ជុំវិញពិភពលោក ៖ ការគ្រប់គ្រងដីនៅកម្ពុជា, (ខែវិច្ឆិកា ឆ្នាំ២០១២), http://bit.ly/1inM2hN

[104] «បញ្ហាផ្ទះសម្បែង និងដីធ្លីនៅកម្ពុជា, ឧបសម្ព័ន្ធទៅរបាយការណ៍អម ដែលបញ្ជូនទៅកាន់គណៈកម្មាធិការស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពាក់ព័ន្ធ នឹងមាត្រា ១១ នៃកតិកាសញ្ញា» (ខែមេសា ឆ្នាំ២០០៩), http://bit.ly/1inHyI7

នៅក្នុងតំបន់ ដែលអះអាងដោយរដ្ឋ ឬក្រុមហ៊ុន មិនអាចជានាសិទ្ធិរបស់ពួកគេលើដីទាំងនេះ និងត្រូវបានផ្ដល់ប័ណ្ណកម្មសិទ្ធិឲ្យនោះទេ ដោយសារតែរដ្ឋអះអាងថាដីរបស់ពួកគេមាន "ស្ថានភាពមិនច្បាស់លាស់" ហើយដូច្នេះបានដកដីទាំងនេះចេញពីកម្មវិធីចុះបញ្ជី។ ជាលទ្ធផល ក្រុមគ្រួសារជាច្រើនដែលងាយរងគ្រោះចំពោះការបណ្ដេញចេញដោយបង្ខំ ហើយជម្លោះដីធ្លី ត្រូវបានទុកឲ្យនៅក្រៅកម្មវិធីផ្ដល់ប័ណ្ណកម្មសិទ្ធិ និងងាយរងគ្រោះចំពោះការរំលោភសិទ្ធិមនុស្ស។[105]

***បឹងកក់ ភ្នំពេញ***[106]

ការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ កាលពីដំបូងត្រូវបានគ្រប់គ្រងដោយ គម្រោងរដ្ឋបាលរៀបចំដែនដីដែលឧបត្ថម្ភធំដោយធនាគារពិភពលោក។ កម្មវិធីនេះ ផ្ដើមដំណើរការចាប់ពី ឆ្នាំ២០០២ រហូតដល់ ចុងឆ្នាំ ២០០៩ បន្ទាប់ពីមានពាក្យបណ្ដឹងពីប្រជាពលរដ្ឋរស់នៅក្នុងតំបន់បឹងកក់។ ប្រជាពលរដ្ឋក្នុងតំបន់បឹងកក់ មានសិទ្ធិស្របច្បាប់ចំពោះដីធ្លីរបស់ពួកគេ ប៉ុន្តែដីទាំងនោះត្រូវបានដកចេញពីការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ នៅពេលដែលកម្មវិធីនេះត្រូវបានអនុវត្តក្នុងតំបន់របស់ពួកគេ ក្នុង ឆ្នាំ២០០៦ ដោយសារតែដីនោះមាន "ស្ថានភាពមិនច្បាស់លាស់"។ រយៈពេលក្រោយមកមិនយូរប៉ុន្មាន រដ្ឋាភិបាលបានជួលដីក្នុងតំបន់នោះ រយៈពេល ៩៩ឆ្នាំ ទៅក្រុមហ៊ុន ស៊ូកាគូ អ៊ីន ដែលជាក្រុមហ៊ុនគ្រប់គ្រងដោយ លោក ឡៅ មេងឃិន ព្រឹទ្ធសភារបស់គណបក្ស ប្រជាជន និងជាអ្នកមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដែលត្រូវបានដាក់ជួល ក្រោយមកត្រូវបានចោទប្រកាន់ថាជាអ្នករស់នៅដោយខុសច្បាប់លើដីកម្មសិទ្ធិរបស់រដ្ឋ។ បន្ទាប់ពីមានការដាក់ពាក្យប្ដឹងទៅកាន់ធនាគារពិភពលោក និងលទ្ធផលនៃការបង្កកកម្មវិធីរបស់ធនាគារពិភពលោកនៅកម្ពុជា រដ្ឋាភិបាលបានចាត់ចែង ដីទំហំ ១២.៤៤ ហិកតា សម្រាប់ក្រុមគ្រួសារចំនួន ៨០០គ្រួសារ។ នេះគឺជាភាពជោគជ័យគួរឲ្យកត់សម្គាល់របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។ ប៉ុន្តែ ក្រុមគ្រួសារ ចំនួន ៩៦គ្រួសារ ត្រូវបានដកចេញពីការចាត់ចែងដីនេះ ហើយមានក្រុមគ្រួសារចំនួន ៨ ត្រូវបានបណ្ដេញចេញពីតំបន់នោះដោយហិង្សា នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១។ ក្រុមគ្រួសារដែលមិនត្រូវបានរាប់បញ្ចូល បានរស់នៅក្នុងតំបន់បឹងកក់ ទាមទារឲ្យមានការវាស់វែងដីរបស់ពួកគេ និងរង់ចាំទទួលយកប័ណ្ណកម្មសិទ្ធិ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ អាជ្ញាធរបានចាប់ផ្ដើមកំណត់ព្រំដែនដី ដែលចាត់ទុកជាជំហានឈានមុខមួយជំហានក្នុងការបែងចែកប័ណ្ណកម្មសិទ្ធិ។[107]

---

105 ស្ថានទៅកាន់សន្តិភាពកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាននិងការបណ្ដេញចេញ សេវាកម្មយេស៊ូជួយជនភៀសខ្លួន «គ្មានកម្មសិទ្ធិ៖ សុវត្ថិភាពការកាន់កាប់ដីធ្លី និងអសមភាពក្នុងវិស័យដីធ្លីនៅកម្ពុជា» (ឆ្នាំ២០០៩) http://bit.ly/1inMtbK

106 អង្គការសមធម៌កម្ពុជា «កម្ពុជា ៖ ការបណ្ដេញចេញនៅបឹងកក់» (វីដេអូ), http://bit.ly/16HLjpr

107 កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ «អ្នកភូមិនៅបឹងកក់ជិតទទួលបានកម្មសិទ្ធិដីធ្លី» ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣, http://bit.ly/1eh8OIb

***ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ***[108]

ក្រោយពី ឆ្នាំ២០០៩ កម្មវិធីចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ បានបន្តសកម្មភាពក្នុង ខេត្តចំនួន ១៥ និងនៅទីក្រុងភ្នំពេញ។ ការស្រាវជ្រាវដែលធ្វើឡើងដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពី កម្ពុជា បានរកឃើញថាដីមានជម្លោះ បន្តត្រូវបានដកចេញពីដំណើរការនៃកម្មវិធីចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ ជាពិសេសក្នុងតំបន់ទីប្រជុំជន។ ឧទាហរណ៍ ក្នុងភូមិទំនប់ នៅភ្នំពេញ ក្បាលដីប្រហែលជា ៨០% មិនទាន់ត្រូវបានចុះបញ្ជី។ ខណៈពេលដែល ក្រុមគ្រួសារចំនួន ៨៦១ គ្រួសារ ដែលរស់នៅក្នុងភូមិ មានត្រឹមតែ ១៩៥ ក្បាលដីប៉ុណ្ណោះដែលត្រូវបានវិនិច្ឆ័យ និងមានប័ណ្ណកម្មសិទ្ធិចំនួន ៤១ ប៉ុណ្ណោះដែលត្រូវបានផ្តល់ ដែលមានន័យថាមាន ដីត្រឹមតែ ១កន្លែង ក្នុងចំណោម ដី ៥កន្លែងដែលបានវិនិច្ឆ័យ ត្រូវបានចុះឈ្មោះ។ របាយការណ៍បានពន្យល់បន្ថែមថា ក្រុមគ្រួសារភាគច្រើន បានដឹងថាពួកគេត្រូវបានបដិសេធមិនផ្តល់ប័ណ្ណកម្មសិទ្ធិ បន្ទាប់ពីពួកគេបានឮថាកម្មវិធីចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធត្រូវបានសន្និដ្ឋាន។

ក្នុងឆ្នាំ២០១២ កម្មវិធីចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបានបញ្ឈប់ និងជំនួសដោយ កម្មវិធីចុះបញ្ជីរបស់ ក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ។

### *៣.១.២. កម្មវិធីចុះបញ្ជី ក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ*

> *"ដីនេះត្រូវបានវាស់វែង ដើម្បីអាចចេញប័ណ្ណកម្មសិទ្ធិកាន់កាប់ដី ទៅឲ្យអាជ្ញាធរ អ្នកមាន និងក្រុមដែលជិតស្និទ្ធិនឹងពួកគេ" – សមាជិកសហគមន៍ ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង*

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន បានសម្ពោធយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដ៏ធាប់ហ័ស ថ្មីមួយ ដែលអនុវត្តដោយយុវជនស្ម័គ្រចិត្ត។ កម្មវិធីនេះគ្របដណ្តប់តំបន់ដែលក្រុមគ្រួសារ ដែលរស់នៅលើដីរដ្ឋ ដោយគ្មានឯកសារផ្នែកច្បាប់ត្រឹមត្រូវ ដែលដីនោះត្រូវបានដាក់ជាសម្បទានដីសេដ្ឋកិច្ច ឬសម្បទានឡូត៍នៃសាទ។ យោងតាមក្រសួងរៀបចំដែនដី នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ មានប័-ណ្ណកម្មសិទ្ធិចំនួន ៣៨០,០០០ ត្រូវបានផ្តល់។ យុទ្ធនាការថ្មីនេះ ត្រូវបានផ្អាកនៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៣ មុនការបោះឆ្នោតជាតិ ថ្ងៃទី២៨ ខែកក្កដា។ នៅមិនទាន់ច្បាស់នោះទេថាតើយុទ្ធនាការនេះនឹងត្រូវបន្តទៀតឬយ៉ាងណា ដោយសារតែការបោះឆ្នោតបានបញ្ចប់ទៅហើយនោះ។

ការព្រួយបារម្ភជាច្រើនត្រូវបានលើកឡើង ពាក់ព័ន្ធនឹងយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដែលត្រូវបានគេហៅថា "*យុវជនស្ម័គ្រចិត្ត សម្តេច តេជោ*" (ត្រូវបានហៅតាមងាររបស់ លោក ហ៊ុន សែន)។ កម្មវិធីនេះចាប់ផ្តើមក្នុង ចុងខែមិថុនា ឆ្នាំ២០១២ ដោយក្រុមយុវជនស្ម័គ្រចិត្ត ត្រូវបានដាក់ពង្រាយនៅក្នុងខេត្តនានា ដើម្បីកំណត់ព្រំប្រទល់ដី។ តាមការកត់សម្គាល់របស់អ្នកតំណាងពិសេស ការណែនាំ និងឯកសារគោលនយោបាយនឹងត្រូវបានបង្កើត ក្រោយពីការកំណត់ព្រំប្រទល់នោះត្រូវបានចាប់ផ្តើមហើយប៉ុណ្ណោះ[109] ដែលនេះបង្ហាញពី "*កង្វះខាតនៃការធ្វើផែនការឲ្យបានទូលំទូលាយ និងអនុលោមទៅតាមក្របខណ្ឌច្បាប់ និងប្រព័ន្ធផ្តល់កម្មសិទ្ធិ*

---

[108] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា «ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា ការសិក្សាពីការចុះបញ្ជីជាប្រព័ន្ធក្នុងខេត្តចំនួន ៣ នៅកម្ពុជា និងទីក្រុង» (ខែវិច្ឆិកា ឆ្នាំ២០១២) http://bit.ly/HoeO6M

[109] លិខិតទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៦៦៦ ស.ជ.ណ (ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២), ក្រុមប្រឹក្សាគោលនយោបាយដីធ្លី លេខ ០១៥ (ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២), ក្រុមប្រឹក្សាគោលនយោបាយដីធ្លី សេចក្តីណែនាំ លេខ០១៨ (ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២)

*ដែលមានស្រាប់*”។[110] កម្មវិធីនេះហាក់ដូចជាមានការជះឥទ្ធិពលផ្នែកនយោបាយក្នុងកម្រិតខ្ពស់ ដោយសារតែក្រុមយុវជនដែលត្រូវបានដាក់ពង្រាយនោះ មានការរាយការណ៍ថា ត្រូវបានជ្រើសរើសតែក្នុងចំណោមអ្នកគាំទ្រ ប្រ.ជ និងត្រូវអនុវត្តការងាររបស់ពួកគេក្នុងឯកសណ្ឋានទាហាន ដែលមានមធ្យោបាយធ្វើដំណើរជាឡានទាហាន និងត្រូវបានទទួលដោយអាផ្ទាធរពី ប្រ.ជ។[111] គម្រោងនេះក៏ហាក់ដូចជា មិនស្ថិតក្រោមក្របខណ្ឌច្បាប់នោះទេ ហើយត្រូវបានឧបត្ថម្ភធនដោយមូលនិធិផ្ទាល់ខ្លួនរបស់ លោកនាយករដ្ឋមន្ត្រី។[112] រដ្ឋាភិបាលក៏បានណែនាំ មិនឲ្យអង្គការនានា ជ្រៀតជ្រែកក្នុងការអនុវត្តន៍កម្មវិធីនេះផងដែរ ដែលធ្វើឲ្យសហគមន៍ និងក្រុមគ្រួសារជាច្រើន មិនបានយល់ដឹងពីសិទ្ធិរបស់ពួកគេ។

យុទ្ធនាការ ក៏មិនរាប់បញ្ចូលនូវតំបន់ដែលមានជម្លោះ និងដីសមូហភាពរបស់ជនជាតិដើមភាគតិចនោះដែរ (មើលផ្នែក ៣.១.៣ ខាងក្រោម) ជាថ្មីម្តងទៀត កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិនេះមិនបានបញ្ចូលប្រជាពលរដ្ឋដែលងាយរងគ្រោះនោះទេ។ ឧទាហរណ៍ ក្នុងស្រុកបុទុមសាគរ និងស្រុកគិរីសាគរ ដែលមានគ្រួសារចំនួន ៣០០ ដែលកំពុងមានជម្លោះជាមួយនឹង ក្រុមអភិវឌ្ឍន៍សហជីព ក្រុមយុវជនស្ម័គ្រចិត្ត បដិសេធមិនព្រមវាស់វែងដីបុគ្គល ដោយអះអាងថាដីទាំងនោះស្ថិតក្នុងតំបន់ដែលមានជម្លោះ។[113]

ម.ស.ម.ក ក៏មានការព្រួយបារម្ភខ្លាំងដែរ ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ក្នុងខែតុលា ឆ្នាំ២០១៣ ម.ស.ម.ក បានសម្ភាសន៍ប្រជាពលរដ្ឋក្នុងភូមិ ពោធិ៍សាត់ ក្នុងឃុំក្បាលត្រាច ស្រុកក្រគរ។ យោងតាមអ្នកផ្តល់បទសម្ភាសន៍ ទោះបីជាមាន ក្រុមគ្រួសារចំនួន១០ ត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិ បន្ទាប់ពីការកំណត់ព្រំដែន ដោយក្រុមយុវជនស្ម័គ្រចិត្តក្នុងខែធ្នូ ឆ្នាំ២០១២ *ក្រុមហ៊ុន ភាពីម៉ិច* បានបន្តកាន់កាប់ដីនោះដដែល។ ក្នុងខែឧសភា ឆ្នាំ២០១៣ គ្រួសារទាំងនោះបានដោតបង្គោលព្រំដី ដើម្បីការពារដីរបស់ពួកគេ ប៉ុន្តែតំណាងរបស់ក្រុមហ៊ុនបាននិយាយថា គាត់មិនទទួលស្គាល់ប័ណ្ណកម្មសិទ្ធិទាំងនោះទេ។ ស្របពេលជាមួយគ្នានេះ លោក គួច វ៉េង ដែលជាសមាជិកនៃបណ្តាញសន្តិភាពសហគមន៍ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ បន្ទាប់ពីបានទៅសួរសុខទុក្ខសហគមន៍ដែលរងគ្រោះ។[114] រដ្ឋាភិបាលអាចអះអាងថា ខ្លួនបានចែកចាយប័ណ្ណកម្មសិទ្ធិដីធ្លីជាច្រើនតាមរយៈយុទ្ធនាការនេះ ប៉ុន្តែកម្មវិធីនេះនឹងនៅតែមិនមានប្រសិទ្ធិភាព ប្រសិនបើមិនមានការអនុវត្តន៍ ហើយសកម្មជនដែលជួយដល់សហគមន៍ទាំងនោះទាមទារការទទួលស្គាល់ដីធ្លី នៅតែត្រូវបានចាប់ខ្លួន។

---

[110] លោក សុរិយា ប្រាសាទ ស៊ូប៉ៃឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[111] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានគេបំពាន» (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/17FLZsD

[112] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានគេបំពាន» (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/17FLZsD

[113] សម្រាប់ឧទាហរណ៍បន្ថែមសូមអាន អង្គការអាដហុក, «ផ្លូវរបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

[114] អង្គការឃ្លាំមើលសិទ្ធិមេធាវីកាណាដា «កម្ពុជា ៖ ការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស លោក គួច វ៉េង តាមអំពើចិត្ត» (លិខិត) (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣), http://bit.ly/173SecM

កម្មវិធីចុះបញ្ជីថ្មីរបស់ រដ្ឋាភិបាល គឺនៅក្រៅច្បាប់ មិនមានតម្លាភាព និងមិនត្រូវបានត្រួតពិនិត្យ។ មិនទាន់មាននរណាដឹងថា កម្មវិធីនេះនឹងត្រូវបន្ត ឬយ៉ាងណានោះទេ ព្រោះថាការបោះឆ្នោតបានបញ្ចប់ទៅហើយ ដែលបណ្តាលឲ្យមានការសង្ស័យកាន់តែខ្លាំង ថាតើយុទ្ធនាការនេះគ្រាន់តែជាការប៉ុនប៉ងដើម្បីទាក់ទាញសំឡេងឆ្នោត សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ ឬក៏យ៉ាងណានោះ។

### *៣.១.៣. ការចុះបញ្ជីកម្មសិទ្ធិសមូហភាពរបស់ក្រុមជនជាតិដើមភាគតិច*

ដូចបានពន្យល់ក្នុងជំពូក ២ ច្បាប់ភូមិបាល បានទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការចុះបញ្ជីដីរបស់ពួកគេ និងដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព។[115] ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិនេះ សហគមន៍នោះត្រូវតែចុះឈ្មោះ មុនពេលដែលដីសហគមន៍នោះអាចត្រូវចុះបញ្ជីបាន។ ប៉ុន្តែ ការចែកចាយប័ណ្ណកម្មសិទ្ធិសមូហភាព ហាក់ដូចជានៅតែក្នុងការស្រមើស្រមៃ ដោយសារមានតែ សហគមន៍ចំនួន ៥ ក្នុងចំណោម សហគមន៍ចំនួន ១១៤ ប៉ុណ្ណោះ[116] ដែលបានដាក់ពាក្យស្នើ និងបានបំពេញតាមដំណើរការស្នើសុំនោះទាំងស្រុង។[117]

កង្វះឆន្ទៈផ្នែកនយោបាយ ក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច (ដែលតែងតែរស់នៅក្នុងតំបន់ដែលសម្បូរធនធាន) និងការអនុវត្តន៍ច្បាប់នៅមានកម្រិត គឺជាមូលហេតុសំខាន់ៗចំនួន ២ ដែលធ្វើឲ្យដីសមូហភាពទំហំតូចបែបនេះ ត្រូវផ្តល់ជាដីសម្បទាន។ សេចក្តីណែនាំ អំពីរបៀបដែលសហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព ទើបតែត្រូវបានបង្កើតឡើងក្នុង ឆ្នាំ២០០៩[118] រយៈពេល ៨ឆ្នាំ ក្រោយពីច្បាប់ភូមិបាលបានអនុម័ត។ បើតាមកំណត់សម្គាល់របស់ការស្រាវជ្រាវថ្មីៗ[119] រយៈពេលប៉ុន្មានឆ្នាំនោះសំខាន់ខ្លាំងណាស់ ៖ ក្នុងអំឡុងពេលរវាងការអនុវត្តន៍ច្បាប់ភូមិបាល ក្នុង ឆ្នាំ២០០១ និងការចេញអនុក្រឹត្យក្នុង ខែមិថុនា ឆ្នាំ២០០៩ មានដីប្រមាណ ២,១០៦,៣៤៣ ហិកតា ត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ច។[120]

បន្ថែមពីលើនោះ ដំណើរការនៃការចុះបញ្ជីប័ណ្ណកម្មសិទ្ធិសមូហភាព មានរយៈពេលយូរ និងស្មុគស្មាញជាខ្លាំង។ តាមការអនុវត្តន៍ ជំហានចំនួន ១១ ដែលតម្រូវឲ្យសហគមន៍ចុះបញ្ជីខ្លួនឯងជាដំបូងសិន ហើយក្រោយមកក៏ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិ និងដំណើរការនោះពាក់ព័ន្ធជាមួយនឹងក្រសួងរដ្ឋាភិបាលចំនួន ៣។ ដំណើរការនោះចាប់ផ្តើម ជាមួយនឹងការកំណត់អត្តសញ្ញាណរបស់សហគមន៍ដោយផ្លូវការថាជា *"វប្បធម៌*

---

[115] ច្បាប់ភូមិបាល មាត្រា ២៦

[116] ហ្វ្រែនស៍ វ៉ុលតឺរ និង គុនធឺរ ស៊ុលដហ្វ «គោលនយោបាយចាស់ សកម្មភាពថ្មី ៖ ការបង្កើតថ្មីផ្នែកនយោបាយដ៏គួរឲ្យភ្ញាក់ផ្អើល ក្នុងការទទួលស្គាល់សិទ្ធិមនុស្ស ក្នុងកំណែទម្រង់ដីធ្លីរបស់កម្ពុជា» សន្និសីទប្រចាំឆ្នាំ របស់ធនាគារពិភពលោក ស្តីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ ២០១៣ ថ្ងៃទី ៨-១១ ខែមេសា ឆ្នាំ២០១៣ http://bit.ly/HxqbcD

[117] ឧត្តមស្នងការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស «សហគមន៍ជនជាតិដើមភាគតិច ចំនួន ៣ នឹងទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព», (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១), http://bit.ly/Hxp24M

[118] អនុក្រឹត្យលេខ ៨៣

[119] ដែហ្វ និងម៉ែនហ្វ្រីត ហ៊ារណុង មូលនិធិ ហេនរេចបូល «ជនជាតិដើមភាគតិច និងប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា», សន្និសីទប្រចាំឆ្នាំរបស់ធនាគារពិភពលោក ស្តីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ២០១៣ ថ្ងៃទី ៨-១១ ខែមេសា ឆ្នាំ២០១៣ http://bit.ly/HxqbcD

[120] អង្គការលីកាដូ «ការបង្ហាញដ៏អស្ចារ្យរបស់កម្ពុជា ៖ បង្ហាញពីដីសម្បទានក្នុងរយៈពេលនីមួយៗ», (ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣) http://bit.ly/HxpSOV

*ប្រពៃណី"* ដោយក្រសួងអភិវឌ្ឍន៍ជនបទ (ក្រសួងអភិវឌ្ឍន៍)។ បន្ទាប់មក សហគមន៍ត្រូវតែដាក់ពាក្យសុំការទទួលស្គាល់ថាជា *"នីតិបុគ្គល"* ជាមួយក្រសួងមហាផ្ទៃ។ ចុងក្រោយ បន្ទាប់ពីបានចុះឈ្មោះជានីតិបុគ្គលរួច សហគមន៍ជនជាតិដើមភាគតិច ត្រូវតែស្នើសុំទៅក្រសួងរៀបចំដែនដី ដើម្បីចេញប័ណ្ណកម្មសិទ្ធិសមូហភាព។[121] ដំណើរការបច្ចុប្បន្ន មិនបានធានាសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី ក្នុងអំឡុងដាក់ពាក្យស្នើសុំនោះទេ ដែលនេះជាការព្រួយបារម្ភដ៏ធំមួយ ដោយសារតែរយៈពេលដែលត្រូវចំណាយក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពនោះ។

រយៈពេលថ្មីៗនេះ កម្មវិធីចុះបញ្ជីថ្មីរបស់ក្រុមយុវជន បានណែនាំមិនឲ្យអាជ្ញាធរមូលដ្ឋានចុះបញ្ជីដីឲ្យដល់ក្រុមជនជាតិដើមភាគតិចនោះទេ។[122] បន្ថែមពីលើនោះ មានរបាយការណ៍ថា សហគមន៍ជនជាតិដើមភាគតិច ត្រូវបានដាក់សម្ពាធដើម្បីឲ្យទទួលយកប័ណ្ណកម្មសិទ្ធិឯកជន ជាជាងប័ណ្ណកម្មសិទ្ធិសមូហភាព។[123] ចំណុចនេះក៏ធ្វើឲ្យមានការព្រួយបារម្ភទៀត ដោយសារតែក្នុងច្បាប់កម្ពុជា នៅពេលដែលក្រុមជនជាតិដើមភាគតិចព្រមទទួលយកប័ណ្ណកម្មសិទ្ធិឯកជន ពួកគេនឹងមិនអាចដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិសមូហភាពបាននោះទេ។[124] ឧទាហរណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានរាយការណ៍ករណី ដែលសហគមន៍ជនជាតិដើមភាគតិចក្នុងស្រុកថ្ពោង នៃខេត្តកំពង់ស្ពឺ ដែលត្រូវបានដាក់សម្ពាធដោយសារក្រុមយុវជនស្ម័គ្រចិត្ត ឲ្យទទួលយកប័ណ្ណកម្ម-សិទ្ធិឯកជនជំនួសឲ្យប័ណ្ណកម្មសិទ្ធិសមូហភាព ៖

> *"ក្រុមនិស្សិតនិយាយថា យើងត្រូវតែទទួលយកអ្វីដែលមន្ត្រីសុរិយោដីថ្នាក់ខេត្តបញ្ជាឲ្យធ្វើ ដែលធ្វើតាមការបញ្ជារបស់ក្រសួងនៅទីក្រុងភ្នំពេញ [...] ប្រសិនបើមិនដូច្នេះទេ នឹងមានបញ្ហា ហើយយើងនឹងមិនទទួលបានអ្វីទាំងអស់។"*[125]

ខណៈពេលដែលច្បាប់បានផ្តល់យន្តការ សម្រាប់ប្រជាពលរដ្ឋ ដើម្បីអាចទទួលបានប័ណ្ណកម្មសិទ្ធិ និងដើម្បីលុបបំបាត់កេរ្តិ៍ដំណែលខ្មែរក្រហម ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង មានសហគមន៍ជាច្រើន ជាពិសេសសហគមន៍ដែលងាយរងគ្រោះចំពោះការរំលោភយកដី និងដែលចាំបាច់ត្រូវទទួលបានប័ណ្ណកម្មសិទ្ធិដែលមានសុវត្ថិភាព មិនត្រូវបានការពារនោះទេ។ ពួកគេត្រូវបានដកចេញពីក្របខណ្ឌច្បាប់ និងការការពារដែលក្របខណ្ឌច្បាប់នោះផ្តល់ឲ្យ ដោយចេតនា។ ដោយគ្មានប័ណ្ណកម្មសិទ្ធិ ដីរបស់ប្រជាពលរដ្ឋទាំងនេះ អាចត្រូវបានរំលោភយកដោយងាយស្រួល និងប្រើប្រាស់សម្រាប់គោលបំណងផ្នែកពាណិជ្ជកម្មក្នុងនាមការអភិវឌ្ឍ។

---

[121] អនុក្រឹត្យលេខ ៨៣

[122] ក្រុមប្រឹក្សាគោលនយោបាយដីធ្លី សេចក្តីណែនាំលេខ ២០ ស្តីពីការអនុវត្តន៍បទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ១ ប.ប (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២), http://bit.ly/1hcN4lm

[123] ដែហ្វ និងម៉ែនហ្វ្រីត ហ៊ែរណុង មូលនិធិ ហេនរេចបូល «ជនជាតិដើមភាគតិច និងប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា», សន្និសីទប្រចាំឆ្នាំរបស់ធនាគារពិភពលោក ស្តីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ២០១៣ ថ្ងៃទី ៨-១១ ខែមេសា ឆ្នាំ២០១៣ http://bit.ly/HxqbcD

[124] ដូចខាងលើ។

[125] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានគេបំពាន» (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/17FLZsD

## ៣.២. ការអភិវឌ្ឍន៍មិនអនុលោមតាមវិធានច្បាប់

ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា ត្រូវបានរាំងស្ទះដោយកង្វះតម្លាភាព។ ប័ណ្ណកម្មសិទ្ធិដែលត្រូវបានផ្តល់ដោយមន្ត្រីរដ្ឋាភិបាល សម្រាប់សម្បទានដីដែលមានទំហំទ្រង់ទ្រាយធំដើម្បីឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ចសកលទៅលើដីធ្លី ក្នុងករណីជាច្រើន បានបំពានលើច្បាប់ ឬព្រងើយកន្តើយចំពោះច្បាប់ដែលបានបង្កើតឡើងដើម្បីការពារទាំងសិទ្ធិមនុស្ស និងបរិស្ថាន។ ប៉ុន្តែមិនទាន់មានបញ្ជីសម្បទានដីពេញលេញ និងអាចស្វែងរកបានត្រូវបានចងក្រងនៅឡើយ ហើយការទទួលបានព័ត៌មានជុំវិញការដោះដូរដី និងដំណើរការដេញថ្លៃ ការវិនិយោគដី ការពិនិត្យមើលឡើងវិញលើសម្បទានដី និងលក្ខខណ្ឌក្នុងការសម្រេចចិត្ត នៅតែជារឿងពិបាកយល់។ កង្វះតម្លាភាព បានសម្រួលដល់បរិស្ថាននៃអំពើពុករលួយ ដែលអាជ្ញាធរ និងអាជីវកម្មព្រងើយកន្តើយចំពោះសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជា។

### *៣.២.១. មន្ត្រីរដ្ឋាភិបាល និងសម្បទានដីធ្លី*

ក្រុមហ៊ុនឯកជនមួយចំនួន ដែលជាប្រភពសំខាន់នៃជម្លោះដីធ្លីនៅកម្ពុជា មានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងរដ្ឋាភិបាល។ របាយការណ៍ជាបន្តបន្ទាប់ដែលចេញផ្សាយដោយ អង្គការ គ្លូបិល វីតនេស បានបង្ហាញពីបណ្តាញក្រុមហ៊ុនឯកជន និងទំនាក់ទំនងដែលមានការសង្ស័យរវាងមន្ត្រីរដ្ឋាភិបាល និងអ្នកទទួលដីសម្បទាន។ របាយការណ៍នោះបានប៉ាន់ស្មានថា ចំនួន ២០% នៃចំនួនដីសរុប ត្រូវបានបែងចែកតាមរយៈការផ្តល់សម្បទាន ដែលរៀបចំដោយសមាជិកព្រឹទ្ធសភាជាន់ខ្ពស់ចំនួន ៥នាក់។[126]

ឧទាហរណ៍ ក្រុមហ៊ុន គ្រីស ស៊ី ដែលគ្រប់គ្រងដោយព្រឹទ្ធសភាកម្ពុជា ឧកញ៉ា ម៉ុង រិទ្ធី ក្នុងខេត្តស្ទឹងត្រែង ត្រូវបានចុះបញ្ជីថាជាអ្នកទទួលដីសម្បទានចំនួន ១០០,៨៥២ ហិកតា។[127] ឧទាហរណ៍មួយទៀត គឺក្រុមហ៊ុន *ភាពីម៉ិច* អ្នកទទួលដីសម្បទានដ៏ធំបំផុតនៅកម្ពុជា។ *ភាពីម៉ិច* ត្រូវបានគ្រប់គ្រងរួមជាមួយនឹងសមាជិកព្រឹទ្ធិសភាកម្ពុជា លោក ឡៅ ម៉េងឃិន ជាក្រុមហ៊ុនដែលពាក់ព័ន្ធនឹងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃនៅកម្ពុជា។[128] ក្នុង ឆ្នាំ ២០០០ ក្រុមហ៊ុន *ភាពីម៉ិច* ទទួលបានដីសម្បទានចំនួន ៣១៥,២០៨ ហិកតា ក្នុងខេត្តពោធិ៍សាត់ និងកំពង់ចាម។

ក្នុងខេត្តពោធិ៍សាត់តែមួយត្រូវបានគេប៉ាន់ប្រមាណថា មានក្រុមគ្រួសារចំនួន ៨,២០០ គ្រួសារដែលត្រូវបានរងគ្រោះដោយជម្លោះដីធ្លីជាមួយនឹងក្រុមហ៊ុន *ភាពីម៉ិច* ។[129] តាមរយៈសម្បទានកាប់ឈើ សម្បទានដី និងសម្បទានរ៉ែ របស់ខ្លួន មានការរាយការណ៍ថា ក្រុមហ៊ុន *ភាពីម៉ិច* គ្រប់គ្រងលើដីចំនួន ៧% នៃផ្ទៃដីសរុប

---

[126] អង្គការគ្លូបិល វីតនេស «អភិជនកៅស៊ូ វិធីដែលក្រុមហ៊ុនវៀតណាម និងអ្នកហិរញ្ញវត្ថុអន្តរជាតិ បានដឹកនាំវិបត្តិដីធ្លីនៅក្នុងប្រទេសឡាវ និងកម្ពុជា» (ខែឧសភា ឆ្នាំ២០១៣), http://bit.ly/1ar7lKn

[127] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[128] អង្គការគ្លូបិល វីតនេស «កម្ពុជាសម្រាប់លក់ ៖ វិធីដែលអភិជននៅកម្ពុជា បានកាន់កាប់នូវឧស្សាហកម្មអស្សាមិករណ៍របស់ប្រទេស» (ខែកុម្ភៈ ឆ្នាំ២០០៩), http://bit.ly/1c3N3cG

[129] កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ «ប័ណ្ណកម្មសិទ្ធិថ្មីនៅមិនទាន់បានទទួលស្គាល់ ៖ ប្រជាពលរដ្ឋ» (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣), http://bit.ly/1c3OSGm

របស់ប្រទេសកម្ពុជា ។[130] លោក ឡៅ ម៉េងឃីន ក៏ជានាយក ក្រុមហ៊ុន *សំណង់អភិវឌ្ឍន៍ការដើកវ៉ែ ទ្រីភាព ហុង ហ៊្វូ* និងដូចដែលបានរៀបរាប់មុននេះ គឺ *ស៊ូកាគូ អ៊ីន* ដែលជាក្រុមហ៊ុនមានពាក់ព័ន្ធនឹងការអភិវឌ្ឍន៍បឹងកក់ដ៏ល្បីឈ្មោះ នៅចំកណ្តាលទីក្រុងភ្នំពេញ ដែលធ្វើឲ្យពលរដ្ឋប្រហែលជា ៣.០០០ នាក់ត្រូវបានបណ្តេញចេញដោយបង្ខំ។[131]

ក្រុមហ៊ុន *សេង គាង* និង លោក សេង កុកហ៊ាង ត្រូវបានរាយការណ៍ថាមានជាប់ពាក់ព័ន្ធនឹងការកាប់ឈើ ក្នុងតំបន់សម្បទាន ដុងហ្វ៊ូ និងដុងណៃ។[132] លោកស្រី សេង គាង (ម្ចាស់ក្រុមហ៊ុន *សេង គាង*) បងប្រុសរបស់លោកស្រី សេង កុកហ៊ាង និងអតីតស្វាមីលោកស្រី ឈ្មោះ ឌី ចូច (ដែលជាបងប្អូនជីដូនមួយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន) រួមគ្នាបង្កើត *"សមាគមកាប់ឈើពិសេស"* ដោយបានជះឥទ្ធិពលយ៉ាងខ្លាំងលើឧស្សាហកម្មកាប់ឈើនៅកម្ពុជា។[133] បន្ថែមពីលើនោះ មានមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយចំនួន រួមទាំង រដ្ឋមន្ត្រីក្រសួងដែនដី បានទៅទស្សនកិច្ចតំបន់សម្បទាន និងបានលើកទឹកចិត្តឲ្យអ្នកស្រុក *"លះបង់"* ដីទៅឲ្យក្រុមហ៊ុនថែមទៀតផង។[134]

### ៣.២.២. *ខ្វះការពិភាក្សា និងការវាយតម្លៃ*

> *"មនុស្សគ្រប់គ្នាមានការភ័យខ្លាចជាខ្លាំង ប៉ុន្តែពួកគេមិនបានផ្តល់ព័ត៌មានចេញទៅក្រៅនោះទេ" -អាឡិច ហ្គុងហ្សៀល ដាវីសុន អង្គការមាតាធម្មជាតិកម្ពុជា និយាយពីការសាងសង់សំណង់វារីអគ្គិសនីរបស់ចិននៅក្នុងតំបន់អារ៉ែង*

ដូចដែលបានរៀបរាប់កាលពីមុន ដីសាធារណៈរបស់រដ្ឋ អាចត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ប្រសិនបើដីនោះមិនបានផ្តល់ប្រយោជន៍សាធារណៈ បាត់បង់តួនាទីដែលត្រូវបានរំពឹងទុកពីដំបូង ឬក៏មិនត្រូវបានប្រើប្រាស់ដោយសាធារណជនដោយផ្ទាល់។[135] ប៉ុន្តែ មានការចងក្រងឯកសារទុកយ៉ាងល្អថា អាជ្ញាធរតែងតែធ្វើអនុបយោគតាមអំពើចិត្ត ប្តូរពីដីសាធារណៈរបស់រដ្ឋ ទៅដីឯកជនរបស់រដ្ឋ។[136] តាមការស្រាវជ្រាវរបស់ ម.ស.ម.ក បានបង្ហាញថា ចាប់តាំងពី ឆ្នាំ២០០៨ មានដីសរុប ៨៥៥,៦១២.៨៤ ហិកតា នៃដីសាធារណៈរបស់រដ្ឋត្រូវបានធ្វើអនុបយោគទៅជាដីឯកជនរបស់រដ្ឋ។ ដោយសារតែចំនួនប្រជាពលរដ្ឋនៅក្នុងតំបន់ជនបទដែលមានប័ណ្ណកម្មសិទ្ធិកាន់កាប់ដី មានចំនួនតិចតួចនៅឡើយ ការធ្វើអនុបយោគដី បានកើតឡើងក្នុង

---

130 អង្គការគ្លូបិល វិតនេស «កម្ពុជាសម្រាប់លក់ ៖ វិធីដែលអភិជននៅកម្ពុជា បានកាន់កាប់នូវឧស្សាហកម្មអស្សាមិករណ៍របស់ប្រទេស» (ខែកុម្ភៈ ឆ្នាំ២០០៩), http://bit.ly/1c3N3cG

131 ដូចខាងលើ។

132 អង្គការគ្លូបិល វិតនេស «អភិជនកៅស៊ូ វិធីដែលក្រុមហ៊ុនវៀតណាម និងអ្នកហិរញ្ញវត្ថុអន្តរជាតិ បានដឹកនាំវិបត្តិដីធ្លីនៅក្នុងប្រទេសឡាវ និងកម្ពុជា» (ខែឧសភា ឆ្នាំ២០១៣), http://bit.ly/1ar7lKn

133 ដូចខាងលើ

134 ដូចខាងលើ

135 ព្រះរាជក្រឹត្យ ស្តីពី បញ្ញត្ត និងគោលការណ៍ស្តីពីការធ្វើអនុបយោគនៃដីសាធារណរបស់រដ្ឋ និងនីតិបុគ្គល នស/រកត/០៨០៦/៣៣៩, (ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៦)

136 មើលឧទាហរណ៍ អង្គការអាដហុក, «ផ្លូវបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

តំបន់ជាច្រើនដែលត្រូវបានកាន់កាប់ ឬប្រើប្រាស់ដោយក្រុមសហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច។

មុនពេលផ្តល់ដីសម្បទានសេដ្ឋកិច្ច អនុក្រឹត្យលេខ ១៤៦ ចែងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវតែបានធ្វើឡើង ហើយដែលមានការពិគ្រោះយោបល់ជាសាធារណៈដោយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងតំបន់នោះកើតឡើង។[137]

ថ្វីបើមាន ការការពារផ្នែកច្បាប់ តំបន់ដីដែលមានទំហំធំ ត្រូវបានផ្តល់ជាដីសម្បទានទាំង ទោះបីជាមានការពិគ្រោះយោបល់ដែលប្រជាពលរដ្ឋមិនពេញចិត្ត ឬក៏មិនមានការពិគ្រោះយោបល់កើតឡើងផងនោះក៏ដោយ។ ម.ស.ម.ក បានរកឃើញឧទាហរណ៍មួយចំនួន នៃសហគមន៍ដែលមិនបានដឹងថាដីដែលពួកគេពឹងផ្អែកដើម្បីបង្គ្រប់តម្រូវការមូលដ្ឋានរបស់ពួកគេ ត្រូវបានផ្តល់ជាដីសម្បទានសេដ្ឋកិច្ចទៅហើយ។ ឧទាហរណ៍មួយ គឺភូមិកាំ ក្នុងខេត្តរតនគិរី[138] ដែលទាំងក្រុមជនជាតិដើមភាគតិចដែលរងគ្រោះ ឬសូម្បីតែអាជ្ញាធរមូលដ្ឋានមិនត្រូវបានផ្តល់ដំណឹងជាមុននោះទេថា ក្រុមហ៊ុនកៅស៊ូ វៀតណាម ទទួលបានដីសម្បទានសេដ្ឋកិច្ច នៅលើដីដែលក្រុមជនជាតិដើមភាគតិច កំពុងតែប្រើប្រាស់។ ក្នុងករណីនេះ ហើយក៏ដូចជាករណីជាច្រើនដែរ សេចក្តីជូនដំណឹងដំបូងដែលប្រជាពលរដ្ឋបានទទួល គឺនៅពេលដែលកម្មកររបស់ក្រុមហ៊ុនមកដល់ ហើយចាប់ផ្តើមឈូសឆាយដីរបស់ពួកគេ។

នៅពេលដែលកិច្ចពិគ្រោះយោបល់កើតឡើង កិច្ចពិគ្រោះយោបល់ទាំងនោះតែងតែត្រូវបានរៀបចំឡើងដោយមិនបានល្អ មានលក្ខណៈប្រញាប់ និងដូចជាគំរាមកំហែង ដោយមានអាជ្ញាធរដាក់សម្ពាធលើសហគមន៍ដើម្បីយល់ព្រមតាមគោលបំណងរបស់គាត់។ ឧទាហរណ៍ ម.ស.ម.ក នាពេលថ្មីៗនេះ បានធ្វើការស៊ើបអង្កេតនៅក្នុងស្រែខ្ទុំ ក្នុងខេត្តមណ្ឌលគិរី[139] ដែលសហគមន៍បានអះអាងថា ក្នុងកិច្ចប្រជុំជាច្រើនលើកច្រើនសា អាជ្ញាធរបញ្ជាក់សាជាថ្មីម្តងទៀតថា ពួកគេនឹងមិនទទួលបានប័ណ្ណកម្មសិទ្ធិសម្រាប់ដីរបស់ពួកគេនោះទេ ប្រសិនបើពួកគេមិនចែករំលែកតំបន់ដីព្រៃសម្រាប់ ការអភិវឌ្ឍន៍របស់ចំការជំឡួងមីដែលកាន់កាប់ដោយ ក្រុមហ៊ុនឯកជន។

កង្វះខាតការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដ៏ម៉ត់ចត់ គឺជាប្រភពសំខាន់ដែលបណ្តាលឲ្យមានការព្រួយបារម្ភ។ ជាញឹកញយ ក្រុមហ៊ុនតែងតែចាប់ផ្តើមកាប់ឆ្ការដី និងតំបន់ព្រៃ មុនពេលចេញអនុក្រឹត្យ និងការចុះហត្ថលេខាលើកុងត្រាពាក់ព័ន្ធ។[140] របាយការណ៍ថ្មីមួយបានបង្ហាញថា មានប្រហែលជា ១០% នៃតំបន់អភិរក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ត្រូវបានផ្តល់ជាដីសម្បទានទៅឲ្យក្រុមហ៊ុនឯកជ-

[137] អនុក្រឹត្យ លេខ ១៤៦ មាត្រា ៤ (៣), (៥)

[138] អាស័យដ្ឋានពេញ ៖ ភូមិកាំ ឃុំល្អក់ ស្រុកអូជុំ ខេត្តរតនគិរី

[139] អាស័យដ្ឋានពេញ ៖ ភូមិស្រែខ្ទុំ ឃុំស្រែខ្ទុំ ស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី

[140] អង្គការអាដហុក, «ផ្លូវបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

ន។[141] តំបន់អភិរក្សចំនួន ៣ នៃជម្រកសត្វព្រៃស្នួល តំបន់អភិរក្សព្រះវិហារ និងជម្រកសត្វព្រៃពាមក្រសប ត្រូវបានធ្វើអនុបយោគទៅជាដីឯកជនរបស់រដ្ឋ។[142]

### *៣.២.៣. ការគ្រប់គ្រងសម្បទានជាទូទៅដែលនៅទន់ខ្សោយ*

តាមការពន្យល់ខាងលើ មិនមានរូបវន្តបុគ្គល ឬនីតិបុគ្គលណានឹងអាចត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចច្រើនរួមគ្នា មានចំនួនលើសពី ១០,០០០ ហិកតានោះទេ។[143] តែទោះបីជាយ៉ាងណាក៏ដោយ មានប្រភពមួយចំនួនបង្ហាញថា មានការរំលោភបំពានលើលក្ខខណ្ឌនេះជាច្រើន។ របាយការណ៍ជាច្រើនបានបញ្ជាក់ថាក្នុងករណីដែលបុគ្គល ឬក្រុមបុគ្គលដដែល ដែលមានផលប្រយោជន៍ក្នុងការផ្តល់ដីសម្បទាននោះ ជាញឹកញយតែងតែមានការផ្តល់ដីសម្បទាន ដោយប្រើឈ្មោះផ្សេង ឬដីដែលនៅជាប់គ្នា។ ឧទាហរណ៍ ក្នុងខែកុម្ភៈ ឆ្នាំ២០១០ ព្រឹទ្ធសភាកម្ពុជា លោក លី យ៉ុងផាត់ និងភរិយារបស់លោក លោកស្រី គឹម ហ៊ាង ដែលអ្នកទាំងពីរសុទ្ធតែទទួលបានសម្បទានដី សម្រាប់ចម្ការអំពៅក្នុងខេត្តកំពង់ស្ពឺ។ សម្បទានដីត្រូវបានផ្តល់ឲ្យទៅ *ក្រុមហ៊ុនស្ករភ្នំពេញ* ទទួលបាន ៨,៥០៦ ហិកតា និង *ក្រុមហ៊ុនស្ករកំពង់ស្ពឺ* ដែលទទួលបាន ៨,២៤៥ ហិកតា។

មូលហេតុសំខាន់ដែលធ្វើឲ្យមានការព្រួយបារម្ភដែរ គឺភាពខ្វះខាតក្នុងការអនុវត្តតាមកិច្ចសន្យា ឬផែនការពាណិជ្ជកម្ម។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពី ឆ្នាំ២០០៨ បានកត់សម្គាល់ថា *"ការប្រមូលផ្តុំដីធ្លី និង ចំនួនពលរដ្ឋដែលគ្មានដី មាននិន្នាការកើនឡើង ដែលជាប្រការដាក់នូវបញ្ហាប្រឈមចំពោះសមធម៌ ប្រសិទ្ធភាព ក្នុងការប្រើប្រាស់ដីធ្លី។ ម្យ៉ាងវិញទៀត ដីមួយចំនួនធំ ដែលរដ្ឋបានផ្តល់ជាសម្បទានសេដ្ឋកិច្ចមិនទាន់ត្រូវបានប្រើប្រាស់ឱ្យចំគោលដៅ និង ប្រកបដោយប្រសិទ្ធភាពនៅឡើយ ដែលទាមទារឱ្យរដ្ឋាភិបាលចាត់វិធានការតឹងរ៉ឹង ដើម្បីដោះស្រាយ។"* [144] ទោះបីជាយ៉ាងណាក៏ដោយ ដីសម្បទានសេដ្ឋកិច្ចមួយចំនួន នៅតែមានលក្ខណៈមិនច្បាស់លាស់។ ប្រាកដណាស់ របាយការណ៍ថ្មីៗមួយ បានអះអាងថា បើយោងតាម មន្ត្រីនៃក្រសួងកសិកម្ម បាននិយាយថា ក្រុមហ៊ុនមួយចំនួនខ្វះខាតប្រាក់ដើមទុនក្នុងការបំលែងសម្បទានដីសេដ្ឋកិច្ចរបស់ពួកគេទៅជា សហគ្រាសកសិកម្ម។[145]

ការបង្កើតការងារ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ គឺជាគោលបំណងដ៏សំខាន់របស់សម្បទានដីសេដ្ឋកិច្ច។[146] ប៉ុន្តែ មានការបញ្ជាក់ច្បាស់ណាស់ថា ក្នុងករណីជាច្រើន សម្បទានដីសេដ្ឋកិច្ច

---

[141] អង្គការលីកាដូ/ការវិភាគរបស់កាសែតឌឹខេមបូឌាដេលី, «ការរូងយកកម្ពុជា៖ សម្បទានម្តងមួយៗ» (ថ្ងៃទី១១ និង១២ ខែមិនា ឆ្នាំ២០១២) http://bit.ly/Hpgih2

[142] អង្គការអាដហុក, «ផ្លូវរបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

[143] ច្បាប់ភូមិបាល មាត្រា ៥៩

[144] សន្ទរកថារបស់សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី"យុទ្ធសាស្រ្តចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី២ នៅអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៤ នៃរដ្ឋសភា (ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨) http://bit.ly/HpfSqY

[145] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពី កម្ពុជា «ដីសម្បទានសេដ្ឋកិច្ច និងសហគមន៍មូលដ្ឋាន» (ឆ្នាំ២០១០), http://bit.ly/16LhDb5

[146] អនុក្រឹត្យលេខ ១៤៦ មាត្រា ៥

បានបណ្តាលឲ្យជីវភាពរស់នៅមានការធ្លាក់ចុះ ជាពិសេសក្នុងករណីដែលប្រជាពលរដ្ឋក្នុងស្រុកបាត់បង់លទ្ធភាពប្រើប្រាស់ដីធ្លីដែលពួកគេពឹងផ្អែកលើសម្រាប់ការរស់នៅ ដាំដំណាំ និងការប្រើប្រាស់ផ្នែកកសិកម្ម។

### ៣.២.៤. ការកំណែទម្រង់ពិតប្រាកដ?

នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ២០១២ រដ្ឋាភិបាលបានត្រៀមខ្លួនក្នុងការកែតម្រូវបញ្ហាទាំងឡាយដែលកើតមានពាក់ព័ន្ធនឹងដីសម្បទាន និងបញ្ហាដែលពាក់ព័ន្ធនឹងការផ្អាកដីសម្បទានសេដ្ឋកិច្ចដែលបានស្គាល់ថាជា "បទបញ្ជា លេខ ០១"។[147] បទបញ្ជានេះ អំពាវនាវឲ្យមានការហាមឃាត់ការផ្តល់សម្បទានដីសេដ្ឋកិច្ច ការវាយតម្លៃលើសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលកំពុងតែត្រូវបានផ្តល់ និងការដកហូតសម្បទានដីសេដ្ឋកិច្ច ត្រូវបានរកឃើញថាបានរំលោភលើបញ្ញត្តិច្បាប់ និងកិច្ចសន្យា។[148] សហគមន៍សកម្មជនដីធ្លី បានកោតសរសើរចំពោះការសម្រេចបែបនេះ។

ប៉ុន្តែ ចន្លោះប្រហោងដ៏សំខាន់មួយកើតមាននៅក្នុងការផ្អាកបណ្តោះអាសន្នក្នុងការផ្តល់សម្បទានដី។ សម្បទានដីសេដ្ឋកិច្ច ដែលស្ថិតក្រោមការពិចារណា នៅពេលដែលមានការប្រកាស ការផ្អាកបណ្តោះអាសន្នប្រកាស ត្រូវបានដកចេញពីការដាក់ពាក្យស្នើសុំ។[149] ចំណុចនេះកាន់តែធ្ងន់ធ្ងរទៅ ដោយសារតែការពិតដែលថា រដ្ឋាភិបាល បានខកខានក្នុងការផ្តល់ព័ត៌មានអំពីចំនួន សម្បទានដីសេដ្ឋកិច្ចដែលស្ថិតក្រោមការពិចារណាពេលដែលការផ្អាកត្រូវបានប្រកាស។[150] រយៈពេលមិនយូរប៉ុន្មានបន្ទាប់ពីការផ្អាកបានប្រកាស ម.ស.ម.ក រកឃើញថា រដ្ឋាភិបាលបានផ្តល់ដីចំនួន ៦៦,៣១៤ ហិកតា ថាជាដីសម្បទានសេដ្ឋកិច្ចទៅក្រុមហ៊ុនឯកជនចំនួន ៩។ ចាប់តាំងពីបទបញ្ជានោះត្រូវបានប្រកាស មានដីចំនួន ១៨៨,៧៤៩.៤៩ ហិកតា ត្រូវបានផ្តល់ជាសម្បទានដីតាមរយៈការធ្វើអនុបយោគដី ដែលនេះគឺចំនួនពាក់កណ្តាលនៃដីសរុបដែលត្រូវបានផ្តល់ជាសម្បទានដីតាមរយៈការធ្វើអនុបយោគក្នុងឆ្នាំ ២០១២។[151]

ការពិតជាក់ស្តែង មានការអនុវត្តន៍ជាច្រើនដែលមិនស្របគ្នា ពាក់ព័ន្ធនឹងការអនុវត្តន៍នៃបទបញ្ជា លេខ ០១ រួមទាំង ឧទាហរណ៍ដូចជា ក្នុងគម្រោងគ្រប់គ្រងដី និងការផ្តល់ប័ណ្ណកម្មសិទ្ធិបែបថ្មី ដែលនៅតែឃើញមានកង្វះតម្លាភាពក្នុងដំណើរការជ្រើសរើស និងស៊ើបអង្កេត នៃការផ្តល់ដីសម្បទានដែលមិនបានអភិវឌ្ឍត្រឹមត្រូវ ឬដីដែលអសកម្ម។[152] ឧទាហរណ៍ ចម្ការកៅស៊ូចំនួន ២ ដែលគ្រប់គ្រងដោយ លោកវ៉ែត្ន ត្រូវបានអនុញ្ញាតក្នុង

---

[147] សេចក្តីបង្គាប់ដើម្បីពង្រឹងវាស់វែង និងប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច លេខ ០១ ប.ប (ខែឧសភា ឆ្នាំ២០១២) (បទបញ្ជាលេខ ០១, http://bit.ly/1hcN4lm

[148] ដូចខាងលើ។

[149] អង្គការអាដហុក, «ផ្លូវបេត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

[150] ដូចខាងលើ។

[151] របាយការណ៍ខ្លីរបស់ ម.ស.ម.ក ៖ ម.ស.ម.ក តាមដានដីសម្បទាននៅកម្ពុជា ក្នុងឆ្នាំ២០១២ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣, http://bit.ly/1eFH9Rh

[152] មើលឧទាហរណ៍ លោក សុរិយា ប្រាសាទ ស៊ូបេឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

តំបន់ជម្រកសត្វព្រៃលំផាត់ បន្ទាប់ពីការប្រកាសនៃបទបញ្ជា លេខ ០១ ថ្មីបើការកាន់កាប់នេះផ្ទុយពីច្បាប់ដែលបានកំណត់ទំហំដីសម្បទានសេដ្ឋកិច្ច និងស្ថានភាពរបស់ដីនោះដែលនៅក្នុងតំបន់អភិរក្សក៏ដោយ។[153]

## ៣.៣. ការបណ្តេញចេញដោយបង្ខំ និងអំពើហិង្សាដែលពាក់ព័ន្ធ

ការអភិវឌ្ឍន៍គ្មានសណ្តាប់ធ្នាប់ ដោយគ្មានតម្លាភាពដែលរួមជាមួយនឹងការខ្វះខាតប័ណ្ណកម្មសិទ្ធិ បណ្តាលឲ្យប្រជាពលរដ្ឋកាន់តែងាយរងគ្រោះ ចំពោះ ការរំលោភយកដី និងការបណ្តេញចេញដោយបង្ខំ។ ទោះបីជាមិនច្បាស់ថាការរំលោភយកដី និងការបណ្តេញចេញដោយបង្ខំ គឺជាការត្រួសត្រាយផ្លូវសម្រាប់ដីសម្បទានសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច ឬយ៉ាងណានោះ ការបណ្តេញចេញដោយបង្ខំជាទូទៅ ដែលកើតមានដោយកងកម្លាំងទាហាន ឬកម្លាំងដទៃទៀត តែងតែត្រូវបានធ្វើឡើងដោយគ្មានដំណើរការតាមច្បាប់ត្រឹមត្រូវ និងក្នុងករណីមួយចំនួនអមជាមួយនឹងអំពើហិង្សាផងដែរ។ ជាការឆ្លើយតបទៅនឹងការរីករាលដាលនៃការរំលោភយកដី ការបណ្តេញចេញដោយមិនស្របច្បាប់ និងអវត្តមាននៃយន្តការដោះស្រាយជម្លោះឯករាជ្យ និងមានប្រសិទ្ធភាព បានបណ្តាលឲ្យមានការប្រឆាំងតវ៉ាចេញពីប្រជាពលរដ្ឋ។

### *៣.៣.១. ការបណ្តេញចេញដោយបង្ខំ រួមជាមួយច្បាប់ដែលគ្មានដំណើរការត្រឹមត្រូវ*

ការបណ្តេញចេញដោយបង្ខំ កើតឡើងជាចម្បងដោយសារតែការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយរដ្ឋទៅឲ្យក្រុមហ៊ុន។ ដើម្បីអាចផ្តល់សម្បទានដីសេដ្ឋកិច្ច រដ្ឋអះអាងថាដីដែលមានជម្លោះនោះ គឺជាដីឯកជនរបស់រដ្ឋ ជាជាងទ្រព្យសម្បត្តិឯកជនរបស់បុគ្គល។[154] រដ្ឋគាំទ្រការអះអាងនេះ ដោយមូលហេតុដែលថា ជាញឹកញាប់ប្រជាពលរដ្ឋដែលត្រូវបានជម្លៀស ខ្វះខាតឯកសារ ឬប័ណ្ណកម្មសិទ្ធិដីធ្លី ទោះបីជាពួកគេមានសិទ្ធិកាន់កាប់ស្របច្បាប់ក៏ដោយ[155] ហើយដូច្នេះចាត់ទុកពួកគេថាជាអ្នកចូលកាន់កាប់ដីខុសច្បាប់ ឬ "តាំងលំនៅដ្ឋានឥតស្របច្បាប់" នៅលើដីនោះ ឬទើបតែមករស់នៅលើដីនោះ។ ដូចដែលយើងបានឃើញក្នុង ផ្នែក២.២ ដីដែលមិនត្រូវបានចាត់ចែងថាជាទ្រព្យសម្បត្តិឯកជនរបស់បុគ្គល គឺត្រូវបានពិចារណាដោយព្រឹត្តន័យថាជាដីរដ្ឋ។[156] ដូច្នេះ យោងតាមរដ្ឋ ប្រសិនបើប្រជាពលរដ្ឋមិនមានប័ណ្ណកម្មសិទ្ធិ នោះមានន័យថាដីនោះត្រូវបានគ្រប់គ្រងដោយរដ្ឋ និងអាចត្រូវបានជួលជាសម្បទានដីសេដ្ឋកិច្ចទៅ កាន់ក្រុមហ៊ុន និងអាចជម្លៀសប្រជាពលរដ្ឋដែលរស់នៅលើដីនោះបាន។ មានកត្តាចំនួន ២ ដែលសម្របសម្រួលដល់ការអះអាងលើដីថាជាដីរដ្ឋ។ ទី១ ដូចដែលបានឃើញក្នុងផ្នែក ៣.១.១[157] រដ្ឋដកហូតសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី របស់សហគមន៍ដែលរស់នៅលើដីដែលរដ្ឋាភិបាលមានបំណងផ្តល់ជាដីសម្បទានសេដ្ឋកិច្ច តាមអំពើចិត្ត។ ទី២ មិនមានបញ្ជីសារពើភ័ណ្ឌសាធារណៈ ឬផែនទីរបស់ដីរដ្ឋ នោះមានន័យថាមិនមានមធ្យោបាយណាអាចបញ្ជាក់នូវព្រំដែន ការកំហិត និងសុរិយោដីនៃដីរបស់រដ្ឋ។ ចំណុចនេះអនុញ្ញាតឲ្យរដ្ឋ ប្រកាសថាក្បាលដីណាមួយជាដីរបស់រដ្ឋដោយគ្មានការកំណត់។

---

[153] អង្គការគ្លូបិល វីតនេស «អភិជនកៅស៊ូ វិធីដែលក្រុមហ៊ុនវៀតណាម និងអ្នកហិរញ្ញវត្ថុអន្តរជាតិ បានដឹកនាំវិបត្តិដីធ្លីនៅក្នុងប្រទេសឡាវ និងកម្ពុជា» (ខែឧសភា ឆ្នាំ២០១៣), http://bit.ly/1ar7lKn

[154] មើលផ្នែក ២.២ នៅលើរបាយការណ៍។

[155] ម.ស.ម.ក «ធុរកិច្ច និងសិទ្ធិមនុស្សនៅកម្ពុជា ៖ ការបង្កើតសសរស្តម្ភ ទាំង ៣" (ខែវិច្ឆិកា ឆ្នាំ២០១០) ទំព័រទី ២៦, http://bit.ly/16EB5Gq

[156] ច្បាប់ភូមិបាល មាត្រា ១២

[157] មើលករណីសិក្សា ៖ បឹងកក់ ក្នុងផ្នែក ៣.១.១ នៃរបាយការណ៍។

មានឧទាហរណ៍ជាច្រើន ដែលការបណ្តេញចេញត្រូវបានធ្វើឡើង ដែលជាលទ្ធផលនៃសម្បទានដីសេដ្ឋកិច្ច ដែលអាចឃើញនៅក្នុងឯកសារជាច្រើនដែលប្រមូលដោយអង្គការសិទ្ធិមនុស្សទូទាំងប្រទេស។ ក្នុងចំណោមនោះ មានករណីថ្មីៗដូចជា បឹងកក់[158] និងករណីការបណ្តេញចេញប្រជាពលរដ្ឋចំនួន ១,១០០ គ្រួសារនៅក្នុងខេត្តកោះកុង បង្ខំឲ្យមានការតាំងទីលំនៅថ្មី ដើម្បីត្រួសត្រាយផ្លូវសម្រាប់គម្រោងទេសចរណ៍របស់ក្រុមហ៊ុនចិន យូឌីជី។ គម្រោងនេះ រួមបញ្ចូលទាំងកន្លែងស្នាក់កំសាន្ត និងបនល្បែងនៅតាមឆ្នេរទន្លេ។[159] ការបណ្តេញចេញដោយបង្ខំ មានជាប់ពាក់ព័ន្ធនឹង ដីសម្បទានសេដ្ឋកិច្ច នឹងបន្តថ្វីបើមានការប្រកាសឲ្យមានការផ្អាកផ្តល់សម្បទានដីសេដ្ឋកិច្ចបណ្តោះអាសន្នក៏ដោយ។ ដូចបានពន្យល់ខាងដើម[160] ការផ្អាកផ្តល់សម្បទានដីមិនរួមបញ្ចូលសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានផ្តល់ទៅហើយ ឬនៅក្នុងការពិចារណាក្នុងពេលដែលប្រកាសនោះទេ។ ដូច្នេះ នាំឲ្យប្រជាពលរដ្ឋជាច្រើនត្រូវតែរើផ្ទះរបស់ពួកគេចេញ ឬក៏មិនដូច្នេះទេនឹងត្រូវលិចទឹក ដើម្បីត្រួសត្រាយផ្លូវសម្រាប់ការសាងសង់ទំនប់អគ្គិសនីថ្នាក់ទាបនៅតំបន់ សេសាន ២ ការធ្វើបែបនេះនៅតែបន្តបើទោះបីជាមានការរំលឹកជាលក្ខណៈសាកលពីផលប៉ះពាល់ខូចខាតយ៉ាងដំណំនៃការសាងសង់វារីអគ្គសនីនេះមកលើបរិស្ថាន និងជីវៈចម្រុះ ដូចជា មច្ឆជាតិ និងការបំផ្លាញព្រៃឈើក៏ដោយ។[161]

ថ្មីៗនេះ មានករណីជាច្រើននៃការដេញចេញដោយបង្ខំ ដែលបណ្តាលមកពីដីសម្បទានសង្គមកិច្ច។ ដូចបានចងក្រងទុកដោយអង្គការអាដហុក ក្នុងឆ្នាំ២០១២ រដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ចចំនួន ៣៨ កន្លែង (ដែលមានទំហំធំជាង គម្រោងសម្បទានដីសង្គមកិច្ចក្នុង ឆ្នាំ២០១១ ២ ដង)។ ក្នុងចំណោមដីចំនួន ៣៨ កន្លែង ដែលត្រូវបានផ្តល់ក្នុង ឆ្នាំ២០១២ មានដីចំនួន ១៣ បណ្តាលឲ្យមានជម្លោះដែលបណ្តាលឲ្យ អាដ-ហុក ជឿជាក់ថាការធ្វើបែបនេះអាចនឹងបង្ហាញបីការផ្លាស់ប្តូរក្នុងគោលនយោបាយ។[162] ក្នុងស្រុកគូលែន ខេត្តព្រះវិហារ មានអ្នកភូមិ ចំនួន ៤០០ នាក់ បានចោទប្រកាន់ទៅលើអាជ្ញាធរ និងកម្លាំងចម្រុះថាបានដុតផ្ទះរបស់ពួកគេ និងកាប់ឆ្ការដីចម្ការ ដើម្បីបង្កើតឲ្យមានដីចំនួន ៥,៥៥៧ ហិកតា សម្រាប់សម្បទានដីសង្គមកិច្ច ដែលក្នុងគោលបំណងផ្តល់ឲ្យទៅក្រុមទាហានពិការ ចំនួន ១៦០ គ្រួសារ។[163] ក្នុងខែតុលា ឆ្នាំ២០១៣ អភិបាលរងខេត្តព្រះវិហារ បាននិយាយទៅកាន់តំណាងនៃក្រុមគ្រួសារដែលមកពីស្រុករវៀង ចំនួន ៥០ នាក់ ថា ដីដែលពួកគេរស់នៅលើនោះ នឹងត្រូវបានកាប់ឆ្ការដើម្បីត្រួសត្រាយផ្លូវសម្រាប់សម្បទានដីសង្គមកិច្ចដែលមានទីតាំងនៅជាប់នឹងចម្ការកៅស៊ូ។[164] ក្នុងស្រុកបាកាន មានប្រជាពលរដ្ឋប្រហែល ៣០០ គ្រួសារ ដែលត្រូវប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ដោយសារតែសម្បទានដីសង្គមកិច្ច។ យោងតាម ក្រុមគ្រួសារទាំងនោះបាន

---

[158] មើលករណីសិក្សា ៖ បឹងកក់ ក្នុងផ្នែក ៣.១.១ នៃរបាយការណ៍។

[159] វិទ្យុសំឡេងសហរដ្ឋអាមេរិក "មានប្រជាពលរដ្ឋមួយចំនួនត្រលប់មកវិញ បន្ទាប់ពីត្រូវបានជម្លៀសចេញពីតំបន់ដែលត្រូវអភិវឌ្ឍន៍ជាកន្លែងលម្ហែកាយ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1hiivuP

[160] មើលផ្នែក ៣.២.៤ នៃរបាយការណ៍

[161] វិទ្យុសំឡេងសហរដ្ឋអាមេរិក «ចាប់ផ្តើមការងារ លើគម្រោងដ៏ចម្រូងចម្រាស់នៅកម្ពុជា» (ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣) http://bit.ly/1hij4oe

[162] អង្គការអាដហុក, «ផ្លូវរបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

[163] កាសែត ឌឹ ភ្នំពេញ ប៉ុស្ត៍ «ស្រុកព្រះ បាននាំគ្នាមកតវ៉ាប្រឆាំងនឹងទាហាន» (ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២) http://bit.ly/1hil93t

[164] កាសែត ឌឹ ខេមបូឌា ដេលី «ក្រុមគ្រួសារនៅព្រះវិហារត្រូវបានបញ្ជាឲ្យចៀសផ្លូវឲ្យគ្រឿងយន្តឈូសឆាយ» (ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣)http://bit.ly/1ar0m45

និយាយថា ពួកគេបានរស់នៅលើដីនោះតាំងពី ឆ្នាំ២០០២។ ក្នុង ឆ្នាំ២០១១ ដីសម្បទានសង្គមកិច្ចត្រូវបានផ្តល់ទៅទាហានពិការ និងចូលនិវត្តន៍ បើតាមមើលទៅ។[165] ការបណ្តេញចេញដោយបង្ខំ ពេលខ្លះក៏កើតឡើងដោយសារតែត្រួសត្រាយផ្លូវសម្រាប់ការសាងសង់បន្ទាយទាហានផងដែរ។ ឧទាហរណ៍ ក្នុងខែឧសភា ឆ្នាំ ២០១២ មានក្រុមប្រជាពលរដ្ឋចំនួន ១,០០០ គ្រួសារ ក្នុងខេត្តក្រចេះ ត្រូវបានជម្លៀសដោយបង្ខំចេញពីផ្ទះរបស់ពួកគេដើម្បីត្រួសត្រាយផ្លូវសម្រាប់ កងពលលេខ ៩ នៃ កងយុទ្ធពលខេមរភូមិន្ទ។[166]

ជាញឹកញយ ជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ មិនមានឱកាសចូលរួម និងពិគ្រោះយោបល់ឲ្យបានច្បាស់លាស់ជាមុននោះទេ។[167] ព័ត៌មានស្តីពីផែនការការបណ្តេញចេញ និងកញ្ចប់សម្រាប់ការទីតាំងលំនៅថ្មី តែងតែមិនបានពេញលេញ និងមិនត្រឹមត្រូវ។[168] ជាញឹកញាប់ ក្រុមគ្រួសារតែងតែទទួលការជូនដំណឹងស្តីពីការបណ្តេញចេញ ត្រឹមតែពីរបីថ្ងៃមុន ថ្ងៃកំណត់។ ឧទាហរណ៍ ក្នុងតំបន់បឹងកក់ ប្រជាពលរដ្ឋទទួលដំណឹងថាមានការអនុញ្ញាតឲ្យពួកគេ មានពេល ៧ ថ្ងៃ សម្រាប់ការរុះរើផ្ទះរបស់ពួកគេ ហើយកិច្ចសន្យាផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ ត្រូវបានធ្វើឡើងដោយគ្មានការពិភាក្សាជាមួយនឹងប្រជាពលរដ្ឋរងគ្រោះនោះទេ។[169] ម.ស.ម.ក ធ្វើការស្រាវជ្រាវក្នុង ខែមីនា ឆ្នាំ២០១៣ និងបានសម្ភាសន៍ ប្រជាពលរដ្ឋចំនួន ២៣នាក់ ពីភូមិសំបុកចាបក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានបណ្តេញចេញក្នុង ឆ្នាំ២០០៦។ យោងតាមការសម្ភាសន៍ មានអ្នកដែលត្រូវបានសម្ភាសន៍ ១០នាក់ ក្នុងចំណោម ២៣នាក់ មិនត្រូវបានជូនដំណឹងថានឹងមានការបណ្តេញចេញត្រូវធ្វើឡើងនោះទេ។ បន្ថែមពីលើនោះ តាមឯកសារចងក្រងដោយ អង្គការលើកលែងទោសអន្តរជាតិ ក្នុងករណីដែលមានការពិគ្រោះយោបល់ស្រដៀងគ្នា នោះហាក់ដូចជាថាអាជ្ញាធរបានសម្រេចចិត្តធ្វើការបណ្តេញចេញ និងប្តូរទីលំនៅថ្មីរួចរាល់ទៅហើយ។[170]

### *៣.៣.២. ការបណ្តេញចេញដោយបង្ខំ រួមជាមួយការប្រើហិង្សា*

ច្បាប់ភូមិបាល មានចែងពីបញ្ញត្តដាក់ទោសទណ្ឌ សម្រាប់ការប្រើប្រាស់អំពើហិង្សា ឬកងកម្លាំងដើម្បីបណ្តេញចេញអ្នកកាន់កាប់។ ឧទាហរណ៍ មាត្រា ២៥៤ ហាមឃាត់មិនឲ្យប្រើកម្លាំងឯកជនក្នុង "ករណីណាមួយ" ដើម្បីបណ្តេញចេញ (ទោះបីជាយោងតាមសេចក្តីសម្រេចរបស់តុលាការ) ដែលបញ្ញត្តនោះចែងថាទោសទណ្ឌអតិបរមា គឺត្រូវជាប់ពន្ធនាគារចំនួន ២ ឆ្នាំ ប្រសិនបើមានការរំលោភបំពានបែបនឹងកើតឡើង។ ការការពារបន្ថែមពីលើនោះ សម្រាប់អ្នកកាន់កាប់ មានចែងក្នុងមាត្រា ២៥៣ ដែលនឹងអាចចាត់ទុកជាបទល្មើសក្នុងការប្រើប្រាស់អំពើហិង្សាមកលើ *"អ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងតែមានទំនាស់ក៏ដោយ"*។ [171] បញ្ញត្តស្តីពីការដាក់ទោសទណ្ឌបន្ថែម ក៏បានចែងស្តីពីអាជ្ញាធរមានសមត្ថ-

---

[165] ឌី ភ្នំពេញ ប៉ុស្តិ៍ «ការបដិសេធប័ណ្ណកម្មសិទ្ធិដីធ្លី អ្នកភូមិនៅខេត្តពោធិ៍សាត់អះអាងប្រាប់។ (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣), http://bit.ly/1hikMGd

[166] ឌី ភ្នំពេញ ប៉ុស្តិ៍ «ដីចម្ការត្រូវបានជំនួសដោយបន្ទាយកងយុទ្ធពលខេមរភូមិន្ទ» (ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៣ http://bit.ly/1ar1NQ1

[167] អង្គការលើកលែងទោសអន្តរជាតិ «សិទ្ធិត្រូវបានលុបចោលនៅកម្ពុជា, (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨) http://bit.ly/1ar2w3Q

[168] សម្រាប់ព័ត៌មាន សូមមើលផ្នែក ៣.២.២ នៅក្នុងរបាយការណ៍។

[169] អង្គការលើកលែងទោសអន្តរជាតិ «ប្រជាពលរដ្ឋចំនួន ១៦០ គ្រួសារនៅកម្ពុជាប្រឈមមុខនឹងការបណ្តេញចេញ (ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ http://bit.ly/1bcHuqB

[170] សម្រាប់ព័ត៌មានជាក់លាក់ សូមមើលឧទាហរណ៍ ដូចខាងលើ។

[171] ច្បាប់ភូមិបាល មាត្រា ២៥៣

កិច្ច ឬក៏កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានរំលោភយកទ្រព្យជាអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាព បើទោះបីជា *"រំលោភសិទ្ធិ"* ឬតាមរយៈ *"បំពានអំណាច"*[172] ក៏ដោយ និងសម្រាប់អាជ្ញាធរមានសមត្ថកិច្ច *"ដែលព្រងើយកន្តើយ ឬបណ្តោយឲ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិករ របស់ភោគី ឬអ្នកកាន់កាប់ដោយសន្តិភាព"*។[173]

ថ្វីបើមានការការពារផ្នែកច្បាប់ ជីមានជម្លោះក្នុងប្រទេសកម្ពុជាតែងតែអមជាមួយនឹងអំពើហិង្សា។ មុនការបណ្តេញចេញ ក្រុមហ៊ុនតែងតែដាក់ពង្រាយកងកម្លាំងសន្តិសុខផ្ទាល់ខ្លួន ឬប្រើប្រាស់កងកម្លាំងសន្តិសុខរបស់រដ្ឋ ដើម្បីការពារដីសម្បទានរបស់គេ ដែលជាញឹកញយបាននាំឲ្យមានការគំរាមកំហែង និងការជំរិតទារប្រាក់ពីសហគមន៍មូលដ្ឋាន។ ប្រជាពលរដ្ឋនាំគ្នាតវ៉ាប្រឆាំងនឹងការបណ្តេញចេញ ហើយប្រឈមមុខជាមួយនឹងអាជ្ញាធរមានលក្ខណៈប្រឈមកាន់តែខ្លាំង ហើយកងកម្លាំងសន្តិសុខរដ្ឋ បានបង្កើនការប្រើប្រាស់កម្លាំងប្រឆាំងនឹងអ្នកតវ៉ាទាំងនោះ ហើយពេលខ្លះបណ្តាលឲ្យមានការស្លាប់។ ការបណ្តេញចេញដោយបង្ខំផ្ទាល់ ក៏តែងតែកើតឡើងដោយមានការប្រើប្រាស់កងកម្លាំងច្រើនហួសហេតុ។

> *"ការធ្វើបាតុកម្ម និងការប្រឆាំងតវ៉ា ដោយសហគមន៍រងគ្រោះ ក្នុងទីក្រុង និងតាមខេត្ត មានការកើនឡើង និងបានបណ្តាលឲ្យមានអំពើហិង្សាកាន់តែច្រើនទៅៗ" លោក សុរិយា ស៊ូប៊ែឌី តំណាងពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា*

ក្រុមហ៊ុនសមាជិកនៃ *ក្រុមចម្ការកៅស៊ូវៀតណាម* ដែលមានទីតាំងនៅកម្ពុជា បានរាយការណ៍ថាបានដាក់ទាហាន ឬកងរាជអាវុធហត្ថសម្រាប់ការពារដីសម្បទានរបស់ពួកគេ។ យោងតាមអង្គការអន្តរជាតិ គ្លូបិល វីតនេស ទាហាន ឬកងរាជអាវុធហត្ថ ធ្វើការយាមល្បាតតាមព្រំដែនរបស់ដីសម្បទាន និងកន្លែងផែកឈើ។ នៅដីសម្បទានមួយកន្លែង មានការរាយការណ៍ថា កងសន្តិសុខកាន់កាំភ្លើង អាកា ៤៧។[174] បន្ថែមពីលើនោះ ក្រុមហ៊ុនមួយដែលជាសមាជិករបស់ ក្រុមចម្ការកៅស៊ូវៀតណាម ក្រុមហ៊ុន*តាន បៀន ដាទៀងទាត់ ជាញឹកញាប់ប្រើប្រាស់អំពើហិង្សា ដើម្បីជម្លៀសពួកគេចេញពីដីដែលក្រុមហ៊ុនកាន់កាប់តាមរយៈដីសម្បទាន ក្នុងឆ្នាំ២០០៨។ អ្នកភូមិ រួមទាំងក្មេងស្រីជាច្រើន ត្រូវបានហាមឃាត់ វាយដំ ចាប់ឃុំ និងចាប់ឃាត់ខ្លួន។* មន្ត្រីកងកម្លាំងប្រដាប់អាវុធក្នុងមូលដ្ឋាន និងកងកម្លាំងសន្តិសុខ បានបិទផ្លូវចេញចូល ការពារមិនឲ្យអ្នកភូមិអាចទៅរកចំណីអាហារ សម្ភារៈប្រើប្រាស់ និងការផ្តល់ជំនួយផ្សេងៗ។ ក្នុងខែធ្នូ ឆ្នាំ២០០៩ តំណាងក្រុមហ៊ុន អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ បានបណ្តេញអ្នកភូមិចេញពីដីរបស់ពួកគេ ដោយប្រើកាំភ្លើងភ្ជង់។[175]

អ្វីដែលកាន់តែគួរឲ្យបារម្ភគឺការដាក់ពង្រាយកងកម្លាំងរក្សាសន្តិសុខរបស់រដ្ឋ ដើម្បីការពារដីសម្បទានជាលទ្ធផលបណ្តាលឲ្យកងកម្លាំងផ្ទាល់ខ្លួន ប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងចំនួនប្រជាពលរដ្ឋ។ ឧទាហរណ៍ក្នុងខេត្តឧត្តរមានជ័យ ក្រុមហ៊ុន *ស្ករអង្គរ ស្ករអំពៅទន្លេ,* និង *ខេន និងស៊ូហ្គាវ៉ាលេយ៍* ដែលបានជួលសេវារបស់

---

172 ដូចខាងលើ។, មាត្រា ២៦១ - ២៦២

173 ដូចខាងលើ។, មាត្រា ២៦៣

174 អង្គការគ្លូបិល វីតនេស «អភិជនកៅស៊ូ វិធីដែលក្រុមហ៊ុនវៀតណាម និងអ្នកហិរញ្ញវត្ថុអន្តរជាតិ បានដឹកនាំវិបត្តិដីធ្លីនៅក្នុងប្រទេសឡាវ និងកម្ពុជា» (ខែឧសភា ឆ្នាំ២០១៣), http://bit.ly/1ar7lKn

175 ដូចខាងលើ។

កងវរសេនាតូច លេខ ៤២ នៃកងយុទ្ធពលខេមរៈភូមិន្ទ ដើម្បីបិទផ្លូវ ដុតផ្ទះ និងឈូសឆាយ បំផ្លាញផ្ទះសម្បែង សម្លាប់សត្វចិញ្ចឹម និងវាយដំ គំរាម សម្លុត និងចាប់ខ្លួនអ្នកភូមិ។[176]

ព័ត៌មានស្តីពីការបាតុកម្មក្នុងករណីជម្លោះដីធ្លី នៅទីក្រុងភ្នំពេញ ឬនៅតាមខេត្ត បានក្លាយជាចំណង-ជើងធំនៅលើសារព័ត៌មានភាសាអង់គ្លេសជារៀងរាល់ថ្ងៃ។ ជាទូទៅ បាតុកម្មទាំងនោះបញ្ចប់ទៅដោយការប៉ះ-ទង្គិចជាមួយនគរបាល។ ឧទាហរណ៍ ក្នុងខែតុលា ឆ្នាំ២០១៣ ការប៉ះទង្គិចរវាងនគរបាល និងសកម្មជននៅបុរី-កីឡា បានបណ្តាលឲ្យស្រ្តី ៣ នាក់ ត្រូវសន្លប់បាត់ស្មារតី។[177]

អ្វីដែលកាន់តែធ្វើឲ្យព្រួយបារម្ភ គឺការកើនឡើងនៃការប្រើប្រាស់កងកម្លាំងហួតបណ្តាលឲ្យមានការស្លាប់បាត់បង់ជីវិត មកលើប្រជាពលរដ្ឋដែលបាតុកម្មប្រឆាំងនឹងការរើផ្ទះសម្បែង។ ក្នុងខែមករា ឆ្នាំ២០១២ មានភ្នាក់ងារសន្តិសុខប្រដាប់អាវុធ ដែលជួលដោយក្រុមហ៊ុន សាជីវកម្ម ធីធីវ៉ាយ ខូ អិលធីឌី ត្រូវបានចាប់ខ្លួនដោយសារសង្ស័យពីការប្រើប្រាស់ កាំភ្លើង អាកា៤៧ ដើម្បីបាញ់ទៅប្រជាពលរដ្ឋចំនួន ៤ នាក់ ដែលជាចំណែកមួយនៃអ្នកភូមិ ចំនួន ៤០០ នាក់ ធ្វើបាតុកម្មតវ៉ាប្រឆាំងនឹងការរំលោភយកដីដោយក្រុមហ៊ុននៅខេត្តក្រចេះ។[178] ក្នុងខែធ្នូ ឆ្នាំ២០១១ មន្រ្តីយោធាក្នុងខេត្តបាត់ដំបង ដែលបានធ្វើជាកងសន្តិសុខឲ្យក្រុមហ៊ុន *សួន-មានសម្បត្តិ* បានបាញ់មកលើក្រុមអ្នកភូមិ បណ្តាលឲ្យអ្នកភូមិចំនួន ៣ នាក់ រងរបួស។ ក្នុងខែកុម្ភៈ ឆ្នាំ២០១២ ក្នុងអំឡុង *ហេង ប្រាឌ័រ* ជាក្រុមហ៊ុនសាខា របស់ក្រុមហ៊ុនកៅស៊ូនៃប្រទេសវៀតណាម ក្នុងខេត្តរតនគិរី ដែលមានការរាយការណ៍ថា មន្រ្តីយោធាបានបាញ់ប្រហារមកលើអ្នកភូមិ។[179] ក្នុងខែឧសភា ឆ្នាំ២០១២ មានក្មេងស្រីម្នាក់ត្រូវបានបាញ់សម្លាប់ ក្នុងខេត្តក្រចេះ ដោយកងកម្លាំងរបស់រដ្ឋ ខណៈពេលដែលនាងកំពុងតែចូលរួមក្នុងការធ្វើបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនកៅស៊ូ។[180] ថ្មីៗនេះ កាលពីខែមីនា ឆ្នាំនេះ ក្នុងខេត្តកោះកុង ស្រុកស្មាច់មានជ័យ មន្រ្តីយោធា និងនគរបាល បានបាញ់ប្រហារមកលើអ្នកភូមិដែលតវ៉ាប្រឆាំងនឹងការបណ្តេញចេញ។[181]

ឧទាហរណ៍នៃករណីល្បីៗចំនួន ២ នៃការប្រើប្រាស់អំពើហិង្សាដោយហួសហេតុ ដើម្បីបណ្តេញប្រជាពលរដ្ឋ បានកើតឡើងក្នុងទីក្រុងភ្នំពេញ។ ករណីបុរីកីឡា និងបឹងកក់ ត្រូវបានចងក្រងទុកជាឯកសារយ៉ាងទូលំទូ-លាយ។ បុរីកីឡា គឺជាដីចំនួន ១៤.១២ ហិកតា ដែលមានទីតាំងនៅចំកណ្តាលទីក្រុងភ្នំពេញ ដែលកាលពីមុនមានប្រជាពលរដ្ឋចំនួន ១,៧៧៦ គ្រួសាររស់នៅ។ ក្នុង ឆ្នាំ២០០៣ ដីសម្បទានសង្គមកិច្ចចំនួន ៤.៦ ហិកតា

---

[176] អង្គការលីកាដូ និងអង្គការសមធម៌កម្ពុជា «ញត្តិស្តីពី សម្បទានស្ករត្រូវបានដាក់ទៅគណៈកម្មាការសិទ្ធិមនុស្សជាតិរបស់ប្រទេសថៃ អង្គការនៅកម្ពុជា បានចោទប្រកាន់ថាការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនស្ករសយក្ស សាជីវកម្មស្ករមិត្តផុល» (សេចក្តីថ្លែងការណ៍) (ភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣) http://bit.ly/1asDi57

[177] កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ «មន្រ្តីនគរបាលវាយដំមកលើសកម្មជនបុរីកីឡា» (ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣) http://bit.ly/16HM55V

[178] កាសែត ឌឹ ខេមបូឌា ដេលី «នគរបាលចាប់ខ្លួនអ្នកគ្រប់គ្រងក្រុមហ៊ុន ធីធីវ៉ាយ ពីបទបាញ់ប្រហារ» (ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២), http://bit.ly/1asDGR6; អង្គការលីកាដូ «មន្រ្តីយោធាបាញ់ប្រហារមកលើអ្នកតវ៉ាទាមទារដីធ្លី ក្នុងប៉ែកខាងជើងភាគខាងកើតនៃប្រទេសកម្ពុជា» (វីដេអូ) (ថ្ងៃទី២១ ខែមករា ឆ្នាំ២០១២), http://bit.ly/1asFWHS

[179] អង្គការគ្លូបិល វីតនេស «អភិជនកៅស៊ូ វិធីដែលក្រុមហ៊ុនវៀតណាម និងអ្នកហិរញ្ញវត្ថុអន្តរជាតិ បានដឹកនាំវិបត្តិដីធ្លីនៅក្នុងប្រទេសឡាវ និងកម្ពុជា» (ខែឧសភា ឆ្នាំ២០១៣), http://bit.ly/1ar7lKn

[180] ប៊ីប៊ីស៊ី «ក្មេងស្រីជំទង់ត្រូវបានបាញ់ស្លាប់ក្នុងពេលធ្វើការតវ៉ានៅកម្ពុជា» (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២), http://bbc.in/1asEipQ

[181] កាសែត ឌឹ ភ្នំពេញ ប៉ុស្តិ៍ «មានការបាញ់ប្រហារពេលដែលប្រជាពលរដ្ឋត្រូវបានជម្លៀស» (ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣), http://bit.ly/1asEFRi

ត្រូវបានផ្តល់ដោយរដ្ឋាភិបាល ទៅឲ្យ *ក្រុមហ៊ុន ផានអ៊ីមិច* (ផានអ៊ីមិច)។ ក្រោមកិច្ចសន្យានេះ ផានអ៊ីមិច ជាប់កិច្ចសន្យាត្រូវសាងសង់អាគារចំនួន ១០ នៅលើដី ២ ហិកតា សម្រាប់អត្ថប្រយោជន៍សង្គម គឺដើម្បីសម្រាប់ជាទីលំនៅរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បុរីកីឡា ដែលជាថ្នូរនឹងសិទ្ធិអភិវឌ្ឍន៍លើដីដែលនៅសល់ចំនួន ២.៦ ហិកតា ទៀត ដែលជាតំបន់ដីសម្បទាន។ ក្នុងខែមេសា ឆ្នាំ២០១០ បន្ទាប់ពីបានសាងសង់អាគារ ចំនួន ៨ ក្នុងចំណោម អាគារចំនួន ១០ *ផានអ៊ីមិច* បានស្នើសុំការអនុញ្ញាតពីរដ្ឋាភិបាលដើម្បីលើកលែងការសាងសង់អាគារចំនួន ២ ទៀត ដោយអះអាងថាខ្វះខាតថវិកាសម្រាប់សាងសង់ និងស្នើសុំយកដីដែលនៅសល់ពីការមិនសាងសង់អាគារចំនួន ២ នេះមកជារបស់ខ្លួន។ ការខកខានមិនបានសាងសង់អាគារចំនួន ២ ដែលនៅសល់ បានធ្វើឲ្យ ប្រជាពលរដ្ឋចំនួនចាប់ពី ៣០០ ទៅ ៤០០ គ្រួសារ ត្រូវរស់នៅដោយគ្មានទីលំនៅអចិន្ត្រៃយ៍។ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១២ មានប្រជាពលរដ្ឋជាច្រើនគ្រួសារដែលរស់នៅក្នុងតំបន់ បុរីកីឡា ត្រូវបានបណ្តេញទាំងហិង្សាចេញពីផ្ទះរបស់ពួកគេ ដោយកងកម្លាំងចម្រុះប្រហែលជា ១០០ នាក់ ដែលរួមមាន មន្ត្រីនគរបាល មន្ត្រីយោធា កងកម្លាំងសន្តិសុខ។ មានប្រជាពលរដ្ឋច្រើនជាង ២០០ គ្រួសារត្រូវបានកម្ទេច។ កងកម្លាំងរបស់រដ្ឋ ក៏បានប៉ះទង្គិចជាមួយនឹងសមាជិកសហគមន៍ផងដែរ។ មានសមាជិកមន្ត្រីនគរបាល និងសមាជិកសហគមន៍ បានរាយការណ៍ថារងរបួស ខណៈពេលដែលប្រជាពលរដ្ឋមួយចំនួនត្រូវបានចាប់ខ្លួន និងឃុំខ្លួន។[182] ការបណ្តេញចេញនេះ បានបណ្តាលឲ្យប្រជាពលរដ្ឋទាំងនោះ ជួបប្រទះនឹងវិបត្តិក្នុងតំបន់តាំងទីលំនៅថ្មី។[183]

ប្រជាពលរដ្ឋនៅតំបន់បឹងកក់ ត្រូវបានបណ្តេញចេញទាំងហិង្សា។[184] នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ មានកងកម្លាំងបង្ក្រាបកូដកម្មចំនួនប្រហែល ១០០ នាក់ និង កងសន្តិសុខ បានឡោមព័ទ្ធតំបន់ដែលមានប្រជាពលរដ្ឋរស់នៅនោះ។ មានម៉ាស៊ីនអេស្កាវ៉ាទ័រ ចំនួន ២ ការពារដោយកងកម្លាំងប្រដាប់អាវុធ បានចាប់ផ្តើមបំផ្លាញផ្ទះប្រជាពលរដ្ឋ។ រយៈពេលក្រោយមកក្នុងពេលរសៀល សកម្មជនឈ្មោះ សួង សុភ័ណ្ឌ ត្រូវបានវាយដំនឹងឥដ្ឋ និងដំបង ដោយក្រុមមន្ត្រីនគរបាល។[185]

តំបន់បុរីកីឡា និងបឹងកក់ ក៏ជាការបង្ហាញពីករណីបទល្មើសព្រហ្មទណ្ឌជាប្រព័ន្ធមកលើសកម្មជនសិទ្ធិដីធ្លីផងដែរ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ មានអ្នកតំណាងនៃសហគមន៍ដែលត្រូវបានបណ្តេញចេញចំនួន ១៣ នាក់ នៅក្នុងតំបន់បឹងកក់ ត្រូវបានចោទប្រកាន់ កាត់សេចក្តី ផ្តន្ទាទោស និងដាក់ពន្ធនាគារឲ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ដែលសកម្មភាពទាំងនេះកើតឡើងក្នុងរយៈពេលត្រឹមតែ ១ ថ្ងៃ ប៉ុណ្ណោះ។[186] ប្រហាក់ប្រហែលគ្នាដែរ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ យ៉ោម បុប្ផា ដែលជាសកម្មជននៅបឹងកក់ ត្រូវបាន

---

[182] អង្គការមេត្រា ១៩ «បុរីកីឡា ខ្សែវីដេអូដែលមិនមានការកែសម្រួល» (វីដេអូ), (ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២), http://bit.ly/16HGTis ; អង្គការលីកាដូ «បុរីកីឡា ការមិនគោរពកិច្ចសន្យា» (វីដេអូ), (ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣), http://bit.ly/1asHxO7

[183] ម.ស.ម.ក «សោកនាដកម្មនៅបុរីកីឡា នៅតែបន្ត» (ខែឧសភា ឆ្នាំ២០១២), http://bit.ly/17G2dbc

[184] មើលផ្នែក ៣.១.១ នៃរបាយការណ៍

[185] វិទ្យុអាស៊ីសេរី «ការបណ្តេញចេញនៅបឹងកក់ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ ៖ រឿងរ៉ាវរបស់វិទ្យុអាស៊ីសេរីនៅពីក្រោយរឿងរ៉ាវទាំងមូល» (វីដេអូ) (ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១) http://bit.ly/16HKddx, អង្គការលីកាដូ «សកម្មជនបឹងកក់ត្រូវបានក្រុមនគរបាលវាយដំយ៉ាងសាហាវ ក្នុងអំឡុងពេលការបណ្តេញចេញ» (វីដេអូ) (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១), http://bit.ly/16HKpJR

[186] ម.ស.ម.ក «ការវិភាគផ្នែកច្បាប់ស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោសមកលើ តំណាងសហគមន៍ បឹងកក់ ចំនួន ១៣នាក់ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២» (ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២), http://bit.ly/16HN5XP

ចាប់ខ្លួន និងចោទប្រកាន់ពីបទអំពើហិង្សាដោយចេតនា។[187] ក្រោយមកមានការចាប់ខ្លួន និងឃុំខ្លួន អ្នកស្រី ទឹម សាក់មុន្នី ដែលជាសកម្មជនសិទ្ធិដីធ្លីពីតំបន់សហគមន៍បុរីកីឡា ស្តីពីការផ្តល់ឯកសារមិនពិត។[188] ករណីមួយទៀតដែលអាចប្រើជាឧទាហរណ៍ គឺករណីចម្ការអំពៅនៅក្នុងខេត្តកំពង់ស្ពឺ ដែលមានសមាជិកសហគមន៍ប្រហែលជា ១៦ នាក់ ត្រូវបានកោះហៅទៅកាន់តុលាការខេត្តដើម្បីសាកសួរ និងមានប្រជាពលរដ្ឋមួយចំនួនត្រូវបានចោទប្រកាន់។ ថ្វីបើមានការដោះលែងពួកគេបន្ទាប់ពីការចាប់ខ្លួនបានមួយសប្តាហ៍ មានប្រជាពលរដ្ឋចំនួន ២ នាក់ ដែលត្រូវតម្រូវឲ្យបង្ហាញខ្លួននៅតុលាការរយៈពេល ២ ដង ក្នុងមួយខែ។[189]

### ៣.៣.៣. គ្មានចំណុចបញ្ចប់៖ គ្មានយន្តការដោះស្រាយជម្លោះ

មានយន្តការដោះស្រាយជម្លោះចំនួន ៥ នៅក្នុងកម្ពុជា ៖ ក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមប្រឹក្សារដ្ឋបាល គណៈកម្មការសុរិយោដី អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី និងតុលាការ។ ក្រុមប្រឹក្សារដ្ឋបាល ធ្វើប្រតិបត្តិការនៅពេលដែលមានជម្លោះកើតឡើងក្នុងដំណើរការចុះបញ្ជីដីធ្លី ប៉ុន្តែ មិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចដោយចាប់បង្ខំនោះទេ។ ប្រសិនបើក្រុមប្រឹក្សារដ្ឋបាល មិនអាចដោះស្រាយជម្លោះ ជម្លោះនឹងបន្តទៅគណៈកម្មការសុរិយោដី ដែលអាចត្រឹមតែធ្វើសវនាការសម្រាប់ជម្លោះដីធ្លីដែលមិនទាន់ត្រូវបានចុះបញ្ជីតែប៉ុណ្ណោះ។ ក្នុងករណីទាំងនោះ ប្រសិនបើមានជម្លោះដីធ្លីកើតឡើង ដំបូងឡើយ ត្រូវឆ្លងកាត់គណៈកម្មការសុរិយោដីថ្នាក់ស្រុក បន្ទាប់មក គណៈកម្មការសុរិយោដីថ្នាក់ខេត្ត និងចុងក្រោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលជាដំណោះស្រាយចុងក្រោយ។ ក្នុងករណីដែលមានការមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ការប្តឹងជំទាស់គួរតែបញ្ជូនទៅកាន់ប្រព័ន្ធតុលាការ។ ជម្លោះដែលពាក់ព័ន្ធនឹងដីដែលត្រូវបានចុះបញ្ជីរួចត្រូវតែធ្វើសវនាការដោយប្រព័ន្ធតុលាការដោយផ្ទាល់។ ចុងក្រោយ ក្នុង ឆ្នាំ២០០៦ អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។[190] ជាអកុសល តួនាទី អាណត្តិ និងមុខងាររបស់អាជ្ញាធរនេះ នៅតែគ្មានភាពច្បាស់លាស់ និងមានព័ត៌មានតិចតួចបំផុតអំពីដំណើរការដែលអាចឲ្យសាធារណជនប្រើប្រាស់បាន។

តាមការកត់សម្គាល់របស់តំណាងពិសេស *"ការងាររដ្ឋបាលដែលត្រូវចំណាយពេលច្រើន និងបន្ទុកផ្នែកដំណើរការ តម្លៃដែលពាក់ព័ន្ធនឹងការដាក់ពាក្យប្តឹង និងកង្វះជំនឿក្នុងប្រព័ន្ធតុលាការ បានបណ្តាលឲ្យមានការប្រើប្រាស់ប្រព័ន្ធនេះដោយមិនទៀងទាត់"* ។[191] អ្នកដាក់ពាក្យប្តឹង បានរាយការណ៍ថា សេចក្តីសម្រេចតែងតែមានពាក់ព័ន្ធនឹងការជ្រៀតជ្រែកផ្នែកនយោបាយ។ យោងតាម វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ចំនួនជម្លោះដីធ្លីដែលនៅមិនទាន់បានដោះស្រាយ មានការកើនឡើងជាបន្តបន្ទាប់។ រវាង ឆ្នាំ២០០៧ និង ឆ្នាំ

---

[187] ម.ស.ម.ក «ដោះលែង យ៉ោម បុប្ផា» (គេហទំព័រ), http://bit.ly/16HNKIK

[188] គណៈកម្មការសិទ្ធិមនុស្សអាស៊ី «សកម្មជនដីធ្លីចំនួន ២ នាក់ ត្រូវបានដាក់ពន្ធនាគារដោយសារតែមានការពាក់ព័ន្ធនឹងការធ្វើបាតុកម្មប្រឆាំងតវ៉ា» (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២), http://bit.ly/16HNn0T

[189] អង្គការសមធម៌កម្ពុជា «ភាពផ្អែមល្ហែមតែល្វីង សេចក្តីសង្ខេបពីផលិតផលនៃឧស្សាហកម្មស្ករ ពាណិជ្ជកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា» (ខែកញ្ញា ឆ្នាំ២០១០), http://bit.ly/1bcEUkw

[190] រាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី នស/រកត/០២០៦/០៩៧, (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦)

[191] លោក សុរិយា ប្រាសាទ ស៊ូប៊េឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីផ្សេងទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

២០១១ មានត្រឹមតែ ៣១% នៃជម្លោះដីធ្លីសរុបដែលបានឆ្លងកាត់ដំណើរការដោះស្រាយជម្លោះ ខណៈពេលដែលមាន ៥៧% ទៀត មិនដែលត្រូវបានឆ្លងកាត់ដំណើរការដោះស្រាយជាផ្លូវការណាមួយនោះទេ ថ្វីបើអ្នកដាក់ពាក្យប្តឹងបានលើកបញ្ហានេះទៅកាន់អាជ្ញាធរ ឬតុលាការក៏ដោយ។ បន្ថែមពីលើនោះ ក្នុងចំណោម ករណីចំនួន ៨៧ ដែលមានជម្លោះ ដែលបានចូលមកក្នុងដំណើរការដោះស្រាយជម្លោះ មានត្រឹមតែ ៤៦% ប៉ុណ្ណោះដែលត្រូវបានចងក្រងជាឯកសារថាត្រូវបានដោះស្រាយបានយ៉ាងពេញលេញ កាលពីខែវិច្ឆិកា ឆ្នាំ២០១១។[192]

កង្វះខាតនៃយន្តការដោះស្រាយជម្លោះដ៏មានប្រសិទ្ធភាព និងឯករាជ្យ និងការទទួលបានសំណង ក៏ត្រូវបានរងផលប៉ះពាល់ដោយការរីករាលដាលនៃនិទណ្ឌភាពផងដែរ[193] និងកង្វះឯករាជ្យភាពនៃប្រព័ន្ធតុលាការ។ អាជ្ញាធរផ្តល់ដីសម្បទានសេដ្ឋកិច្ចទាំងបំពាន និងរំលោភលើកម្មសិទ្ធិដីធ្លី និងសិទ្ធិទទួលបានលំនៅឋានសមស្របរបស់ប្រជាពលរដ្ឋ មន្ត្រីនគរបាលវាយដំមកលើអ្នកតវ៉ា និងកងកម្លាំងសន្តិសុខឯកជនប្លន់យកដំណាំ និងចាប់ជំរិតប្រជាពលរដ្ឋនៅតាមមូលដ្ឋាន មិនដែលត្រូវបានចាប់ខ្លួន ឬសូម្បីតែមានការស៊ើបអង្កេតនោះទេ។ វប្បធម៌និទណ្ឌភាព ធ្វើឲ្យជម្លោះនៅតែបន្តកើតមាន ដោយជនល្មើសដែលរំលោភសិទ្ធិមនុស្សមិនដែលត្រូវបានចាប់ខ្លួនឲ្យមកទទួលខុសត្រូវ ហើយការរំលោភបែបនេះនឹងនៅតែបន្តដោយគ្មានការស្រាកស្រាន្ត។

***ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង***[194]

ក្នុងខែសីហា ឆ្នាំ២០០៦ ដីសម្បទានសេដ្ឋកិច្ច ចំនួន ២ រួមគ្នា ត្រូវបានផ្តល់ទៅឲ្យ ក្រុមហ៊ុន *កោះកុង ផ្លែនជីស៊ិន ខូអិលធីឌី* និង *កោះកុងស៊ូហ្គាអ៊ិនដាស្ទ្រី ខូអិលធីឌី* ដោយមានដីប្រហែលជា ២០,០០០ ហិកតាក្នុងស្រុកបទុមសាគរ និងស្រុកស្រែអំបិល ក្នុងខេត្តកោះកុង។ ដីសម្បទានសេដ្ឋកិច្ច សម្រាប់ផលិតផលស្ករអំពៅ និងត្រូវបានផ្តល់ដោយគ្មានការពិគ្រោះយោបល់ពីសាធារណជន។

មានការរាយការណ៍ថា បុគ្គលិកក្រុមហ៊ុន និងកងកម្លាំងសន្តិសុខ បានសម្លាប់សត្វចិញ្ចឹម និងបំផ្លាញដំណាំ និងគំរាមកំហែងមកលើអ្នកភូមិ និងជំរិតយកប្រាក់ពីពួកគេ។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ កម្មករឈូសឆាយ និងមន្ត្រីយោធាប្រដាប់អាវុធបានមកដល់ និងបានបណ្តេញប្រជាពលរដ្ឋចំនួន ២៥០ គ្រួសារចេញដោយប្រើម៉ាស៊ីនឈូសកម្ទេច។ មិនមានការជូនដំណឹងជាមុនត្រូវបានធ្វើឡើងនោះទេ ហើយការបណ្តេញចេញនោះត្រូវបានធ្វើឡើងដោយគ្មានសេចក្តីបង្គាប់ពីតុលាការនោះទេ។ មន្ត្រីនគរបាល ក៏បានវាយប្រហារយ៉ាងឃោរឃៅមកលើអ្នកភូមិដែលប្រឆាំងនឹងការបណ្តេញចេញនោះផងដែរ។ មានប្រជាពលរដ្ឋចំនួន ៥ នាក់ រងរបួសបន្ទាប់ពីមានការវាយដំ ហើយមាន ២ នាក់ទៀត រងរបួសដោយសារតែការបាញ់កាំភ្លើងរបស់នគរបាល។ កាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០០៦ លោក អាន អ៊ីន សកម្មជនសហគមន៍ ត្រូវបានរកឃើញថាស្លាប់បាត់បង់ជីវិត ដោយសារ

---

[192] ការដាក់ស្នើរួម សម្រាប់ដំណើរការពិនិត្យជាសាកលតាមពេលវេលាកំណត់ លើកទី ២ ស្តីពី ប្រទេសកម្ពុជា (ខែមិថុនា ឆ្នាំ២០១៣), http://bit.ly/1bFGb5n

[193] ភីតទ័រ ឡឺប្រ៊ីច តំណាងពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា «ការបន្តវប្បធម៌និទណ្ឌភាពនៅកម្ពុជា» (ខែតុលា ឆ្នាំ២០០៩), http://bit.ly/1a7tba0

[194] ដើម្បីមើលករណីទាំងមូលសូមចូលទៅ ៖ អង្គការសមធម៌កម្ពុជា និងការអភិវឌ្ឍន៍អន្តរជាតិដែលមានលក្ខណៈរួមបញ្ចូល «ការប្រមូលផលដែលមានភាពផ្អែមល្ហែមតែល្វីង ៖ ការវាយតម្លៃផលប៉ះពាល់មកលើសិទ្ធិមនុស្ស របស់សហគមន៍អឺរ៉ុប មិនបានរកឃើញអ្វីក្រៅពី ការផ្តួចផ្តើមទិញអាវុធនៅកម្ពុជានោះទេ» (ឆ្នាំ២០១៣), http://bit.ly/17G5OpH

ការកាប់ចំនួន ៣ ពូថៅ ចំក្បាលរបស់លោក។ មិនមាននរណាទទួលខុសត្រូវចំពោះឃាតកម្មមកលើរូបលោកនោះទេ។

ប្រជាពលរដ្ឋ នៅស្រែអំបិល បានធ្វើការប្ដឹងទៅកាន់រដ្ឋាភិបាលជាច្រើនលើក ប៉ុន្តែមិនបានជោគជ័យ ពួកគេបញ្ជូនញត្តិទៅកាន់អាជ្ញាធរមូលដ្ឋាន រដ្ឋសភា នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រសួងផ្សេងៗជាច្រើន ប៉ុន្តែមិនមានវិធានការណាត្រូវបានធ្វើឡើងនោះទេ។ បន្ទាប់ពីរៀបចំធ្វើបាតុកម្ម តំណាងរបស់ក្រសួងមហាផ្ទៃ បានចូលមករកដំណោះស្រាយ ប៉ុន្តែអាជ្ញាធរ និងក្រុមហ៊ុនព្រងើយកន្តើយចំពោះការណែនាំរបស់ក្រសួង។ ប្រជាពលរដ្ឋក៏បានបន្តរឿងក្ដីរបស់គេទៅតុលាការកម្ពុជា។ អ្នកភូមិដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងព្រហ្មទណ្ឌប្រឆាំងនឹងក្រុមហ៊ុន។ តុលាការមិនបានចាត់វិធានការអ្វីមកលើការដាក់ពាក្យបណ្ដឹង អស់រយៈពេល ៥ ឆ្នាំ ហើយបន្ទាប់មកក៏ទម្លាក់បណ្ដឹងព្រហ្មទណ្ឌចោលមិនមានចំណាត់ការ។ ក្នុងឆ្នាំ២០១២ តុលាការបានបង្វែរបណ្ដឹងរដ្ឋប្បវេណី ទៅឲ្យគណៈកម្មាការសុរិយោដី ដោយព្រងើយកន្តើយនឹងផលវិបាកដែលប្រជាពលរដ្ឋបានជួបប្រទះដោយសារតែការផ្ដល់ដីសម្បទានបែបនេះ។

ដូចនឹងត្រូវពន្យល់ក្នុងជំពូកខាងក្រោម ការព្រងើយកន្តើយចំពោះច្បាប់ និងកិច្ចការពារប្រឆាំងនឹងការបណ្ដេញចេញ និងការរំលោភបំពានសិទ្ធិមនុស្សដែលរួមមកជាមួយ បានជះឥទ្ធិពលអាក្រក់យ៉ាងសម្បើមមកលើប្រជាពលរដ្ឋដែលរងគ្រោះ និងបរិស្ថាន។

# ៤. លទ្ធផល៖ ការវាយតម្លៃលើផលប៉ះពាល់នៃជម្លោះដីធ្លី

ថ្វីបើគ្មានភស្តុតាងជាក់ស្តែង ឬទិន្នន័យស្តីពីអត្ថប្រយោជន៍ នៃសម្បទានដីសេដ្ឋកិច្ច ត្រូវបានបោះពុម្ពផ្សាយជាសាធារណៈយ៉ាងណាក្តី រដ្ឋាភិបាលបានអះអាងថាសម្បទានដីសេដ្ឋកិច្ច ផ្តល់ផលវិជ្ជមានដល់ប្រទេសកម្ពុជា ដោយបានចូលរួមក្នុងការអភិវឌ្ឍន៍សំខាន់ៗក្នុងប្រទេស។ ផ្ទុយមកវិញ ឥទ្ធិពលអវិជ្ជមាននៃការបណ្តេញចេញ ដែលកើតឡើងជាញឹកញាប់ដោយសារតែការផ្តល់សម្បទានដី ត្រូវបានចងក្រងទុកជាឯកសារយ៉ាងច្រើននៅទូទាំងប្រទេស។ ជំពូកខាងក្រោម បង្ហាញពីទិដ្ឋភាពរួមនៃផលប៉ះពាល់ផ្នែកសង្គមនិងផ្នែកសេដ្ឋកិច្ច ដែលបណ្តាលមកពីជម្លោះដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋកម្ពុជា រួមទាំងផលប៉ះពាល់ជាក់លាក់ដែលកើតមានចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងសហគមន៍ក្រុមជនជាតិដើមភាគតិច។ ជំពូកនេះ រួមបញ្ចូលការពិភាក្សាសង្ខេបពីការបំផ្លាញបរិស្ថាន ដែលមិនអាចកែតម្រូវបាន ដែលកើតមានឡើងដោយសារតែជម្លោះដីធ្លី។

## ៤.១. ផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ចមកលើប្រជាពលរដ្ឋរងគ្រោះ

ការបណ្តេញចេញដោយបង្ខំតែងតែបណ្តាលឲ្យមានការរំលោភបំពានលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចជា ការរំលោភបំពានសិទ្ធិទទួលបានអាហារ ទឹក សុខភាព និងការអប់រំ ក៏ដូចជា ការរំលោភបំពានលើសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដូចជាសិទ្ធិសេរីភាពបញ្ចេញមតិ និងសិទ្ធិជួបប្រជុំជាដើម។ ផលប៉ះពាល់នៃការបណ្តេញចេញ មិនមែនប៉ះពាល់មកលើតែផ្ទះរបស់នរណាម្នាក់នោះទេ។ ជាញឹកញយ ការបណ្តេញចេញនេះនឹងបណ្តាលឲ្យមានកំណើនភាពក្រីក្រកើនឡើង ការទទួលបានប្រាក់ចំណូលមានកម្រិត បំណុល កង្វះទឹកស្អាតប្រើប្រាស់និងអនាម័យ និងជីវភាពរស់នៅប្រចាំថ្ងៃ បញ្ហាសុខភាពរាងកាយ និងសុខភាពផ្លូវចិត្ត ធ្វើឲ្យក្រុមគ្រួសារបែកបាក់ ការរើសអើងក្នុងសង្គម ភាពបែកបាក់សាមគ្គីក្នុងសហគមន៍ និងបន្តក្លាយជាជនដែលត្រូវបានគេចាត់ឲ្យនៅក្រៅសង្គម។ នៅចុងឆ្នាំ២០១២ និងដើមឆ្នាំ២០១៣ ម.ស.ម.ក បានរៀបចំការស្រាវជ្រាវដើម្បីប្រមូលព័ត៌មានស្តីពីផលប៉ះពាល់ផ្នែកសង្គមនិងសេដ្ឋកិច្ចនៃការបណ្តេញចេញដោយបង្ខំ។

***ការបណ្តេញចេញរបស់អ្នកភូមិសំបុកចាប និងការតាំងទីលំនៅថ្មីនៅភូមិអណ្តូង***

ភូមិអណ្តូង ក្នុងសង្កាត់គោករការ ខណ្ឌពោធិ៍សែនជ័យ មានទីតាំងនៅចម្ងាយប្រហែលជា ២៥ គីឡូម៉ែត្រពីភ្នំពេញ និងជាតំបន់តាំងទីលំនៅថ្មីមួយ ក្នុងចំណោមតំបន់ចំនួន ៥៤ នៅជុំវិញទីក្រុងភ្នំពេញ។ ក្នុងឆ្នាំ២០០៦ មានប្រជាពលរដ្ឋចំនួន ១,៥៥៤ គ្រួសារ ដែលត្រូវបានបណ្តេញចេញដោយអំពើហិង្សា ចេញពីផ្ទះរបស់ពួកគេនៅក្នុងភូមិសំបុកចាប ឃុំទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ដោយកងកម្លាំងនគរបាល និងមន្ត្រីយោធាប្រដាប់ដោយអាវុធ ឧស្ម័នបង្ហូរទឹកភ្នែក និងដំបងឆក់ ប្រជាពលរដ្ឋទាំងនោះត្រូវបានបង្ខំឲ្យឡើងឡានមួយហើយបញ្ជូនទៅរស់នៅក្នុងតំបន់អណ្តូង។ ប្រជាពលរដ្ឋដែលត្រូវបានជម្លៀសមកតំបន់ភូមិអណ្តូង មិនទាន់ត្រូវ

បានផ្តល់ប័ណ្ណកម្មសិទ្ធិនៅឡើយទេ ថ្វីបើមានការសន្យាជាបន្តបន្ទាប់ពីសំណាក់អាជ្ញាធរក៏ដោយ។[195] ប្រជាពលរដ្ឋតិចជាង ៥០០គ្រួសារ ត្រូវបានគេផ្តល់ប័ណ្ណកម្មសិទ្ធិឲ្យកាន់កាប់ដីជាផ្លូវការនៅតំបន់តាំងទីលំនៅថ្មីនោះ។[196]

នៅពេលនោះ តំបន់ភូមិអណ្តូងគឺគ្រាន់តែជាវាលស្រែល្ហល្ហេវ និងពោរពេញដោយទឹកជំនន់ ហើយក្រុមគ្រួសារដែលបានរើមកនៅកន្លែងនេះ មិនអាចមានលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលអាចអនុញ្ញាតឲ្យពួកគេបង្កើតជីវភាពរបស់ពួកគេសាជាថ្មីនោះទេ។ បើតាមអង្គការលើកលែងទោសអន្តរជាតិបានរៀបរាប់នោះ ប្រជាពលរដ្ឋដែលត្រូវបានជម្លៀសគឺ *"គ្មានជម្រក គ្មានប្រព័ន្ធលូ គ្មានការផ្គត់ផ្គង់ទឹកស្អាត គ្មានអគ្គិសនី គ្មានផ្លូវថ្នល់ គ្មានសាលារៀន គ្មានមន្ទីរព្យាបាល និងគ្មានផ្សារ"* ។[197] ដោយគ្មានជម្រើស ប្រជាពលរដ្ឋដែលត្រូវបានជម្លៀសមក ក៏សាងសង់នូវជម្រកសាមញ្ញសម្រាប់រស់នៅ ហើយពួកគេកំពុងតែរស់នៅក្នុងទឹកកង្វក់ដែលមានជម្រៅត្រឹមកែងជើង។ មកដល់ថ្ងៃនេះ គ្រួសារដែលរស់នៅក្នុងភូមិអណ្តូង កំពុងតែប្រឈមនឹងបញ្ហាសុខភាពជាច្រើន រួមទាំង កង្វះអាហារូបត្ថម្ភ គ្រុនពោះវៀន គ្រុនឈាម ដំបៅបំពង់ដង្ហើម និង ជំងឺពោះវៀនតូច និងបញ្ហាសុខភាពផ្លូវចិត្ត ដូចជា ភាពតឹងតែង និងបញ្ហាក្នុងការគ្រប់គ្រងការខឹងសម្បារ។

ការរំលូតកូនកើតមានជាច្រើន ការថែទាំមុនពេលសម្រាលសម្រាប់ស្ត្រីមានផ្ទៃពោះគឺមានតិចតួច ឬក៏គ្មានសោះ ហើយតែងតែសម្រាលកូនក្នុងតំបន់ភូមិអណ្តូងនោះតែម្តង ដោយសារតែពួកគេមិនអាចមានលទ្ធភាពចំណាយលើថ្លៃធ្វើដំណើរទៅមន្ទីរពេទ្យ។ កុមារតូច តែងតែឆ្លងជំងឺដែលងាយព្យាបាលបំផុត ដូចជា ជំងឺហើមសួត ជំងឺរលាកទងសួត ជំងឺរបេង ជំងឺរាគរូស រាគមួល កង្វះអាហារូបត្ថម្ភ និងជំងឺសើស្បែក។[198]

ក្នុងខែមីនា ឆ្នាំ២០១៣ ម.ស.ម.ក បានសម្ភាសន៍ប្រជាពលរដ្ឋចំនួន ២៣ នាក់ ដែលត្រូវបានជម្លៀសចេញពីភូមិសំបុកចាប ទៅតំបន់អណ្តូង។ បញ្ហាសំខាន់មួយត្រូវបានលើកឡើង គឺការថយចុះនៃប្រាក់ចំណូលបន្ទាប់ពីការដូរទីតាំងថ្មីទៅតំបន់អណ្តូង ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមសម្រាប់ប្រជាពលរដ្ឋដែលត្រូវបានជម្លៀស ធ្លាក់ចុះពី ៥.៧៨ដុល្លារ ទៅ ៣.២៤ដុល្លារ។ ការធ្លាក់ចុះនៃប្រាក់ចំណូល បូកផ្សំជាមួយនឹងប្រាក់ចំណាយថ្លៃធ្វើដំណើរខ្ពស់ ដោយសារតែភាពដាច់ស្រយាលរបស់តំបន់តាំងទីលំនៅថ្មី។ បន្ថែមពីលើនោះ ប្រជាពលរដ្ឋដែលម.ស.ម.កបានសម្ភាសន៍ជាមួយនោះ បានរាយការណ៍ថាអំពីការកើនឡើងដ៏គួរឲ្យកត់សម្គាល់នូវបញ្ហាសុខភាពខាងរាងកាយ និងសុខភាពខាងផ្លូវចិត្ត ដែលរួមមាន ជំងឺគេងមិនលក់ រោគសញ្ញានៃជំងឺកកឈាម ការបាត់បង់ការចងចាំ និងជំងឺធុញថប់អារម្មណ៍(ស្ត្រេស)។ ជាមួយនឹងការធ្លាក់ចុះនៃប្រាក់ចំណូលរបស់ពួកគេ ប្រជាពលរដ្ឋជាច្រើនមិនអាចមានលទ្ធភាពចំណាយលើការព្យាបាល ដែលការចំណាយទាំងនោះភាគច្រើន ច្រើន

---

[195] ម.ស.ម.ក «ការប្រឈមនឹងការបណ្តេញចេញដោយបង្ខំជាលើកទី ២ របស់សហគមន៍ ភូមិអណ្តូងដោយគ្មានសំណង គឺជាការមើលស្រាលរបស់រដ្ឋាភិបាលចំពោះសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស» (វិចារណកថាព័ត៌មាន)(ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២) www.cchrcambodia.org/media/files/press_release/294_210mcafee_en.pdf

[196] អង្គការលីកាដូ «២ ឆ្នាំបន្ទាប់ពីការបណ្តេញចេញរបស់ពួកគេចេញពីកណ្តាលទីក្រុងភ្នំពេញ ប្រជាពលរដ្ឋនៅតែរស់នៅក្នុងទុគ៌តភាព» (ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨) http://bit.ly/1athCWm

[197] អង្គការលើកលែងទោសអន្តរជាតិ «កម្ពុជា ៖ ការអភិវឌ្ឍន៍ទីប្រជុំជន ឬក៏ការរៀបចំសំណង់អានាធិបតេយ្យ?» (ខែឧសភា ឆ្នាំ២០០៩) http://bit.ly/17GoXYr

[198] អង្គការលីកាដូ «២ ឆ្នាំបន្ទាប់ពីការបណ្តេញចេញរបស់ពួកគេចេញពីកណ្តាលទីក្រុងភ្នំពេញ ប្រជាពលរដ្ឋនៅតែរស់នៅក្នុងទុគ៌តភាព» (ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨) http://bit.ly/1athCWm

ជាងប្រាក់ចំណូលរបស់ពួកគេ។ សម្រាប់ប្រជាពលរដ្ឋដែលមានលទ្ធភាពចំណាយលើការព្យាបាល ក៏ចុងបញ្ចប់ត្រូវប្រឈមនឹងការចំណាយខ្ពស់ដោយសារតែតំបន់តាំងទីលំនៅនោះនៅដាច់ស្រយាល ធ្វើឲ្យថ្លៃធ្វើដំណើរទៅកាន់មណ្ឌលសុខភាពមានតម្លៃខ្ពស់ ជាពិសេសសម្រាប់អ្នកមានជំងឺឈឺរ៉ាំរ៉ៃ ដែលតម្រូវឲ្យមានពិគ្រោះជំងឺជាទៀងទាត់ ជាមួយនឹងអ្នកជំនាញផ្នែកសុខភាព ។

បញ្ហាផ្នែកសង្គមសេដ្ឋកិច្ច ដែលអ្នករស់នៅក្នុងតំបន់អណ្តូងត្រូវជួបប្រទះ មិនមែនជារឿងខុសប្លែកពីករណីដទៃនោះទេ។ នៅទូទាំងប្រទេស ជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ ដែលម.ស.ម.ក បានសម្ភាសន៍ជាមួយ បានបង្ហាញពីបញ្ហាដដែលនេះ និងផលប៉ះពាល់ប្រហាក់ប្រហែលគ្នាដោយសារតែការរំលោភលើសិទ្ធិរបស់ពួកគេ។ ក្នុងភូមិឈូក ឃុំជីខលើ ស្រុកស្រែអំបិល ក្នុងខេត្តកោះកុង[199] ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំ របស់ជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ ធ្លាក់ចុះពី ១,០៨៣.៨២ ដុល្លារ ទៅ ៤៨៤.៩២ ដុល្លារ ហើយក្នុងភូមិព្រែកជីក ឃុំជីខក្រោម ស្រុកស្រែអំបិល នៃខេត្តកោះកុង ប្រាក់ចំណូលប្រចាំឆ្នាំធ្លាក់ចុះពី ២,០៧០.៣១ ដុល្លារ ទៅ ៣១៥.៨៩ ដុល្លារ។ ចំណែកប្រជាពលរដ្ឋរស់នៅក្នុងតំបន់អណ្តូង ប្រាក់ចំណូលដែលធ្លាក់ចុះយ៉ាងច្រើន ក្នុងសហគមន៍ទាំងនេះ បានប៉ះពាល់ជាខ្លាំងមកលើលទ្ធភាពនៃការទទួលបានសេវាថែទាំសុខភាព ដែលអាចបណ្តាលឲ្យពួកគាត់ប្រឈមនឹងកង្វះអាហារូបត្ថម្ភ និងបញ្ហាជាច្រើន។

ជម្លោះដីធ្លី ក៏បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើប្រភេទ និងគុណភាពនៃឱកាសការងារសម្រាប់ជនរងគ្រោះ នៃការរំលោភយកដីផងដែរ។ ប្រជាពលរដ្ឋដែលត្រូវបានជម្លៀសជាច្រើន ដែល ម.ស.ម.ក សម្ភាសន៍ ធ្លាប់មានមុខជំនួញរបស់ខ្លួនមុនពេលការបណ្តេញចេញ ដូចជាការដាំដំណាំនៅលើដីរបស់ពួកគេ។ ប៉ុន្តែ ការរំលោភយកដី មានន័យថា ដីដែលពួកគេធ្លាប់ដាំដំណាំនៅលើនោះ គឺត្រូវបាត់បង់ទាំងស្រុង ឬក៏ត្រូវរួមតូចដោយសារតែការរំលោភយកដីពីការសម្បទានដី ដែលនោះធ្វើឲ្យពួកគេមិនអាចផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ពួកគេបានទៀតនោះទេ។ ជាលទ្ធផល ប្រជាពលរដ្ឋជាច្រើនដែលត្រូវបានសម្ភាសន៍ជាមួយ បានប្រាប់អំពីការដែលត្រូវបានបង្ខំឲ្យធ្វើការងារដែលគ្មានជំនាញ ឬប្រើកម្លាំង ក្នុងករណីខ្លះ ពួកគេត្រូវទៅរស់នៅឆ្ងាយពីក្រុមគ្រួសាររបស់គេ ដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគេ។ សម្រាប់ប្រជាពលរដ្ឋជាច្រើន ការផ្លាស់ប្តូរបែបនេះគឺបណ្តាលមកពីប្រាក់ចំណូលធ្លាក់ចុះដោយផ្ទាល់។

## ៤.២. ផលប៉ះពាល់មកលើស្ត្រី និងកុមារ

ទោះបីជាដីមានសារៈសំខាន់ជាខ្លាំងសម្រាប់ពលរដ្ឋទាំងបុរសនិងស្ត្រីនៅក្នុងកម្ពុជា ប៉ុន្តែស្ត្រីដែលជាអ្នកថែរក្សាផ្ទះសម្បែង គឺជាក្រុមមួយដែលងាយរងគ្រោះក្នុងបរិបទនៃសិទ្ធិដីធ្លី និងផ្ទះសម្បែង ហើយដែលទទួលផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែការកើនឡើងនៃការរំលោភយកដីនៅកម្ពុជា។ រដ្ឋមនុញ្ញធានាសិទ្ធិស្មើភាពគ្នាក្នុងការកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិសម្រាប់ស្ត្រី សិទ្ធិទាំងនោះក៏បានធានានៅក្នុងបទដ្ឋាននិងច្បាប់សិទ្ធិមនុស្សអន្តរជាតិផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែប្រឈមមុខនឹងការលំបាកជាច្រើន ពាក់ព័ន្ធនឹងការចុះបញ្ជី និងប័ណ្ណកម្មសិទ្ធិ បណ្តាលឲ្យមានកំណើននៃអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងធ្វើឲ្យពួក

[199] មើលករណីសិក្សា ក្នុង ផ្នែក ៣.៣.៣ នៃរបាយការណ៍

គេកាន់តែងាយរងគ្រោះដោយសារសម្បទានដីសេដ្ឋកិច្ចដែលបានប៉ះពាល់ដល់ដីរបស់ពួកគេ។[200] ដូចបានកត់សម្គាល់ក្នុងរបាយការណ៍ អាក់ស្ទិនអេដ (ActionAid) ក្នុងខែតុលា ឆ្នាំ២០១២ ៖

> *"អសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីរបស់ស្ត្រី [នៅកម្ពុជា] គឺអាចបណ្តាលមកពីហេតុផលចំនួន ៣ ៖ ភាពក្រីក្រ និងភាពគ្មានដីធ្លីបានកាត់បន្ថយសិទ្ធិដីធ្លីរបស់ស្ត្រី ការអនុវត្តន៍តាមបែបប្រពៃណីនិងវប្បធម៌ ដែលមានន័យថាសិទ្ធិដីធ្លីរបស់ស្ត្រីគឺមិនសូវសំខាន់ក្នុងគ្រួសារ ហើយស្ត្រីខ្លួនឯងមិនដឹងពីសិទ្ធិរបស់ខ្លួន។"*[201]

ភាពងាយរងគ្រោះបន្ថែមទៀតពីការរំលោភយកដី គឺថាស្ត្រីភាគច្រើនតែងតែងាយរងគ្រោះដោយសារតែផលវិបាកនៃការរំលោភយកដីផងដែរ។ ក្នុងឆ្នាំ២០១៣ ការស្រាវជ្រាវដែលធ្វើឡើងដោយអង្គការស្ត្រីខ្មែរ បានរកឃើញថា ស្ត្រីបានឆ្លងកាត់នូវជីវភាពដ៏អាក្រក់បំផុតដោយសារតែការបណ្តេញចេញដោយបង្ខំ។[202] បន្ទាប់ពីការបណ្តេញចេញ ពួកគេភាគច្រើនបាត់បង់មធ្យោបាយក្នុងការរស់នៅ ជាពិសេសសក្នុងតំបន់ជនបទ។ ក្នុងតំបន់តាំងទីលំនៅថ្មី ពួកគេមិនអាចរួមចំណែកដើម្បីជួយទ្រទ្រង់គ្រួសារនោះទេ ដែលនេះប៉ះពាល់ដល់សុខមាលភាពគ្រួសារទាំងមូល បណ្តាលឲ្យគេភ័យខ្លាចអំពីអនាគតរបស់ពួកគេ។ ស្ត្រីជាច្រើន ដែលត្រូវបានជម្លៀសទៅនៅតំបន់ដាច់ស្រយាលឆ្ងាយពីទីក្រុង ត្រូវបានទុកឲ្យនៅម្នាក់ឯង ដើម្បីមើលថែទាំកូន ដោយសារតែស្វាមីនិងសាច់ញាតិរបស់ពួកគេត្រូវទៅក្នុងទីក្រុងដើម្បីស្វែងរកការងារ។[203] ជាលទ្ធផល មានការរាយការណ៍ពី ករណីជាច្រើនដែលប្រជាពលរដ្ឋមានជំងឺដូចជា ការខ្វល់ខ្វាយជាទូទៅ ការខ្វល់ខ្វាយដែលកើតមានក្រោយពីជំងឺស្រ្តេស និងភាពតានតឹង។[204]

ផលប៉ះពាល់មកលើស្ត្រី គឺមានលក្ខណៈខុសគ្នារវាងស្ត្រីនៅជនបទ និងស្ត្រីនៅទីក្រុង។ ស្ត្រីជាច្រើនដែលមកពីសហគមន៍ទីក្រុង ដែលកំពុងតែប្រឈមមុខនឹងការបាត់បង់ដីដែលពួកគេរស់នៅ ការចំណាយប្រចាំខែរបស់គេក៏កើនឡើងជាច្រើន ដោយសារតែគេត្រូវបានបង្ខំចិត្តឲ្យជួលលំនៅដ្ឋានបណ្តោះអាសន្ន ឬក៏ចំណាយលើថ្លៃធ្វើដំណើរ នៅពេលដែលពួកគេធ្វើដំណើរពីតំបន់ទីតាំងលំនៅថ្មីទៅទីក្រុង ហើយដែលតំបន់តាំងទីលំនៅថ្មីនោះនៅតំបន់ជាយក្រុង។ តំបន់តាំងទីលំនៅថ្មី តែងតែនៅដាច់ស្រយាល ដែលធ្វើឲ្យស្ត្រីពិបាកក្នុងការរកការងារធ្វើ និងត្រូវតែទៅទីក្រុងភ្នំពេញដើម្បីស្វែងរកការងារ។ ម្យ៉ាងវិញទៀត ស្ត្រីមកពីសហគមន៍ជនបទ អាចផ្គត់ផ្គង់ជីវភាពរបស់ពួកគេដោយសារតែការធ្វើជាកសិករ និងដឹងថាពួកគេមានជំនាញនិងឱកាសការងារមានក

---

[200] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[201] អាកស្ទិនអេដ «កន្លែងទំនេរលើដី ៖ អភិវឌ្ឍការគ្រប់គ្រងដីធ្លីដើម្បីបញ្ឈប់ការរំលោភយកដី» http://bit.ly/17Gk0yM

[202] អង្គការស្ត្រីខ្មែរ «ពួកគេយកដីរបស់ខ្ញុំ ពួកគេបំផ្លាញជីវិតខ្ញុំ ៖ របាយការណ៍ស្តីពីផលប៉ះពាល់ផ្នែកចិត្តសាស្ត្រមកលើស្ត្រីដែលរងគ្រោះដោយសារការបណ្តេញចេញនៅកម្ពុជា» (ខែកុម្ភៈ ឆ្នាំ២០១៣), http://bit.ly/17GkqFD

[203] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[204] ដូចខាងលើ។

ម្រិត។ នៅពេលដែលពួកគេបាត់បង់ដីធ្លី ពួកគេមិនអាចទទួលបានប្រាក់ចំណូលបន្តទៀតនោះទេ ជាលទ្ធផលធ្វើឲ្យមានបំណុលជាច្រើន និងមិនអាចមានលទ្ធភាពចិញ្ចឹមកូន និងចំណាយសម្រាប់សេវាកម្មធម្មតាៗ។[205]

### *ហុយ ម៉ៃ និង ខេត្តឧត្តរមានជ័យ*[206]

ក្រុមគ្រួសាររបស់ ហុយ ម៉ៃ និង ១១៨ គ្រួសារទៀត ក្នុងភូមិបុស្ស ខេត្តឧត្តរមានជ័យ ត្រូវបានបណ្តេញចេញដោយបង្ខំ ក្នុងខែតុលា ឆ្នាំ២០០៩ ជាផ្នែកមួយនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចឲ្យទៅក្រុមហ៊ុន *ស្ករអង្គរ*។ ផ្ទះរបស់ពួកគេត្រូវបានដុតចោល ហើយពួកគេបាត់បង់ទ្រព្យសម្បត្តិ និងដីចម្ការ។ ថ្វីបើមានការសន្យា ថាអ្នកស្រីនឹងទទួលបានដីមួយកន្លែងទៀត ប៉ុន្តែអ្នកស្រីមិនបានទទួលទាំងដី និងប្រាក់សំណង ធ្វើឲ្យអ្នកស្រី និងកូនៗត្រូវរស់នៅទាំងគ្មានទីជម្រក និងទីទាល់ក្រ។ ហុយ ម៉ៃ ដែលពេលនោះមានផ្ទៃពោះចំនួន ៥ខែ ត្រូវបានចោទប្រកាន់ពីបទរំលោភលើដីព្រៃ និងត្រូវបានចាប់ដាក់ពន្ធនាគារចំនួន ៨ ខែ បន្ទាប់ពីព្យាយាមដាក់ពាក្យបណ្តឹងជំទាស់ទៅកាន់អាជ្ញាធរនៅទីក្រុងភ្នំពេញ។

អ្នកស្រីបានសម្រាលបុត្រនៅក្នុងពន្ធនាគារ ដែលអ្នកស្រីត្រូវបង្ខំឲ្យនៅទីនោះរយៈពេល ២ យប់ និង ៣ ថ្ងៃ មុនពេលនាំយកទៅមន្ទីរពេទ្យ។ រយៈពេល ២ ឬ ៣ ម៉ោង ក្រោយពីអ្នកស្រីសម្រាលកូន អ្នកស្រីត្រូវបាននាំត្រលប់ទៅកាន់ពន្ធនាគារវិញ។ រយៈពេល ២ ខែ អ្នកស្រីចិញ្ចឹមកូនប្រុសរបស់អ្នកស្រីនៅក្នុងគុក ដោយរស់នៅក្នុងស្ថានភាពដែលខ្វះអនាម័យ និងរស់នៅក្នុងជញ្ជាំងគុកជាមួយស្ត្រីចំនួន ៧ នាក់ទៀត។ រយៈពេល ៨ ខែ បន្ទាប់ពីការឃុំខ្លួនរបស់អ្នកស្រី អ្នកស្រីម៉ៃ ត្រូវបាននាំទៅតុលាការដើម្បីបើកសវនាការ។ ប៉ុន្តែ ជំនួសឲ្យការបើកសវនាការដោយយុត្តិធម៌ តុលាការបានប្រាប់អ្នកស្រីថា អ្នកស្រីនឹងត្រូវបានដោះលែងប្រសិនបើព្រមចុះហត្ថលេខាលើកិច្ចសន្យា យល់ព្រមលុបចោលការអះអាងទាមទារកម្មសិទ្ធិលើដីក្នុងភូមិបុស្ស និងទទួលយកដីដែលត្រូវបានផ្តល់ឲ្យជំនួសវិញ។

ស្ត្រីក៏តែងតែងាយរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារផងដែរ[207] និងអំពើហិង្សាផ្អែកលើយេនឌ័រ ទាំងនៅក្នុងបរិបទការបណ្តេញចេញដោយបង្ខំ និងករណីទូទៅ។ ក្នុងខែតុលា ឆ្នាំ២០០៩ សេចក្តីសង្ខេបបញ្ហារបស់ មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅដ្ឋាននិងការបណ្តេញចេញ បានកត់សម្គាល់ថាការស្រាវជ្រាវបាន "*បង្ហាញជារឿយៗថា ស្ត្រីដែលប្រឈមមុខនឹងអំពើហិង្សាបន្ថែមនៅក្នុងផ្ទះ ក្នុងបរិបទនៃលក្ខខណ្ឌនៃការរស់នៅដ៏តានតឹង និងផលប៉ះពាល់ផ្នែកចិត្តសាស្ត្រដែលការបណ្តេញចេញមានមកលើសមាជិកគ្រួសារ ដែលយូរៗទៅនឹងបណ្តាលឲ្យមានការរំលោភបំពានជាញឹកញាប់ និងការផ្តាច់ខ្លួនចេញពីសង្គម។*" [208] សុវត្ថិភាពក្នុងតំបន់តាំងទី

---

[205] អង្គការស្ត្រីខ្មែរ «ពួកគេយកដីរបស់ខ្ញុំ ពួកគេបំផ្លាញជីវិតខ្ញុំ៖ របាយការណ៍ស្តីពីផលប៉ះពាល់ផ្នែកចិត្តសាស្ត្រមកលើស្ត្រីដែលរងគ្រោះដោយសារការបណ្តេញចេញនៅកម្ពុជា» (ខែកុម្ភៈ ឆ្នាំ២០១៣), http://bit.ly/17GkqFD

[206] អង្គការលើកលែងទោសអន្តរជាតិ «ការបណ្តេញចេញ និងការតស៊ូនៅកម្ពុជា ៖ ស្ត្រី ៥ នាក់ បានរៀបរាប់ពីជីវិតរបស់ពួកគេ» (ខែវិច្ឆិកា ឆ្នាំ២០១១), http://bit.ly/17GlPfp

[207] មជ្ឈមណ្ឌលសិទ្ធិលំនៅឋាន និងការបណ្តេញចេញ «រស់នៅក្រោមការគំរាមកំហែង ប៉ុន្តែមិនមានកន្លែងណាផ្សេងដែលត្រូវទៅ ៖ ការស្រាវជ្រាវស្តីពីផលប៉ះពាល់ពីការបណ្តេញចេញមកលើស្ត្រីនៅភ្នំពេញ» (ខែវិច្ឆិកា ឆ្នាំ២០១១), http://bit.ly/17GkBk6

[208] មជ្ឈមណ្ឌលសិទ្ធិលំនៅឋាន និងការបណ្តេញចេញ «ស្ត្រី និងសិទ្ធិលំនៅឋាន» (សង្ខេបបញ្ហា) (ឆ្នាំ២០០៩) www.cohre.org/sites/default/files/issue_brief_1_forced_eviction.pdf

លំនៅថ្មី ក៏ជាបញ្ហាសម្រាប់ស្ត្រីផងដែរ ដូចជា ចោរប្លន់ និងអំពើហិង្សាផ្លូវភេទ រួមទាំង ការចាប់រំលោភ គឺជារឿងធម្មតា រួមទាំងបង្កឡើងដោយកម្មករដែលធ្វើការឲ្យក្រុមហ៊ុនដែលទទួលបានដីសម្បទានផងដែរ។

ការបណ្តេញចេញដោយបង្ខំ ក៏មានផលប៉ះពាល់សំខាន់មកលើកុមារផងដែរ។ នៅពេលដែលគ្រួសារត្រូវបានជម្លៀសទៅកន្លែងតាំងទីលំនៅថ្មី កុមារតែងតែត្រូវបង្ខំឲ្យចាកចេញពីសាលារៀន ឬក៏ក្រុមគ្រួសារត្រូវរស់នៅបែកបាក់គ្នា ដើម្បីអាចឲ្យកូនៗរបស់ពួកគេឲ្យនៅកន្លែងដែលត្រូវបានជម្លៀស ដើម្បីឲ្យពួកកូនៗអាចបញ្ចប់ឆ្នាំសិក្សា។ ក្នុងករណីខ្លះ គ្រួសារត្រូវតែចំណាយប្រាក់ដើម្បីផ្ទេរកូនឲ្យទៅសាលាផ្សេង ដែលផ្តល់ផលប៉ះពាល់បន្ថែមទៀតលើស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ។[209] ពលកម្មកុមារក៏ជាបញ្ហាធំផងដែរ ៖ កុមារខ្លះអាចនឹងត្រូវឲ្យឈប់រៀន ដើម្បីធ្វើការ និងស្វែងរកប្រាក់ដើម្បីក្រុមគ្រួសារបន្ទាប់ពីការបណ្តេញចេញ ដោយសារតែគ្រួសារទាំងនោះ តែងតែមិនអាចសងបំណុលដែលពួកគេជំពាក់។[210] ឧទាហរណ៍ មន្ត្រីគម្រោងរបស់ ម.ស.ម.ក បានជួបជាមួយនឹង ទូច ភារ៉ា ដែលមានអាយុ ១០ឆ្នាំ កាលពីខែមករា ឆ្នាំ២០១៣ នៅភូមិពីស ឃុំអមលាំង ស្រុកថ្ពងក្នុងខេត្តកំពង់ស្ពឺ។ ទូច ភារ៉ា បានឈប់រៀនត្រឹមថ្នាក់ទី ២ ហើយចាប់ផ្តើមធ្វើការកាប់ដើមអំពៅនៅក្នុងក្រុមហ៊ុន *ស្ករភ្នំពេញ* របស់ចម្ការ លី យ៉ុងផាត់ បន្ទាប់ពីក្រុមគ្រួសាររបស់គេ ត្រូវបានជម្លៀស។ គេធ្វើការជិត ១០ម៉ោងក្នុងមួយថ្ងៃ ហើយទទួលបានប្រាក់ត្រឹមតែ ៧០០០ រៀល (ប្រហែល ១.៧៥ ដុល្លារ)។ គេបានចាប់ផ្តើមធ្វើការដោយសារតែក្រុមគ្រួសាររបស់គេ ខ្វះខាតដីចម្ការនៅតំបន់តាំងលំនៅថ្មី។ ជាទូទៅកុមារៗ តែងតែរងគ្រោះដោយសារតែការបែកបាក់គ្រួសារ។

រយៈពេលជាច្រើនឆ្នាំមកនេះ ការបណ្តេញចេញបានជះឥទ្ធិពលអាក្រក់មកលើសុខមាលភាពរបស់ស្ត្រីដែលបណ្តាលឲ្យមានសកម្មភាពសកម្មនិយម ដែលស្ត្រីទៅឈរនៅជួរមុខ ដើម្បីធ្វើការតវ៉ា និងធ្វើបាតុកម្ម។ ករណីដែលល្បីល្បាញនោះ គឺករណីស្ត្រីដែលត្រូវបានគេបណ្តេញចេញពីតំបន់បឹងកក់ ដែលបានបង្កើតចលនាប្រឆាំងនឹងការបណ្តេញចេញ ដោយសារតែពួកគេគិតថាស្ត្រី និងកុមារ នឹងមិនសូវបានអាថ្វាធរដៅមុខសញ្ញា ។[211] ថ្ងៃនេះ ពួកគេគឺជាឧទាហរណ៍ នៃស្ត្រីមកពីសហគមន៍ផ្សេងៗ ដែលបានប្រឈមនឹងការបណ្តេញចេញដោយខុសច្បាប់។ ប៉ុន្តែ បើយោងតាមអ្នកតំណាងពិសេស ចំណុចនេះអាចនឹងបង្កផលបះពាល់អវិជ្ជមានបន្ថែមមកលើស្ត្រីដែលបានរងផលប៉ះពាល់ដោយការបណ្តេញចេញ៖ "*សកម្មជនជាស្ត្រី ពាក់ព័ន្ធនឹងជម្លោះដីធ្លី ត្រូវបានរាយការណ៍ពីការប្រឈមនឹងការឃាយី និងគំរាមកំហែងមកលើខ្លួនឯងផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេដែលបានប៉ះពាល់ដល់ទំនាក់ទំនងគ្រួសារ និងសុខមាលភាពផ្នែកចិត្តសាស្ត្រ។*"[212]

---

[209] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[210] អង្គការ អាប្រូដេវ «ដីដែលត្រូវបានលួច អនាគតដែលត្រូវបានលួច ៖ របាយការណ៍ពីការរំលោភយកដីនៅកម្ពុជា» (ខែធ្នូ ឆ្នាំ២០១១), http://bit.ly/17Gmg9k

[211] អង្គការលើកលែងទោសអន្តរជាតិ «ការបណ្តេញចេញ និងការតស៊ូនៅកម្ពុជា ៖ ស្ត្រី ៥ នាក់ បានរៀបរាប់ពីជីវិតរបស់ពួកគេ» (ខែវិច្ឆិកា ឆ្នាំ២០១១), http://bit.ly/17GlPfp

[212] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

## ៤.៣. ផលប៉ះពាល់មកលើជនជាតិដើមភាគតិច

*"ដីគឺជាវប្បធម៌ របស់ជនជាតិដើមភាគតិច" –ដេហ្វ វ៉ាស៍ និង ម៉ែនប្រែហ្វត ហ៊ារណុង*

សម្បទានដី ជម្លោះដីធ្លី និងការគំរាមកំហែងពីការបណ្ដេញចេញ មកលើក្រុមសហគមន៍ជនជាតិដើមភាគតិចដែលនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យប៉ះពាល់ដល់ជីវភាពប្រពៃណីរបស់ពួកគេតាមច្រើនវិធី។ ចំណុចនេះកើតឡើង ដោយសារការពិតដែលថាសហគមន៍ជនជាតិដើមភាគតិច មិនបានប្រើប្រព័ន្ធទ្រព្យសម្បត្តិឯកជន ប៉ុន្តែគឺកាន់កាប់ដីជាសមូហភាព។ ទោះបីជា សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការមានប័ណ្ណកម្មសិទ្ធិសមូហភាព ត្រូវបានការពារតាមទ្រឹស្តី ក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ (មើលជំពូក ១) ការរំលោភបំពានមកលើដីរបស់ពួកគេនៅតែកើតមានជាបន្តបន្ទាប់ ដោយសារតែការផ្តល់ដីសម្បទានសេដ្ឋកិច្ច បានកាត់បន្ថយឱកាសរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព លើដីដែលពួកគេទទួលបានពីដូនតាមក។ យោងតាមអ្នកតំណាងពិសេស មានករណីមួយចំនួន ដែលដីសម្បទានត្រូវបានអភិវឌ្ឍន៍ដោយផ្ទាល់លើដីរបស់ជនជាតិដើមភាគតិច ដូច្នេះ នៅពេលដែលសហគមន៍ព្យាយាមចុះបញ្ជីដីរបស់ពួកគេ ពួកគេនឹងមិនទទួលបានប័ណ្ណកម្មសិទ្ធិ ឬក៏មិនមានដីនៅសល់សម្រាប់ចុះបញ្ជី។[213]

អ្វីដែលជំរុញឲ្យបញ្ហាកាន់តែរាលដាល គឺកត្តាដែលសហគមន៍ជនជាតិដើមភាគតិចរស់នៅក្នុងតំបន់ដែលសម្បូរធនធាន ដែលមានសក្តានុពលជាច្រើនក្នុងការចាប់ផ្តើមជីករ៉ែ និងសកម្មភាពកាប់ឈើ។ ដីរបស់ពួកគេតែងតែមានសក្តានុពលសម្រាប់កសិឧស្សាហកម្ម ដូចជា ចម្ការកៅស៊ូ។ បន្ថែមពីលើនោះ បច្ចេកទេសសម្រាប់កសិឧស្សាហកម្ម និងការអភិវឌ្ឍន៍ខាងផលិតកម្ម បានគំរាមកំហែងមកលើប្រព័ន្ធកសិកម្ម និងការដាំដំណាំរបស់ក្រុមជនជាតិដើមភាគតិចយ៉ាងខ្លាំង។ សហគមន៍ជនជាតិដើមភាគតិច ថ្មីៗនេះបានរាយការណ៍ពីផលលំបាកបណ្តាលមកពីបច្ចេកទេសដាំដំណាំថ្មី ដែលត្រូវបានប្រើលើដីរបស់ពួកគេ ក៏ដូចជា បញ្ហាផ្នែកទំនាក់-ទំនងជាមួយនឹងក្រុមហ៊ុនបរទេស។ បន្ថែមពីលើនោះ ភាពតានតឹងដែលពាក់ព័ន្ធនឹងការដកហូតយកដី និងការគ្រប់គ្រងលើចម្ការបានកើនឡើងជាច្រើន។[214]

អ្វីដែលសំខាន់បំផុត សម្បទានដីសេដ្ឋកិច្ច និងគម្រោងអភិវឌ្ឍន៍បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើវប្ប-ធម៌ប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិច និងរបៀបរស់នៅ។ សម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដីជាចំណុចកណ្តាលនៃជីវភាពរស់នៅ និងវប្បធម៌ ៖ បន្ថែមពីលើការដែលដីជាប្រភពសំខាន់សម្រាប់ស្វែងរកម្ហូបអាហារ ដីក៏ត្រូវបានប្រើប្រាស់ដើម្បីកប់សាកសព និងមានអត្ថន័យផ្នែកព្រលឹង ដូចជា *"ព្រៃអារក្ខ"* ដែលពិធីផ្នែកសាសនាត្រូវបានប្រារព្ធឡើង។ ដូច្នេះ ការរំលោភយកដីរបស់ជនជាតិដើមភាគតិច មានផលប៉ះ-ពាល់មិនមែនមកលើតែផ្នែកសេដ្ឋកិច្ច និងសង្គម ប៉ុន្តែក៏មានការរាយការណ៍ពីសម្បទានដីសេដ្ឋកិច្ចជាការប្រមាថ និងបំផ្លាញលើដីសម្រាប់កប់សាកសពរបស់ក្រុមជនជាតិដើមភាគតិច និងអារក្ខផងដែរ។ ឧទាហរណ៍ក្នុងដើមឆ្នាំ២០១៣ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថា សហគមន៍ចារ៉ាយ ប្រហែលជា ១០០ គ្រួសារ

---

[213] សម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការចុះបញ្ជីរបស់ដីសមូហភាព សូមមើលផ្នែក ៣.១.៣ នៃរបាយការណ៍។

[214] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

នៅក្នុងខេត្តរតនគិរី បានបដិសេធការប៉ុងប៉នរបស់អាជ្ញាធរក្នុងការវាស់វែងដីធ្លីរបស់ពួកគេ ៖ "*ក្នុងភូមិរបស់យើង មិនមានព្រៃសម្រាប់ព្រលឹងដូនតារបស់យើងទៀតនោះទេ ដូច្នេះយើងមានបំណងចង់រក្សាព្រៃនេះទុកឲ្យព្រលឹងទាំងនោះ និងសម្រាប់ជាអត្តសញ្ញាណនៃក្រុមជនជាតិដើមភាគតិចផងដែរ។*"[215]

## ៤.៤. ផលប៉ះពាល់លើបរិស្ថាន

ការបំផ្លាញបរិស្ថាន គឺជាការព្រួយបារម្ភដ៏ចម្បងមួយនៅប្រទេសកម្ពុជា ក្នុងពេលបច្ចុប្បន្ន។ យោងតាមការស្រាវជ្រាវដែលធ្វើឡើងដោយ ប្រតិភូសហភាពអឺរ៉ុប ឆ្នាំ២០១២[216]

> "*ធនធានបរិស្ថាន និងធនធានធម្មជាតិនៅកម្ពុជា កំពុងតែរងការគំរាមកំហែងដោយសារតែការទាញយកកម្រៃជ្រុលហួសហេតុ ក្នុងទំហំដ៏ធំ និងគួរឲ្យភ័យខ្លាច ដោយសារតែការគិតខ្លី។ ការធ្វើបែបនេះធ្វើឲ្យធនធានទាំងមូលមានការថយចុះ ហើយផលប្រយោជន៍មហាសាលបានធ្លាក់មកលើមនុស្សតែមួយចំនួនតូច ប៉ុន្តែបន្ទុកយ៉ាងធ្ងន់ធ្ងរបានធ្លាក់មកលើប្រជាពលរដ្ឋជាច្រើន។*"

ការស្រាវជ្រាវបានកំណត់បញ្ហាចំនួន ៤ ធំៗ ពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ៖ (១) ការរៀបចំផ្ទៃទឹក ដោយសារតែហេដ្ឋារចនាសម្ព័ន្ធដែលបានគ្រោងទុក និងជាក់ស្តែង នឹងត្រូវបានសាងសង់លើទន្លេមេគង្គ (២) ការរៀបចំ និងការប្រើប្រាស់ដី ជាពិសេសដីព្រៃរបស់រដ្ឋ (៣) ការបំផ្លាញព្រៃឈើតាមរយៈការកាប់ឈើខុសច្បាប់ និងដីសម្បទានសម្រាប់ការចម្រាញ់យកធនធាន និង (៤) ការបំផ្លាញដីដោយសារតែការធ្វើសកម្មភាពផ្នែកកសិកម្មដែលមិនសមរម្យ។

ការបន្តការកាប់ឈើដោយខុសច្បាប់ និងការអភិវឌ្ឍន៍នៃទំនប់វារីអគ្គិសនី គឺជាការព្រួយបារម្ភដ៏ធំមួយពាក់ព័ន្ធនឹងការពិចារណាលើផលប៉ះពាល់បរិស្ថាន។ ការចាត់តាំងដីក្នុងតំបន់ការពារ គឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ដែលត្រូវបានប្រើ ក្នុងការដាក់កំហិតលើការបំផ្លាញបរិស្ថាននៅក្នុងប្រទេស។ តំបន់ការពារត្រូវបានចែកចេញជាបួនប្រភេទ៖[217] (១) តំបន់សំខាន់ (២) តំបន់អភិរក្ស (៣) តំបន់ប្រើប្រាស់ដោយស្ថិរភាព និង (៤) តំបន់សហគមន៍។ ការអភិវឌ្ឍន៍អាចកើតឡើងបានក្នុងតំបន់ ២ ក្រោយ ប្រសិនបើការវាយតម្លៃផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានត្រូវបានធ្វើឡើង។[218] ថ្មីៗនេះ មានអនុក្រឹត្យជាមួយចំនួន ត្រូវប្រកាសដើម្បីចាត់តាំងដីក្នុងតំបន់ការពារ និងដើម្បីអនុញ្ញាតគម្រោងអភិវឌ្ឍន៍ ដូចជា គម្រោងកសិឧស្សាហកម្ម[219] ដូច្នេះជះឥទ្ធិពលយ៉ាងអាក្រក់ខ្លាំងមកលើបរិស្ថាន និងចាត់ទុកជាមោឃៈចំពោះការអនុម័តថាតំបន់នេះជាតំបន់ដែលត្រូវបានការពារ។

---

[215] ប៉ាក សៀងលី «ក្រុមចារ៉ាយការពារព្រៃនៃព្រលឹង» *ឌឹ ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣) http://www.phnompenhpost.com/national/jarai-ethnic-group-takes-stand-spirit-forest.

[216] ស្តេហ្វិន ចនស៊ិន (ណារដេកូ) និង គ្រេក ម៉ុនហ្វត (បាសស្តេល) ប្រតិភូសហគមន៍អឺរ៉ុបនៅកម្ពុជា «ស្ថានភាពបរិស្ថាននៅក្នុងប្រទេស» (ខែមេសា ឆ្នាំ២០១២), http://bit.ly/17HJa03

[217] ច្បាប់ស្តីពីតំបន់ការពារ (ខែកុម្ភៈ ឆ្នាំ២០០៨), http://bit.ly/1hPQmc7

[218] ដូចខាងលើ។ មាត្រា ៤៤

[219] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

គម្រោងកសិឧស្សាហកម្មជាច្រើន ពាក់ព័ន្ធនឹងការកាប់ឈើនៅតំបន់ធំៗក្នុងព្រៃ ដើម្បីឆ្ការដីសម្រាប់ដាំដំណាំអំពៅ ដំឡូងមី កៅស៊ូ និងដំណាំដទៃទៀត។ ជាលទ្ធផល តំបន់ព្រៃអាចនឹងត្រូវបានបំផ្លាញ ដែលធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើជីវចម្រុះ។ ការស្រាវជ្រាវដឹកនាំដោយ សាកលវិទ្យាល័យ ម៉ារីឡែន ដែលបានចេញផ្សាយកាលពីខែវិច្ឆិកា ឆ្នាំ២០១៣ បង្ហាញថាកម្ពុជាបាត់បង់ព្រៃប្រហែល ៧% ក្នុងរយៈពេល ១២ ឆ្នាំមកនេះ។[220] ព្រៃតំបន់ត្រូពិក ដូចជាព្រៃនៅកម្ពុជាផ្តល់ជីវិតដល់ប្រព័ន្ធអេកូឡូស៊ី ត្រូវរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារតែការរីករាលដាលនៃការកាប់ព្រៃ បណ្តាលឲ្យទឹកជំនន់កើនឡើង និងប៉ះពាល់ដល់លក្ខខណ្ឌការរស់នៅរបស់សត្វព្រៃជាច្រើនប្រភេទ។[221] ទឹកជំនន់គឺជាការព្រួយបារម្ភដ៏ធំមួយក្នុងតំបន់ទីប្រជុំជន ដែលផែនការរៀបចំនគរូបនីយកម្មមានភាពទន់ខ្សោយ និងគម្រោងអភិវឌ្ឍន៍ផ្នែកអចលនៈវត្ថុដោយមិនបានគិតគូរវែងឆ្ងាយ បណ្តាលឲ្យមានការហូរចេញដោយមិនគ្រប់គ្រាន់។[222] ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញជាច្រើន ចាប់ផ្តើមដឹងពីផលវិបាកនៃការចាក់បំពេញបឹងកក់ ដោយសារឃើញមានការកើនឡើងនៃទឹកជំនន់នៅទីប្រជុំជន។

*ព្រៃឡង់*[223]

ព្រៃឡង់ ត្រូវបានចាត់ទុកជាព្រៃដែលមានទីតាំងលើវាលទំនាប ដែលមានពណ៌ខៀវខ្ចី និងជាព្រៃដ៏ធំបំផុតនៃឧបទ្វីបឥណ្ឌូចិន។ ព្រៃនេះមានទីតាំងរវាងទន្លេមេគង្គ និងស្ទឹងសែន ព្រៃនេះបានលាតសន្ធឹងក្នុងខេត្តចំនួន ៤ និងរួមមានប្រព័ន្ធអេកូឡូស៊ី ចំនួន ៧ ជិតជាច់ពូជ ដែលបានផ្តល់លំនៅដ្ឋានដល់រុក្ខជាតិ និងសត្វរងគ្រោះចំនួន ៤០។ ព្រៃឡង់ក៏ត្រូវបានចាត់ទុកជាតំបន់ដីរបស់ជនជាតិដើមភាគតិច ដែលមិនទាន់រងការខូចខាតធ្ងន់ធ្ងរនៅកម្ពុជា ហើយជនជាតិកួយ ប្រហែលជា ២០០,០០០ នាក់ រស់នៅក្នុងភូមិរាប់រយនៅជុំវិញព្រៃនោះ។ ប្រជាពលរដ្ឋទាំងនេះពឹងផ្អែកលើព្រៃឡង់ មិនមែនសម្រាប់តែជីវភាពរបស់ពួកគេនោះទេ ប៉ុន្តែថែមទាំងប្រពៃណីបែបសង្គម និងព្រលឹងរបស់ពួកគេផងដែរ។

ក្នុងអំឡុង ឆ្នាំ១៩៩០ ព្រៃទាំងមូលត្រូវបានដកទុកសម្រាប់សម្បទានកាប់ឈើ បន្ទាប់ពីរដ្ឋាភិបាលបានធ្វើអនុបយោគតំបន់នោះ ពីដីព្រៃរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ។ បន្ទាប់ពីការតវ៉ាប្រឆាំងពីសាធារណជន និងសម្ពាធពីម្ចាស់ជំនួយ សម្បទានកាប់ឈើត្រូវបានព្យួរក្នុង ឆ្នាំ២០០២។ ប៉ុន្តែ ព្រៃឡង់ ក្នុងពេលបច្ចុប្បន្ននេះកំពុងតែប្រឈមមុខនឹងគ្រោះថ្នាក់ថ្មី និងកាន់តែខ្លាំងជាងមុន។ ចម្ការកសិឧស្សាហកម្មជាច្រើន (ជាពិសេសចម្ការកៅស៊ូ) និងសម្បទានជីករ៉ែ (ជាពិសេសការចម្រាញ់រ៉ែដែក និងរ៉ែមាស) កំពុងតែមានសកម្មភាព។ ចម្ការ និងរ៉ែទាំងនេះ បានលេបត្របាក់យកដីកសិកម្ម ដែលប្រជាពលរដ្ឋជនជាតិដើមភាគតិចពឹងផ្អែកលើ ដើម្បីស្វែងរកប្រាក់ចំណូលចិញ្ចឹមជីវិត និងថែមទាំងបំផ្លាញដើមជ័រឈើសំខាន់ៗ រាប់សែនដើម។ ឧស្សាហកម្មជីករ៉ែ ក៏ជំនួសសហគមន៍ជីករ៉ែទំហំតូច ដែលប្រើប្រាស់បច្ចេកទេសជីក មិនផ្តល់ផលប៉ះពាល់ដល់បរិស្ថាន ដែលបានធ្វើជា

---

[220] កាសែត ឌឹ ខេមបូឌា ដេលី «ការបាត់បង់ព្រៃឈើនៅកម្ពុជា ជាការបាត់បង់មួយដ៏អាក្រក់នៅក្នុងពិភពលោក» (ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣), http://bit.ly/HYlubu

[221] ដូចខាងលើ។

[222] លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[223] ការគំរាមកំហែង ព្រៃឡង់ (វេបសាយ), http://bit.ly/1hPRa0H

ច្រើនជំនាន់មកហើយ។ ការផ្តល់សម្បទានបែបនេះ គឺបណ្តាលឲ្យមានផលប៉ះពាល់ខ្លាំងក្លាណាស់ហើយ ប៉ុន្តែសម្បទានបែបនេះក៏ថែមទាំងបានសាងសង់បណ្តាញផ្លូវធំៗ និងរបងជុំវិញព្រៃ កាប់បំផ្លាញព្រៃ ឈើ និងរាំងការធ្វើដំណើរសត្វព្រៃ និងមនុស្សផងដែរ។ ផ្លូវថ្មីៗបែបនេះ ក៏បានជំនួយដល់អ្នកកាប់ឈើ និងអ្នកប្រមាញ់ខុសច្បាប់ផងដែរ។

ក្នុងច្បាប់ភូមិបាល គម្រោងអភិវឌ្ឍន៍ទាំងអស់ត្រូវតែចាំបាច់ត្រូវតែមានការវាយតម្លៃផ្នែកបរិស្ថាន ដែលត្រូវតែរួមបញ្ចូលការពិគ្រោះយោបល់ពីសហគមន៍រងគ្រោះ។ មកទល់ពេលនេះ បើតាមសកម្មជនសិទ្ធិដីធ្លី និងសមាជិកសហគមន៍ព្រៃឈើ ក្នុងតំបន់ព្រៃឡង់បានដឹង គឺថាមិនមានការវាយតម្លៃណាត្រូវបានធ្វើឡើងសម្រាប់គម្រោងអភិវឌ្ឍន៍ក្នុងតំបន់ព្រៃឡង់នោះទេ។ ពួកគេក៏បានរាយការណ៍ថាសហគមន៍ដែលរងផលប៉ះពាល់ក៏មិនដែលត្រូវបានពិគ្រោះយោបល់ផងដែរ។

ការទទួលបានទឹកស្អាតប្រើប្រាស់ ក៏ជាបញ្ហាផងដែរ។ ឧទាហរណ៍ ក្នុងខែសីហា ឆ្នាំ២០០៦ រដ្ឋាភិបាល បានផ្តល់ដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តកោះកុង ទៅកាន់ក្រុមហ៊ុនស្ករសញ្ជាតិកម្ពុជាចំនួន ២។ សហគមន៍ដែលរងផលប៉ះពាល់ បានអះអាងថាកាកសំណល់គីមី ដែលបានមកពីចម្ការទាំងនេះបានបំពុលប្រភពទឹកក្នុងមូលដ្ឋាន ហើយបានសម្លាប់មច្ឆាជាតិ ដែលជាមធ្យោបាយសំខាន់បំផុតសម្រាប់ប្រភពចំណីអាហាររបស់ពួកគេ។ ក្នុងខែមករា ឆ្នាំ២០១០ សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ទៅឲ្យ ក្រុមហ៊ុន *អេជអេជអិល គ្រុប* ដើម្បីផលិត និងកែច្នៃពោតសម្រាប់ចំណីសត្វ។ ក្រុមហ៊ុននេះទាញយកទឹកដើម្បីបង្កើតប្រព័ន្ធបង្ហូរទឹក បណ្តាលឲ្យទឹកជន់ដំណាំរបស់ប្រជាពលរដ្ឋ។ អ្នកភូមិបានរាយការណ៍ពីករណី ដែលទឹកបានប្រែពណ៌ និងសត្វឈឺ និងស្លាប់ដោយសារតែទឹក។[224]

ដោយបានឃើញការបំផ្លាញបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិរបស់កម្ពុជាយ៉ាងលោភលន់ សកម្មជនសិទ្ធិបរិស្ថានបាននាំគ្នាបំពងសំឡេង និងបានក្លាយជាជនសកម្មក្នុងការការពារដីរបស់ពួកគេ។ ប៉ុន្តែការការពារបរិស្ថាននៅកម្ពុជា ត្រូវចំណាយថ្លៃដ៏ខ្ពស់លើសលុប ដោយសារតែការលើកកម្ពស់ការយល់ដឹងពីការកាប់ឈើ និងការបំផ្លាញព្រៃឈើ បានរាំងផ្លូវអ្នកអភិវឌ្ឍន៍ដែលមានអំណាច និងគំរាមដល់ប្រាក់ចំណូលរបស់ពួកគេ។ ករណីដែលអាចបង្ហាញជាឧទាហរណ៍នៃគ្រោះថ្នាក់បែបនេះឲ្យកាន់តែច្បាស់ គឺករណី លោក ឈុត វុទ្ធី ដែលជាសកម្មជនការពារបរិស្ថានដ៏ល្បីល្បាញម្នាក់ ដែលត្រូវបានមន្ត្រីយោធាបាញ់សម្លាប់ក្នុង ខែមេសា ឆ្នាំ ២០១២ ក្នុងខេត្តកោះកុង ខណៈពេលដែលលោកកំពុងថតរូបការកាប់ឈើខុសច្បាប់។[225]

បន្ថែមពីលើនោះ ការងារដែលសកម្មជនបរិស្ថានបានធ្វើឡើង តែងតែមានការពិបាក ដោយសារតែព័ត៌មានដែលទាក់ទិននឹងគម្រោងនោះមានតិចតួច ឬក៏គ្មានសោះ។ ឧទាហរណ៍ ក្នុងតំបន់អារ៉ែង ខេត្តកោះកុង ភាពមិនច្បាស់លាស់ ថាតើការសាងសង់ទំនប់វារីអគ្គិសនីធំសម្បើមរបស់ក្រុមហ៊ុនចិន នឹងត្រូវបន្ត ឬយ៉ាងណានោះ ធ្វើឲ្យប្រជាពលរដ្ឋនៅតែមានការព្រួយបារម្ភ។ មិនមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន ត្រូវបានធ្វើឡើង

[224] លោក សុរិយា ប្រាសាទ ស៊ូបេឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

[225] អង្គការ មាត្រា ១៩ និង ម.ស.ម.ក «ការពារអ្នកការពារសិទ្ធិមនុស្ស ៖ សុវត្ថិភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា» (២០១៣), http://bit.ly/HrQfWL

ក្នុងតំបន់នេះនោះទេ ខណៈពេលដែលអង្គការជាច្រើនបានលើកឡើងពីការព្រួយបារម្ភយ៉ាងខ្លាំង ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលទំនប់វារីអគ្គិសនីនេះមានមកលើសហគមន៍មូលដ្ឋាន សត្វព្រៃ និងព្រៃឈើ។ អង្គការជាច្រើនបានចោទជាសំណួរពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនី ត្រូវបានព្រមាន ថាពួកគេនឹងអាចត្រូវបានបណ្តេញចេញពីប្រទេស។[226]

[226] កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ «ព្រះសង្ឃ បានចូលរួមក្នុងការពារព្រៃឈើ» (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣), http://bit.ly/17HNVXx

# ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

ជម្លោះដីធ្លីនៅកម្ពុជា កើតមានឡើងដោយសារតែប្រវត្តិសាស្ត្រដ៏ស្មុគស្មាញ និងកត្តាសំខាន់ៗផ្សេងៗមួយចំនួនទៀត។ ប៉ុន្តែ រដ្ឋាភិបាលក៏បានចូលរួមចំណែកដល់ការដែលធ្វើឲ្យជម្លោះដីធ្លីនៅទូទាំងប្រទេសកម្ពុជាកាន់តែរីករាលដាល។ ដើម្បីត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍន៍ និងការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលផ្តល់ផលប្រយោជន៍សម្រាប់អភិជនផ្នែកនយោបាយមួយចំនួននៅក្នុងប្រទេស រដ្ឋាភិបាលបានធ្វើប្រតិបត្តិការស្ងាត់ៗ ហើយបានរំលោភបំពានច្បាប់ និងប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងប្រជាពលរដ្ឋ ដោយមានអមជាមួយនឹងនិទណ្ឌភាពទាំងស្រុង។

អភ័យឯកសិទ្ធិ ដែលរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល និងក្រុមហ៊ុនអភិវឌ្ឍន៍បានធ្វើប្រតិបត្តិការនៅក្នុងប្រទេស មិនបានផ្តល់ប្រយោជន៍អ្វី ក្រៅពីធ្វើឲ្យប្រជាពលរដ្ឋកាន់តែក្រីក្រ និងធ្វើឲ្យបុគ្គលដែលងាយរងគ្រោះកាន់តែត្រូវបានទទួលការយកចិត្តទុកដាក់កាន់តែខ្លាំង។ ប្រសិនបើរដ្ឋាភិបាលមិនចាត់វិធានការដាក់លាក់ និងភ្លាមៗ ក្នុងការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ និងបញ្ឈប់គម្រោងអភិវឌ្ឍន៍ដែលធ្វើឲ្យផលវិនាសអន្តរាយនេះ និងអំពើហិង្សាដែលអមមកជាមួយនោះទេ ជម្លោះដីធ្លីនឹងរាលដាលទៅទូទាំងប្រទេស ដែលនឹងធ្វើឲ្យកើតមានផលប៉ះពាល់ដែលមិនអាចកែតម្រូវបានសម្រាប់ប្រជាពលរដ្ឋកម្ពុជា និងបរិស្ថាន។ រដ្ឋាភិបាលថ្មីមានទំនួលខុសត្រូវក្នុងការសម្រេចចិត្តឲ្យបានត្រឹមត្រូវ និងដើម្បីចាត់វិធានការដើម្បីបញ្ចប់រាល់ជម្លោះដីធ្លីនៅកម្ពុជាឲ្យបានដាច់ស្រេច។

## ៥.២. អនុសាសន៍

ដោយពិចារណាឃើញស្ថានភាពបច្ចុប្បន្ននៃសិទ្ធិដីធ្លីនៅកម្ពុជា ម.ស.ម.ក បានផ្តល់អនុសាសន៍ដូចខាងក្រោមទៅរដ្ឋាភិបាលថ្មី។ អនុសាសន៍មួយចំនួនសម្រាប់រយៈពេលខ្លី ខណៈពេលដែលអនុសាសន៍ខ្លះទៀតគឺមានរយៈពេលមធ្យម ឬក៏រយៈពេលវែង។ អនុសាសន៍ខ្លះដែលបានរួមបញ្ចូលនេះ គឺត្រូវបានលើកឡើងដោយសហគមន៍ដែលបានរងគ្រោះដោយសារជម្លោះដីធ្លី ហើយដែលបានចូលរួមក្នុងវេទិកាពិភាក្សាគោលនយោបាយរបស់ ម.ស.ម.ក និងកិច្ចពិភាក្សាតុមូលដែលបានរៀបចំឡើងក្នុងរវាងខែកញ្ញា ឆ្នាំ២០១២ និងខែមិថុនា ឆ្នាំ២០១៣។[227]

សរុបមក រដ្ឋាភិបាលគួរតែធានាថាច្បាប់ដែលមានស្រាប់ត្រូវបានអនុវត្តន៍យ៉ាងត្រឹមត្រូវ រួមទាំង ការអនុវត្តន៍ដោយអាជ្ញាធរ និងវិស័យឯកជន។ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលគួរតែសហការណ៍យ៉ាងជិតស្និទ្ធដើម្បីធ្វើការរួមគ្នា ដើម្បីជំរុញឲ្យមានការអនុវត្តន៍នូវអនុសាសន៍ដូចខាងក្រោម ជាពិសេសគឺ ៖

- ជូនដំណឹង និងអប់រំសហគមន៍អំពីសិទ្ធិរបស់ពួកគេ

[227] ម.ស.ម.ក, «របាយការណ៍គោលនយោបាយកំណែទម្រង់ដីធ្លី៖ របកគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ» (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1inGTWX

- បង្កើតសំណើសម្រាប់កំណែទម្រង់ដីធ្លីដែលជាក់លាក់ និងលម្អិត ដែលធ្វើឡើងដោយមានការពិគ្រោះយោបល់ពីអង្គការសង្គមស៊ីវិល និងសហគមន៍រងគ្រោះ និង
- ធ្វើការស៊ើបអង្កេតដោយឯករាជ្យ ម៉ត់ចត់ និងមិនលម្អៀងមកលើករណីជម្លោះដីធ្លី។

### *៥.២.១. ពាក់ព័ន្ធនឹងតម្លាភាព*

រដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធរួមទាំង ក្រសួងរៀបចំដែនដី ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម គួរតែ៖

- ចងក្រងព័ត៌មានជាសាធារណៈ ហើយសាធារជនអាចស្វែងរកព័ត៌មានបាន អំពីការផ្តល់និងការលុបចោលសម្បទានដីសេដ្ឋកិច្ច
- ចងក្រងព័ត៌មានជាសាធារណៈតាមទម្រង់ជាផែនទី ចំណាត់ថ្នាក់ និងការចុះបញ្ជីនៃដីឯកជន និងសាធារណៈរបស់រដ្ឋ ក៏ដូចជាព័ត៌មានទាក់ទងនឹងការធ្វើអនុប្បយោគ
- ចងក្រងព័ត៌មានជាសាធារណៈអំពីបញ្ជីនៃតំបន់ការពារ
- ធានាថាការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋ និងតំបន់ប្រើប្រាស់ជាស្ថិរភាព មានតម្លភាព និងបើកចំហ
- ធានាថាដំណើរការដេញថ្លៃសម្បទានដីសេដ្ឋកិច្ច មានលក្ខណៈប្រកួតប្រជែង និងមានតម្លាភាព
- ពន្យានូវការផ្អាកផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងបើកចំហជាសាធារណៈពីចំនួនសម្បទានដីសេដ្ឋកិច្ចដែលកំពុងដំណើរការ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ និងធ្វើឲ្យការពិនិត្យសាឡើងវិញលើប្រព័ន្ធផ្តល់សម្បទានដីសេដ្ឋកិច្ចថាអាចត្រូវបានដឹងឮជាសាធារណៈ និង
- អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដើម្បីបង្កើនតម្លាភាព និងការចូលរួមជាសាធារណៈ។

### *៥.២.២. ពាក់ព័ន្ធនឹងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី*

រដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធរួមទាំង ក្រសួងរៀបចំដែនដី ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម គួរតែ៖

- ដោះស្រាយរាល់ជម្លោះដីធ្លីជាអាទិភាព និងចៀសវាងការដកហូតសិទ្ធិចេញពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិបន្ថែមទៀត
- គោរពសិទ្ធិមានកម្មសិទ្ធិ និងសិទ្ធិកាន់កាប់ យោងតាមច្បាប់ភូមិបាល
- ពន្លឿនដំណើរការចុះបញ្ជីសម្រាប់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជា នីតិបុគ្គល និងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិសមូហភាពរបស់ពួកគេ និងបញ្ឈប់ការផ្តល់សម្បទានដីលើដីជនជាតិដើមភាគតិច មុនដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពត្រូវបានបញ្ចប់
- ធានាថាការអនុវត្តនៃបទបញ្ជាលេខ ០១ មិនធ្វើឲ្យសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវប្រឈមនឹងការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពនោះទេ

- ធានាថារាល់ការផ្តល់សម្បទាន នឹងត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីចៀសវាងការបំផ្លាញបរិស្ថាន
- ការពារសកម្មភាពនៅលើតំបន់ដែលបញ្ជាក់ពីអត្តសញ្ញាណផ្នែកវប្បធម៌ និងអារក្ខរបស់ពួកគេ។

### *៥.២.៣. ពាក់ព័ន្ធនឹងការពិគ្រោះយោបល់*

រដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធរួមទាំង ក្រសួងរៀបចំដែនដី ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម គួរតែ៖

- រៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈ រួមបញ្ចូលគ្រប់វិស័យ និងមានអត្ថន័យ ជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់ និងសហគមន៍រងផលប៉ះពាល់ នៅពេលដែលដីសម្បទាន និងគម្រោងអភិវឌ្ឍន៍នឹងត្រូវបានធ្វើឡើង។ ការពិគ្រោះយោបល់គួរតែចាប់ផ្តើមពីដំណាក់កាលដំបូងបង្អស់តាមដែលអាចធ្វើទៅបាន និងបង្កើតឡើងតាមរយៈដំណើរការសម្រេចចិត្ត និង
- វាយតម្លៃនូវផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន នៃគម្រោងអភិវឌ្ឍន៍ទំហំធំយោងតាមបទដ្ឋានអន្តរជាតិ មុនពេលផ្តល់ដីសម្បទានសេដ្ឋកិច្ច និងដោយបានពិគ្រោះយោបល់ជាមួយនឹងសហគមន៍ដែលរងផលប៉ះពាល់។

### *៥.២.៤. ពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ*

រដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធរួមទាំង ក្រសួងរៀបចំដែនដី ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម គួរតែ៖

- ធានាថាការបណ្តេញចេញ នឹងត្រូវបានប្រើជាមធ្យោបាយចុងក្រោយបង្អស់តែប៉ុណ្ណោះ
- រក្សាការផ្អាកការបណ្តេញចេញ ហូតទាល់តែដំណើរការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិបានចប់សព្វ-គ្រប់
- ធានាថាតំបន់តាំងលំនៅថ្មីមានសេវាកម្មជាមូលដ្ឋាន រួមទាំង អគ្គិសនី ទឹក អនាម័យ ការអប់រំសាធារណៈ និងសេវាសុខភាព និងសុវត្ថិភាព
- ធានាថាជំនួយផ្នែកហិរញ្ញវត្ថុយ៉ាងសមស្រប និងការរស់នៅដោយសមរម្យ និងប្រាក់សំណងសមរម្យត្រូវបានផ្តល់ជូន និងទទួលបានដោយសហគមន៍ដែលរងផលប៉ះពាល់
- ធានាថាបុគ្គលដែលត្រូវបានជម្លៀស ត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិដើម្បីការពារពួកគេប្រឆាំងនឹងការគំរាមកំហែងនៃការបណ្តេញចេញថ្មី និង
- ធានាថាកងកម្លាំងរបស់រដ្ឋ នឹងមិនត្រូវបានក្រុមហ៊ុនទទួលដីសម្បទានជួលនោះទេ។

### *៥.២.៥. ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានសំណងដ៏មានប្រសិទ្ធភាព*

រដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធរួមទាំង ក្រសួងរៀបចំដែនដី ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម គួរតែ៖

- ពង្រឹងយន្តការដោះស្រាយជម្លោះដែលមានស្រាប់

- ធ្វើការស៊ើបអង្កេត និងប្រសិនបើចាំបាច់ ដាក់ទោសដល់តួអង្គឯកជនដែលទទួលខុសត្រូវចំពោះការរំលោភយកដី ការបណ្តេញចេញដោយបង្ខំ និងការមិនអនុវត្តន៍តាមច្បាប់
- ដាក់ឲ្យកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋទទួលខុសត្រូវចំពោះការប្រើប្រាស់កម្លាំងហួសហេតុមកលើប្រជាពលរដ្ឋ និង
- ធ្វើការបន្ថែមឆ្ពោះទៅរកការធានាថាប្រព័ន្ធតុលាការមានភាពឯករាជ្យ ដើម្បីកម្រិតនូវការជះឥទ្ធិពលផ្នែកនយោបាយ។

### *៥.២.៦. ពាក់ព័ន្ធនឹងសិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំ និងសិទ្ធិធ្វើសមាគម*

រដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធរួមទាំង ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម គួរតែះ

- សម្របសម្រួលការងាររបស់អង្គការសង្គមស៊ីវិល ក្នុងការស៊ើបអង្កេតការរំលោភយកដី និងករណីបណ្តេញចេញដោយបង្ខំ
- បញ្ចប់រាល់ការយាយីពាក់ព័ន្ធនឹងនយោបាយ និងតាមរយៈប្រព័ន្ធតុលាការ និងអំពើហិង្សាលើក្រុមបាតុករត្រូវដោះលែងតំណាងសហគមន៍ និងអ្នកតស៊ូមតិខាងសិទ្ធិដីធ្លី ដែលកំពុងតែជាប់ឃុំខ្លួន ឬជាប់ពន្ធនាគារដោយសារតែបានអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ និងសិទ្ធិជួបប្រជុំជាបន្ទាន់។

# ឯកសារយោង

## ច្បាប់ជាតិ អនុក្រឹត្យ សេចក្តីបង្គាប់ និងសេចក្តីសម្រេច

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ 092/003/2007 (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ១៩៩៣ ធ្វើវិសោធនកម្មក្នុង ឆ្នាំ២០០៦ ) http://bit.ly/1hcJqYV

ក្រុមប្រឹក្សាគោនយោបាយដីធ្លី សេចក្តីណែនាំលេខ ២០ ស្តីពីការអនុវត្តន៍បទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ១ ប.ប ( ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ), http://bit.ly/1hcN4lm

«សេចក្តីប្រកាសអន្តរក្រសួងស្តីពី ការកំណត់ប្រាក់ចំណូលមកពីថ្លៃសេវាកម្មសុរិយោដី» លេខ៣៧៧ SHV/, ក្រសួងរៀបចំដែនដី (ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២), http://bit.ly/1bU3wQH

ច្បាប់ភូមិបាល នស/រកម/០៨០១/១៤ ( ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ ), http://bit.ly/1dGTrbO

ច្បាប់ស្តីពី អស្សាមិករណ៍ ( ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ), http://bit.ly/1dKukoq

សេចក្តីណែនាំ ពីការអនុវត្តន៍បទបញ្ជាលេខ ០១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការរៀបចំ និងចងក្រងជាឯកសារដោយលេខាធិការស្តីពីការអនុវត្តបទបញ្ជាលេខ ០១ បប ក្រសួងរៀបចំដែនដី ( ឆ្នាំ២០១២ ), http://bit.ly/1hcN4lm

សេចក្តីបង្គាប់ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច លេខ ០១ បប (ខែឧសភា ឆ្នាំ២០១២)

ច្បាប់ស្តីពីតំបន់ការពារ (ខែកុម្ភៈ ឆ្នាំ២០០៨), http://bit.ly/1hPQmc7

ព្រះរាជក្រឹត្យ ស្តីពីបទបញ្ញត្ត និងគោលការណ៍ណែនាំ ពាក់ព័ន្ធនឹងការធ្វើអនុបយោគនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងស្ថាប័នរដ្ឋ នស/រកត/០៨០៦/៣៣៩ (ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៦)

ព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី នស/កត/០២០៦/០៩៧ (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦)

អនុក្រឹត្យ លេខ ១៩ ស្តីពីដីសម្បទានសង្គមកិច្ច អនក/បក (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣), http://bit.ly/17FLTRS

អនុក្រឹត្យ លេខ ៨៣ ស្តីពីដំណើរការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច អនក/បក (ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩), http://bit.ly/17FKSZV

អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក/បក (ថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥), http://bit.ly/16EBYyU

អនុក្រឹត្យ លេខ ១៤៦ ស្តីពី ដីសម្បទានសេដ្ឋកិច្ច អនក/បក (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥), http://bit.ly/17FLWgj

អនុក្រឹត្យ ស្តីពី វិធាន និងនីតិវិធីនៃការធ្វើអនុបយោគស្តីពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងស្ថាប័នសាធារណៈ លេខ ១២៩ អនក្រ បក (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦), http://bit.ly/1hcMjcc

មើលអនុក្រឹត្យ លេខ ១៣១ អនក/បក ស្តីពីការកែប្រែអនុក្រឹត្យ ស្តីពី ដីសម្បទានសេដ្ឋកិច្ច ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

# ច្បាប់ និងកតិកាសញ្ញាអន្តរជាតិ

## *អនុសញ្ញាអន្តរជាតិ និងសេចក្តីប្រកាស*

កតិកាសញ្ញា ស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៣៤/១៨០ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ ចូលជាធរមាន ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១) http://bit.ly/180arEj

*កតិកាសញ្ញា ស្តីពី សិទ្ធិកុមារ ( សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៤៤/២៥ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ១៩៨៩ ចូលជាធរមាន ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០)* http://bit.ly/180atMv

សេចក្តីប្រកាសស្តីពី សិទ្ធិជនជាតិដើមភាគតិច (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៦១/២៩៥ នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០៧) , http://bit.ly/1h1SfDS

កតិកាសញ្ញាអន្តរជាតិ ស្តីពី ការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងពូជសាសន៍ (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២១០៦ (XX) នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ ចូលជាធរមាន ថ្ងៃទី៤ ខែមករា ឆ្នាំ ១៩៦៩) http://bit.ly/180azUe

កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២២០០A (XX) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាន ថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦) , http://bit.ly/15WUwtO

សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២១៧ A III នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨), http://bit.ly/1808qrH

## *ករណីផ្នែកច្បាប់*

គណៈកម្មាធិការស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីអត្ថាធិប្បាយទូទៅ លេខ ៤ ៖ «សិទ្ធិទទួលបានលំនៅឋានសមស្រប (មាត្រា ១១ (១))» (ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១), http://bit.ly/15WViHa

គណៈកម្មាធិការស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីអត្ថាធិប្បាយទូទៅ លេខ ៧ ៖ «សិទ្ធិទទួលបានលំនៅឋានសមស្រប (មាត្រា ១១.១) ៖ ការបណ្តេញចេញដោយបង្ខំ» (ថ្ងៃទី២០ ខែឧសភា ឆ្នាំ ១៩៩៧), http://bit.ly/HbQDIV

*លិខិតុបករណ៍អន្តរជាតិផ្សេងៗ*

គោលការណ៍ណែនាំរបស់អ.ស.ប ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍ , និងឧបសម្ព័ន្ធ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.ប ស្តីពីការមានផ្ទះសម្បែងសមរម្យជាធាតុផ្សំនៃសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ A/HRC/4/18, (ឆ្នាំ២០០៧) http://bit.ly/HbSJIF

គោលការណ៍សិទ្ធិមនុស្សអប្បបរមាពាក់ព័ន្ធនឹងការទទួលបាន ឬផ្ទេរសិទ្ធិដីធ្លីក្នុងទ្រង់ទ្រាយធំ, ឧបសម្ព័ន្ធភ្ជាប់ក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសអ.ស.ប ស្តីពីសិទ្ធិទទួលបានស្បៀងអាហារ A/HRC/13/33/Add.2, (ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩) http://bit.ly/HbTqlk

គោលការណ៍ស្តីពីការដោះស្រាយមានប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិសម្រាប់ជនភៀសខ្លួន និងជនភៀសសឹក, អ្នករាយការណ៍ពិសេសរបស់អ.ស.បស្តីពីប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិ, E/CN.4/Sub.2/2005/17, (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៥) http://bit.ly/1afgYM9

គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស, ឧបសម្ព័ន្ធក្នុងរបាយការណ៍របស់តំណាងពិសេសស្តីពីបញ្ហាសិទ្ធិមនុស្ស និងអន្តរសាជីវកម្ម និងសហគ្រាសដទៃទៀត A/HRC/17/31 (ថ្ងៃទី១២ ខែមិនា ឆ្នាំ២០១១) http://bit.ly/HbVg5A

## របាយការណ៍ និងការបោះពុម្ពផ្សាយ

អាកស្សិនអេដ «កន្លែងទំនេរលើដី ៖ អភិវឌ្ឍការគ្រប់គ្រងដីធ្លីដើម្បីបញ្ឈប់ការរំលោភយកដី» http://bit.ly/17Gk0yM

អង្គការអាដហុក, «ផ្លូវបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា ឆ្នាំ២០១២» (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1eFH8wu

អង្គការលើកលែងទោសអន្តរជាតិ «កម្ពុជា ៖ ការអភិវឌ្ឍន៍ទីប្រជុំជន ឬក៏ការរៀបចំសំណង់អានាធិបតេយ្យ?» (ខែឧសភា ឆ្នាំ២០០៩) http://bit.ly/17GoXYr

អង្គការលើកលែងទោសអន្តរជាតិ «ការបណ្តេញចេញ និងការតស៊ូនៅកម្ពុជា ៖ ស្ត្រី ៥ នាក់ បានរៀបរាប់ពីជីវិតរបស់ពួកគេ» (ខែវិច្ឆិកា ឆ្នាំ២០១១), http://bit.ly/17GlPfp

អង្គការលើកលែងទោសអន្តរជាតិ «សិទ្ធិត្រូវបានលុបចោលនៅកម្ពុជា, (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨) http://bit.ly/1ar2w3Q

អង្គការ អាប្រូជេរ «ដីដែលត្រូវបានលួច អនាគតដែលត្រូវបានលួច ៖ របាយការណ៍ពីការរំលោភយកដីនៅកម្ពុជា» (ខែធ្នូ ឆ្នាំ២០១១), http://bit.ly/17Gmg9k

ស្ពានទៅកាន់សន្តិភាពកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាននិងការបណ្តេញចេញ, គម្រោងគណនេយ្យភាពអន្តរជាតិ៖ «សៀវភៅណែនាំស្តីពីពីសិទ្ធិដីធ្លី និងលំនៅដ្ឋាននៅកម្ពុជា» លេខ១, ផ្នែកទី២ (ខែតុលា ឆ្នាំ២០០៩) http://bit.ly/Hrafs4

ម.ស.ម.ក និងអង្គការមាត្រា១៩, «ការពារអ្នកការពារសិទ្ធិមនុស្ស៖ សុវត្ថិភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (ឆ្នាំ២០១៣) ទំព័រទី២៩, http://bit.ly/HrQfWL

ម.ស.ម.ក «ធុរកិច្ច និងសិទ្ធិមនុស្សនៅកម្ពុជា ៖ ការបង្កើតសសរស្តម្ភ ទាំង ៣" (ខែវិច្ឆិកា ឆ្នាំ២០១០), http://bit.ly/16EB5Gq

ម.ស.ម.ក, «កំណែទម្រង់ប្រព័ន្ធយុត្តិធម៌» (របាយការណ៍សង្ខេប) (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1bo6GdM

ម.ស.ម.ក, «របាយការណ៍គោលនយោបាយកំណែទម្រង់ដីធ្លី៖ របកគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ» (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1inGTWX

ម.ស.ម.ក «ការវិភាគផ្នែកច្បាប់ស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោសមកលើ តំណាងសហគមន៍ បឹងកក់ ចំនួន ១៣នាក់ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២» (ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២), http://bit.ly/16HN5XP

ម.ស.ម.ក «សោកនាដកម្មនៅបុរីកីឡា នៅតែបន្ត» (ខែឧសភា ឆ្នាំ២០១២), http://bit.ly/17G2dbc

មជ្ឈមណ្ឌលសិទ្ធិលំនៅឋាន និងការបណ្តេញចេញ «កម្ពុជា ៖ ធនាគារពិភពលោកស៊ើបអង្កេតគម្រោងផ្តល់បណ្ណកម្មសិទ្ធិដីធ្លី» (ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១០), http://bit.ly/1inVce0

មជ្ឈមណ្ឌលសិទ្ធិលំនៅឋាន និងការបណ្តេញចេញ «រស់នៅក្រោមការគំរាមកំហែង ប៉ុន្តែមិនមានកន្លែងណាផ្សេងដែលត្រូវទៅ ៖ ការស្រាវជ្រាវស្តីពីផលប៉ះពាល់ពីការបណ្តេញចេញមកលើស្ត្រីនៅភ្នំពេញ» (ខែវិច្ឆិកា ឆ្នាំ២០១១), http://bit.ly/17GkBk6

អង្គការសមធម៌កម្ពុជា «ភាពផ្អែមល្ហែមតែល្វីង សេចក្ដីសង្ខេបពីផលិតផលនៃឧស្សាហកម្មស្ករ ពាណិជ្ជកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា» (ខែកញ្ញា ឆ្នាំ២០១០), http://bit.ly/1bcEUkw

អង្គការសមធម៌កម្ពុជា និងការអភិវឌ្ឍន៍អន្តរជាតិដែលមានលក្ខណៈរួមបញ្ចូល «ការប្រមូលផលដែលមានភាពផ្អែមល្ហែមតែល្វីង ៖ ការវាយតម្លៃផលប៉ះពាល់មកលើសិទ្ធិមនុស្ស របស់សហគមន៍អឺរ៉ុប មិនបានរកឃើញអ្វីក្រៅពី ការផ្ដួចផ្ដើមទិញអាវុធនៅកម្ពុជានោះទេ» (ឆ្នាំ២០១៣) http://bit.ly/17G5OpH

ហ្វ្រេង វិលមែ, «សំឡេងជនជាតិដើមភាគតិចក្នុងនយោបាយពិភពលោក (១៩៩៣)

ហ្វ្រែនស៍ វ៉ុលគ័រ និង គុនធឺរ ស៊ុលជហ្វ «គោលនយោបាយចាស់ សកម្មភាពថ្មី ៖ ការបង្កើតថ្មីផ្នែកនយោបាយដ៏គួរឲ្យភ្ញាក់ផ្អើល ក្នុងការទទួលស្គាល់សិទ្ធិមនុស្ស ក្នុងកំណែទម្រង់ដីធ្លីរបស់កម្ពុជា» សន្និសីទប្រចាំឆ្នាំ របស់ធនាគារពិភពលោក ស្ដីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ២០១៣ ថ្ងៃទី ៨-១១ ខែមេសា ឆ្នាំ២០១៣

អង្គការគ្លូបិល វិតនេស «កម្ពុជាសម្រាប់លក់ ៖ វិធីដែលអភិជននៅកម្ពុជា បានកាន់កាប់នូវ ឧស្សាហកម្មអស្សាមិករណ៍ របស់ប្រទេស» (ខែកុម្ភៈ ឆ្នាំ២០០៩), http://bit.ly/1c3N3cG

អង្គការគ្លូបិល វិតនេស «អភិជនកៅស៊ូ វិធីដែលក្រុមហ៊ុនវៀតណាម និងអ្នកហិរញ្ញវត្ថុអន្តរជាតិ បានដឹកនាំវិបត្តិដីធ្លីនៅក្នុងប្រទេសឡាវ និងកម្ពុជា» (ខែឧសភា ឆ្នាំ២០១៣), http://bit.ly/1ar7lKn

ហែល ចំរើន, «ការណែនាំច្បាប់ភូមបាលនៃប្រទេសកម្ពុជា» នៅក្នុងរបាយការណ៍របស់ ហោ ផេង, គង់ ផល្លៈ និងជត មែនហ្សែល, ការណែនាំច្បាប់កម្ពុជា (២០១២) ទំព័រទី៣១៦ http://bit.ly/18AYchV

សម្ព័ន្ធដីធ្លីអន្តរជាតិ «សេចក្ដីប្រកាស ធីរ៉ាណា» មហាសន្និបាត ឆ្នាំ២០១១ (ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១), http://bit.ly/1a7inbY

ដែហ្វ និងម៉ែនហ្វ្រីត ហ៊ែរណុង មូលនិធិ ហោនរេចបូល «ជនជាតិដើមភាគតិច និងប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា», សន្និសីទប្រចាំឆ្នាំ របស់ធនាគារពិភពលោក ស្ដីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ២០១៣ ថ្ងៃទី ៨-១១ ខែមេសា ឆ្នាំ២០១៣ http://bit.ly/HxqbcD

ការដាក់ស្នើរម សម្រាប់ដំណើរការពិនិត្យជាសាកលតាមពេលវេលាកំណត់ លើកទី ២ ស្ដីពី ប្រទេសកម្ពុជា (ខែមិថុនា ឆ្នាំ២០១៣), http://bit.ly/1bFGb5n

អង្គការឃ្លាំមើលសិទ្ធិមនុស្សហ្យូមែនរ៉ៃវ៍វ៉ចNO

អង្គការឃ្លាំមើលសិទ្ធិមេធាវីកាណាដា «កម្ពុជា ៖ ការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស លោក គួច វែង តាមអំពើចិត្ត» ( លិខិត ) ( ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ), http://bit.ly/173SecM

អង្គការលីកាដូ «២ ឆ្នាំបន្ទាប់ពីការបណ្តេញចេញរបស់ពួកគេចេញពីកណ្តាលទីក្រុងភ្នំពេញ ប្រជាពលរដ្ឋនៅតែរស់នៅក្នុងទុគ៌ភាព» ( ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ ) http://bit.ly/1athCWm

ការិយាល័យឧត្តមស្នងការអ.ស.ប, «តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអ.ស.បក្នុងការជួយដល់រដ្ឋាភិបាល និងពលរដ្ឋកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស» ( ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១១ ) http://bit.ly/1iteXBc

ការិយាល័យឧត្តមស្នងការអ.ស.ប, «តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអ.ស.បក្នុងការជួយដល់រដ្ឋាភិបាល និងពលរដ្ឋកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស» ( ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៣ ) http://bit.ly/1itfzXq

ភីតទ័រ ឡឺប្រឺច តំណាងពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា «ការបន្តវប្បធម៌និទណ្ឌភាពនៅកម្ពុជា» ( ខែតុលា ឆ្នាំ២០០៥ ), http://bit.ly/1a7tba0

សឺក បូរ័ក្ស, «ភាពជាម្ចាស់កម្មសិទ្ធិ, លក់ និងការក្តោបក្តាប់ដីធ្លីនៅកម្ពុជា៖ ការពិនិត្យបឋមលើទិន្នន័យដែលមានស្រាប់ និងទិន្នន័យដែលប្រមូលបានពីការស្ទង់មតិថ្មីៗចំនួន៤» ( ខែកញ្ញា ឆ្នាំ២០០០ ), ឯកសារសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( CDRI ) លេខ១៦, ទំព័រទី៣ http://bit.ly/18AWa17

ស្តេបហ្វេន អេរិនត្រូដ, «វិសហមជ្ឈការ និងក្តីសង្ឃឹមនៃការពង្រឹងអំណាចពលរដ្ឋជនជាតិដើមភាគតិច៖ ករណីធនាគារពិភពលោកនៅកម្ពុជា ឆ្នាំ២០០៩,» កាសែតប៉ាស៊ីហ្វិក, វ៉ុល ២៤, លេខ ១ ( ខែមិនា ឆ្នាំ២០១១ )។

ស្តេហ្វិន ចនស៊ិន ( ណរដេកូ ) និង គ្រេក ម៉ុនហ្វត ( បាសស្តេល ) ប្រតិភូសហគមន៍អឺរ៉ុបនៅកម្ពុជា «ស្ថានភាពបរិស្ថាននៅក្នុងប្រទេស» (ខែមេសា ឆ្នាំ២០១២), http://bit.ly/17HJa03

អង្គការស្ត្រីខ្មែរ «ពួកគេយកដីរបស់ខ្ញុំ ពួកគេបំផ្លាញជីវិតខ្ញុំ ៖ របាយការណ៍ស្តីពីផលប៉ះពាល់ផ្នែកចិត្តសាស្ត្រមកលើស្ត្រីដែលរងគ្រោះដោយសារការបណ្តេញចេញនៅកម្ពុជា» (ខែកុម្ភៈ ឆ្នាំ២០១៣), http://bit.ly/17GkqFD

របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការដ្ឋានស្តីពីបញ្ហាសិទ្ធិមនុស្ស និងអន្តរសាជីវកម្ម និងសហគ្រាសដទៃទៀត, «ការពារ, គោរព, និងដោះស្រាយ» ដែលជាក្របខណ្ឌមួយសម្រាប់ធុរកិច្ចនិងសិទ្ធិមនុស្ស A/HRC/8/5 (ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨) http://bit.ly/HbWayZ

លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា», សេចក្តីបន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀតនៅកម្ពុជា, A/HRC/21/63/Add.1/Rev.1 (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) http://bit.ly/17FL8bq

លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី, «របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា» (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣) http://bit.ly/17G77ox

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា «ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា ការសិក្សាពីការចុះបញ្ជីជាប្រព័ន្ធក្នុងខេត្តចំនួន ៣ នៅកម្ពុជា និងទីក្រុង» (ខែវិច្ឆិកា ឆ្នាំ២០១២) http://bit.ly/HoeO6M

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពី កម្ពុជា «ដីសម្បទានសេដ្ឋកិច្ច និងសហគមន៍មូលដ្ឋាន» (ឆ្នាំ២០១០), http://bit.ly/16LhDb5

## សន្ទរកថា និងបទសម្ភាសន៍

សន្ទរកថារបស់សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី"យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី២ នៅអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៤ នៃរដ្ឋសភា (ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨) http://bit.ly/HpfSqY

សន្ទរកថារបស់សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី"យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី**៥** នៃរដ្ឋសភា (ថ្ងៃទី២**៥** ខែកញ្ញា ឆ្នាំ២០១**៣**)http://bit.ly/HxsV9U

## អត្ថបទសារព័ត៌មាន និងសេចក្តីថ្លែងការណ៍

អង្គការលើកលែងទោសអន្តរជាតិ «ប្រជាពលរដ្ឋចំនួន ១៦០ គ្រួសារនៅកម្ពុជាប្រឈមមុខនឹងការបណ្តេញចេញ (ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ http://bit.ly/1bcHuqB

គណៈកម្មាការសិទ្ធិមនុស្សអាស៊ី «សកម្មជនដីធ្លីចំនួន ២ នាក់ ត្រូវបានដាក់ពន្ធនាគារដោយសារតែមានការពាក់ព័ន្ធនឹងការធ្វើបាតុកម្មប្រឆាំងតវ៉ា» (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២), http://bit.ly/16HNn0T

ប៊ីប៊ីស៊ី «ក្មេងស្រីជំទង់ត្រូវបានបាញ់ស្លាប់ក្នុងពេលធ្វើការតវ៉ានៅកម្ពុជា» (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២), http://bbc.in/1asEipQ

ម.ស.ម.ក «ការប្រឈមនឹងការបណ្តេញចេញដោយបង្ខំជាលើកទី ២ របស់សហគមន៍ ភូមិអណ្តូងដោយគ្មានសំណង គឺជាការមើលស្រាលរបស់រដ្ឋាភិបាលចំពោះសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស» (វិចារណកថាព័ត៌មាន)(ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២) http://bit.ly/1athOVz

អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានគេបំពាន» (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/17FLZsD

អង្គការលីកាដូ/ការវិភាគរបស់កាសែតឌឹខេមបូឌាដេលី, «ការរូងយកកម្ពុជា៖ សម្បទានម្តងមួយៗ» (ថ្ងៃទី១១ និង១២ ខែមិនា ឆ្នាំ២០១២) http://bit.ly/Hpgih2

អង្គការលីកាដូ និងអង្គការសមធម៌កម្ពុជា «ញត្តិស្តីពី សម្បទានស្ករត្រូវបានដាក់ទៅគណៈកម្មាការសិទ្ធិមនុស្សជាតិរបស់ប្រទេសថៃ អង្គការនៅកម្ពុជា បានចោទប្រកាន់ថាការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនស្ករសយក្ស សាជីវកម្មស្ករមិត្តផុល» (សេចក្តីថ្លែងការណ៍) (ភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣) http://bit.ly/1asDi57

ការិយាល័យឧត្តមស្នងការអ.ស.ប «សហគមន៍ជនជាតិដើមភាគតិច ចំនួន ៣ នឹងទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព», (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១), http://bit.ly/Hxp24M

ទស្សនាវដ្តីអ្នកស្រាវជ្រាវអាជីព «ជុំវិញពិភពលោក ៖ ការគ្រប់គ្រងដីនៅកម្ពុជា, (ខែវិច្ឆិកា ឆ្នាំ២០១២), http://bit.ly/1inM2hN

កាសែត ឌឹ ខេមបូឌា ដេលី «ការបាត់បង់ព្រៃឈើនៅកម្ពុជា ជាការបាត់បង់មួយដ៏អាក្រក់នៅក្នុងពិភពលោក» (ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣), http://bit.ly/HYlubu

កាសែត ឌឹ ខេមបូឌា ដេលី «នគរបាលចាប់ខ្លួនអ្នកគ្រប់គ្រងក្រុមហ៊ុន ជីជីវ៉ាយ ពីបទបាញ់ប្រហារ» (ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២), http://bit.ly/1asDGR6

កាសែត ឌឹ ខេមបូឌា ដេលី «ក្រុមគ្រួសារនៅព្រះវិហារត្រូវបានបញ្ជាឲ្យចៀសផ្លូវឲ្យគ្រឿងយន្តឈូសឆាយ» (ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣) http://bit.ly/1ar0m45

កាសែត ឌឹ ភ្នំពេញប៉ុស្ត៍ «អ្នកភូមិនៅបឹងកក់ជិតទទួលបានកម្មសិទ្ធិដីធ្លី» ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣, http://bit.ly/1eh8OIb

កាសែត ឌឹ ភ្នំពេញ ប៉ុស្ត៍ «ក្មេងត្រូវវាយដំដោយសារតែដីសម្បទានសេដ្ឋកិច្ច» (ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣), http://bit.ly/17G8DH9

កាសែត ឌឹ ភ្នំពេញ ប៉ុស្ត៍ «ការបដិសេធប័ណ្ណកម្មសិទ្ធិដីធ្លី អ្នកភូមិនៅខេត្តពោធិ៍សាត់អះអាងប្រាប់។ (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣), http://bit.ly/1hikMGd

កាសែត ឌឹ ភ្នំពេញប៉ុស្ត៍ «ព្រះសង្ឃ បានចូលរួមក្នុងការពារព្រៃឈើ» (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២), http://bit.ly/17HNVXx

កាសែត ឌឹ ភ្នំពេញប៉ុស្ត៍ «ប័ណ្ណកម្មសិទ្ធិថ្មីនៅមិនទាន់បានទទួលស្គាល់ ៖ ប្រជាពលរដ្ឋ» (ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៣), http://bit.ly/1c3OSGm

កាសែត ឌឹ ភ្នំពេញ ប៉ុស្ត៍ «ស្រុកព្រះ បាននាំគ្នាមកតវ៉ាប្រឆាំងនឹងទាហាន» (ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២) http://bit.ly/1hil93t

កាសែត ឌឹ ភ្នំពេញប៉ុស្ត៍ «មន្ត្រីនគរបាលវាយដំមកលើសកម្មជនបុរីកីឡា» (ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣) http://bit.ly/16HM55V

កាសែត ឌឹ ភ្នំពេញ ប៉ុស្ត៍ «ដីចម្ការត្រូវបានជំនួសដោយបន្ទាយកងយុទ្ធពលខេមរភូមិន្ទ» (ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ២០១៣ http://bit.ly/1ar1NQ1

កាសែត ឌឹ ភ្នំពេញ ប៉ុស្ត៍ «មានការបាញ់ប្រហារពេលដែលប្រជាពលរដ្ឋត្រូវបានជម្លៀស» (ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៣), http://bit.ly/1asEFRi

វិទ្យុសំឡេងសហរដ្ឋអាមេរិក "មានប្រជាពលរដ្ឋមួយចំនួនត្រលប់មកវិញ បន្ទាប់ពីត្រូវបានជម្លៀសចេញពីតំបន់ដែលត្រូវអភិវឌ្ឍន៍ជាកន្លែងលម្ហែកាយ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1hiivuP

វិទ្យុសំឡេងសហរដ្ឋអាមេរិក «ចាប់ផ្តើមការងារ លើគម្រោងដ៏ចម្រូងចម្រាស់នៅកម្ពុជា» (ថ្ងៃទី៧ ខែឧសភា ឆ្នាំ ២០១៣) http://bit.ly/1hij4oe

## វេបសាយ និងវីដេអូ

អង្គការមាត្រា ១៩ «បុរីកីឡា ខ្សែវីដេអូដែលមិនមានការកែសម្រួល» (វីដេអូ), (ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២), http://bit.ly/16HGTis

ម.ស.ម.ក «ដោះលែង យ៉ោម បុប្ផា» (គេហទំព័រ), http://bit.ly/16HNKIK

អង្គការសមធម៌កម្ពុជា «កម្ពុជា ៖ ការបណ្តេញចេញនៅបឹងកក់» (វែបសាយ), http://bit.ly/16HLjpr

ការអភិវឌ្ឍន៍អន្តរជាតិដែលមានលក្ខណៈរួមបញ្ចូល «កម្ពុជា ៖ ការបណ្តេញចេញនៅតំបន់បឹងកក់» (វែបសាយ) http://bit.ly/16HLjpr

អង្គការលីកាដូ «សកម្មជនបឹងកក់ត្រូវបានក្រុមនគរបាលវាយដំយ៉ាងសាហាវ ក្នុងអំឡុងពេលការបណ្តេញចេញ» (វីដេអូ) (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១), http://bit.ly/16HKpJR

អង្គការលីកាដូ «បុរីកីឡា ការបំភ្លេចពាក្យសន្យា» (វីដេអូ), (ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣), http://bit.ly/1asHxO7

អង្គការលីកាដូ «មន្ត្រីយោធាបាញ់ប្រហារមកលើអ្នកតវ៉ាទាមទារដីធ្លី ក្នុងប៉ែកខាងជើងភាគខាងកើតនៃប្រទេសកម្ពុជា» (វីដេអូ) (ថ្ងៃទី២១ ខែមករា ឆ្នាំ២០១២) http://bit.ly/1asFWHS

អង្គការលីកាដូ «ការបង្ហាញដ៏អស្ចារ្យរបស់កម្ពុជា ៖ បង្ហាញពីដីសម្បទានក្នុងរយៈពេលនីមួយៗ», (ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣) http://bit.ly/HxpSOV

វិទ្យុអាស៊ីសេរី «ការបណ្តេញចេញនៅបឹងកក់ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ ៖ រឿងរ៉ាវរបស់វិទ្យុអាស៊ីសេរីនៅពីក្រោយរឿងរ៉ាវទាំងមូល» (វីដេអូ) (ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១) http://bit.ly/16HKddx

ការគំរាមកំហែង ព្រៃឡង់ (វែបសាយ), http://bit.ly/1hPRa0H

ភ្នាក់ងារស៊ើបអង្កេតកណ្តាលរបស់សហរដ្ឋអាមេរិក, «កណត់ហេតុទូទៅរបស់ពិភពលោក» ស្តីពីសេដ្ឋកិច្ចកម្ពុជា http://1.usa.gov/HpceNG